# ប្រជុំពាក្យទព្យជនិ

## មានសេចក្ដីពន្យល់ពាក្យនីមួយៗ ដោយសព្វគ្រប់

ការផ្សាយរបស់

លេខ ៨៨ វិថីតេជោដំឌិន ភ្នំពេញ

ព.ស. ២៤៩៩ គ.ស. ១៩៥៦

រក្សាសិទ្ធិ

២៥៛០០

CA 13

# ប្រជុំពាក្យទប្បជទិ

រៀបរៀង (8/6/a.l/B.Th)

ដោយ

ទ្បូប-គិមសឿន

le 15/7/56

ព្រះទេពសត្ថា គិម-ទ្បូរ (បរុមង្គលោ)

បានជួយកែសម្រួលត្រឹមត្រូវហើយ


បណ្ណាគារ គិម-គី លេខ ៨៨

វិថី គេដាដំឌិន ភ្នំពេញ

នៅខាងកើតរោងកុនព្រហ្មបាយ័នផ្ទាល់

ព.ស. ២៤៩៩ គ.ស. ១៩៥៦

# បុព្វកថា

មុននឹងរៀបរៀងសៀវភៅនេះឡើង, ខ្ញុំបានយោបល់យល់ឃើញថា កម្ពុជរដ្ឋយើងនេះ ទើបតែទទួលឋានៈជាអត្តាធីន (ឯករាជ្យ) ជាប្រថម ប្រជាជនក៏ខំប្រឹងស្រាវស្រទេញនិយមប្រើអក្សរសាស្ត្រជាតិកាន់តែមានដោយភាគច្រើន ។ ឯសារពត៌មានក្តី សៀវភៅផ្សេង ៗ ដែលអ្នកនិពន្ធរៀបរៀងជាគតិលោក ឬគតិធម៌ក្តី មានផ្សាយចេញទៅហើយច្រើនជាប់ទាក់ទងដោយ " អគ្គវាទ " ពាក្យខ្ពស់ ឬ ពាក្យបំឡែក ពិបាកស្តាប់ទាំងពិបាកអាន, ម៉្លោះហើយប្រជាជនពួកខ្លះ ក៏ពុំទាន់មានឆន្ទៈដំស្មោះស្ម័គ្រ ឬ ពុំទាន់សិប់ចិត្តនៅឡើយ ព្រោះមកអំពីមិនធ្លាប់ប្រទះ មិនធ្លាប់ថា ។

រឿងនេះ សូមជំរាបថា ភាសាក្នុងលោក តាមតែភាសាជាតិណាក៏ដោយ សុទ្ធតែមានពាក្យខ្ពស់ ពាក្យទាប ពាក្យពិបាក ពាក្យងាយ ដូចគ្នាទាំងអស់, កាលដែលប្រទេសយើងធ្លាក់នៅក្នុងអំណាចអាណាព្យាបាលបារាំងសែស ជិត

មួយសតវត្សរ៍នោះ, វប្បធម៌របស់ខ្មែរមានពាក្យពេចន៍ជាដើម បេះតែរបេះរេចរឹលបាត់បន្តិចម្តងៗ ស្ទើរតែទាំងអស់, ម្ល៉ោះហើយក៏យកពាក្យបារាំងសែសមកប្រើលាយចម្រុះជាមួយនឹងភាសាជាតិ ។ លុះដល់វេលា អាណាព្យាបាលបារាំងសែសថយចេញទៅ យើងជាម្ចាស់ស្រុក ស្រាប់តែខ្វះពាក្យជាតិសម្រាប់ប្រើឲ្យទាន់សម័យច្រើនណាស់ ។ ការខ្វះនេះឯងហើយ ដែលមកបង្គាប់ខ្ញុំឲ្យនិពន្ធពាក្យរៀបរៀងទុកក្នុងសៀវភៅនេះឡើង ។

ការរៀបរៀងនេះ, ខ្ញុំបានរើសប្រមូលយកពាក្យដែលគណៈកម្មការវប្បធម៌បានបង្កើតឡើងនោះខ្លះ រើសយកពាក្យដែលមានក្នុងសៀវភៅដទៃខ្លះ តាមមតិរបស់ខ្ញុំខ្លះ មករួបរួមរៀបរៀងតាមលំដាប់អក្សរតាំងពី ក ដល់ អ ។ នៅខាងចុង មានរៀបរៀងជាពាក្យបកិណ្ណកៈ ត្រង់នេះខ្លះ ត្រង់នោះខ្លះ មិនហូរហែរតាមលំដាប់អក្សរដូចខាងដើមទេ ព្រោះសម្រាប់ជាជំនួយដល់ពាក្យខាងដើមក្រែងពុំមានដោយសព្វគ្រប់

ហើយកំណត់ឲ្យឈ្មោះសៀវភៅនេះថា "ប្រជុំពាក្យវិប្បធម៌" មានសេចក្ដីពន្យល់ពាក្យនីមួយ ៗ ល្មមស្ដាប់យល់បាន តាមសម័យនិយម ។

ខ្ញុំយល់ថា សៀវភៅប្រជុំពាក្យវប្បធម៌នេះ មានប្រយោជន៍យ៉ាងសំខាន់ដល់ក្រុមអ្នកសិក្សាគឺគ្រូបង្រៀននិងសិស្សផង ដល់អ្នកអានសារពត៌មាននិងសៀវភៅផ្សេង ៗ ផង ដល់អ្នកនិពន្ធអត្ថបទផ្សេង ៗ ផង ទាំងផ្នែកសាសនា ទាំងផ្នែកអក្សរសាស្ត្រមិនចំពោះមនុស្ស ។ បើអស់លោក-អ្នកមានសៀវភៅនេះជាគូដៃ ក៏ហាក់ដូចជាមានគ្រូ ឬ មិត្តម្នាក់យ៉ាងវិសេស នៅប្រចាំខ្លួនហើយពន្យល់បំភ្លឺអស់លោក-អ្នកជានិច្ច ។

ធ្វើនៅថ្ងៃ ខែ ២៤៩៨ / ១៩៥៦

ឡុង-គឹមសៀង

# សង្កិត្តបណ្ណ

## កន្សែលខប័ត្រនេះ

| | | |
|---|---|---|
| ប. ក្ល. | គឺៈ | ប្រើក្លាយជា |
| ន. គុ. | ,, | នាម ឬ គុណនាម |
| គុ. | ,, | គុណនាម |
| ន. | ,, | នាម ឬ នាមនាម |
| កិ. | ,, | កិរិយា |
| កិ. វិ | ,, | កិរិយាវិសេសន៍ |
| ប. ព. ក. | ,, | ប្រើកន្សែពាក្យកាព្យ |
| កិ. គុ. | ,, | កិរិយា ឬ គុណនាម |
| ម. បិ. | ,, | មើលថា |
| ក្ល. | ,, | ក្លាយជា |
| ស. និ. | ,, | (ច្រើនប្រើកន្ស.) សម័យនិយម, |
| ព. ធ. | ,, | ពាក្យធម្មតា |

# អក្សរសាស្ត្រជាតិនិយម

កម្មករ ន. អ្នកធ្វើការបំរើដោយឈ្នួល, អ្នកស៊ីឈ្នួល, គូលី ។

កលហភាព ន.គុ. ដំណើរឈ្លោះគ្នា ។

កវី ន. អ្នកប្រាជ្ញខាងសំដី ។

កសិកម្ម ន. ការភ្ជួររាស់, គឺការធ្វើស្រែចំការ ។

កសិការ ន. អ្នកធ្វើកសិកម្ម ។

ការិយាល័យ ន. កន្លែងធ្វើការ, បន្ទប់ធ្វើការ ។

កាសាវពស្ត្រ ន. សម្ពត់ជ្រលក់ទឹកអម្ចត់ ។

កេណ្ឌាពិរុណសាស្ត្រ (ម.ថ.កែន–) ន. ទាយទឹកភ្លៀង, ក្បួនសម្រាប់កំណត់សំគាល់នូវទឹកភ្លៀង ។

កោសេយ្យពស្ត្រ (ម.ថ. គោសៃយៈ–) សំពត់សូត្រ, សំពត់ព្រែ,

ក្រមការៈ ន. អ្នកធ្វើការ (ងារក្នុងដំណែងរាជការ....)

ក្សេត្រាធិការ ន. ឈ្មោះក្រសួងដែលបង្គាប់បញ្ជាត្រួតត្រាលើការស្រែ, -ចំការ, -ច្បារដំណាំ ។

ខេមរភាសា ន. សំដីខ្មែរ, ពាក្យខ្មែរ ។

គន្ធពិដោរ គ្រឿងក្រអូប, ក្លិនក្រអូបល្អ ។

គន្ធព្វ ន. ទេវតាពួករបាំ ។

គន្ធជាតិ ន. គ្រឿងក្រអូប, ជាតិក្រអូប ។

គម្ភីរភាព ន.គុ. ដែលមានភាពជ្រាលជ្រៅ ។

គមនាគមន៍ ន. ដំណើរទៅមក ។

គេហដ្ឋាន, គេហស្ថាន ន. ទីផ្ទះ, ផ្ទះទាំងមូល ។

គេហជន ន. មនុស្សដែលនៅក្នុងផ្ទះ, អ្នកផ្ទះ ។

គោឃាតក៍ (ម.ថ.-ឃាត.) អ្នកសម្លាប់គោ ។

គោឃាតដ្ឋាន,-ស្ថាន កន្លែងដែលគេពិឃាតគោ ។

គោរក្ខកម្ម ន. ការរក្សាគោ, របរចិញ្ចឹមគោ ។

គោរក្ខ ន. អ្នកចិញ្ចឹមគោ, ការរក្សាគោ, ។

ចក្រពង្ស ន. វង្សនៃស្តេចចក្រពត្តិ ។

ចតុស្តម្ភ ន. សសរ៤, ដែលមានសសរ៤ ។

ចន្ទច្ឆាយា ន. ស្រមោលព្រះចន្ទ ។

ចន្ទមណ្ឌល ន. វង់ព្រះចន្ទ, រូបព្រះចន្ទ ។

ចន្ទគ្រាស ន. ការចាប់ព្រះចន្ទនៃរាហូអសុរិន្ទ ។

ចោរកណ្តក (ម.ថ. កន្ទ) ចោរដែលទុកស្មើបន្លា - ទុកស្មើបម្រុង ។

ចោទ កិ. សួរដណ្តឹង, ដាក់ប្រស្នាឲ្យរក, ប្តឹងប្រកាន់ ។

ចោទក ន. អ្នកចោទ, (ខាងចោទគេអាងថា...)

ចោរឃាត ន. ការពិឃាតចោរ, ធ្វើចោរឃាត ។

ចោរឃាតក ន. អ្នកពិឃាតចោរ, អ្នកសម្លាប់ចោរ ។

ចៅក្រម ន. មន្ត្រីតុលាការ, មន្ត្រីជំរះក្តី ។

ឆដាកា ន. ផ្លេកបន្ទោរ, ពន្លឺភ្លៀលទ្វាត់ ។

ឆាតកាល ន. កាលដែលអត់ឃ្លាន, សម័យដែលអត់បាយ ។

ជនក ន. បុរសអ្នកបង្កើតកូន, (បិតា)

ជរាទុព្វលភាព ន. ដំណើរថយកម្លាំងព្រោះជរា ។

ជលន័យន៍ (ម.ថ. ជ:ល:នៃ) ទឹកភ្នែក ។

ជលបថ (ម.ថ. បត់) ផ្លូវទឹក, ដើរទឹក ។

ជលភាជន៍ ន. ថូទឹក, ផ្តិលទឹក, ក្អមទឹក,... ។

ជលយន្ត ន. រហាត់ទឹក, ស្នប់ទឹក, នាឡិកាទឹក ។

ជលស័យ ន. ទន្លេសាប... ។

ជលាល័យ ន. អណ្តូង, ស្រះ... កន្លែងទុកទឹកភ្លៀង ។

ជវ័ន ន. (ម.ថ. ជាន់) កំឡាំងដែលស្ទុះ, សំទុះចិត្ត ។

ជាតស្រះ ន. ស្រះដែលកើតឯង, ដូចត្រពាំងជាដើម

ជីវិត ន. ការចិញ្ចឹមជីវិត, ដំណើររស់នៅ ។

ជីវិត្ត គ. គំពុងរស់នៅ ។

ជុណ្ហបក្ស ន. ចំណែកខាងខ្នើត ។

ជូតកម្ម ន. ការលេងល្បែងភ្នាល់, អំពើភ្នាល់ ។

ជោគនាការ ន. អាការនៃសេចក្ដីរុងរឿង, អ្នកមានសេចក្ដីរុងរឿង ។

ជោតិភាព ន. បែប-ភាពនៃពន្លឺ-រស្មី ។

ឈាបនកិច្ច ន. ការដុតសពខ្មោច ។

ឈាបនដ្ឋាន ន. កន្លែងសម្រាប់ដុតសព (ខ្មោច) ។

ញាណសម្ភារ ការសន្សំប្រមូលសេចក្ដីដឹងទុកឲ្យមានច្រើន

ញាណសាស្ត្រ ន. ក្បួនព្យាករណ៍, ក្បួនសម្រាប់ទាយ ។

ញាតិពន្ធ (ឬ.ថ.ញាតិពន់) ជនដែលគេរាប់ថាជាញាតិ ដោយជាប់ទាក់ទងគ្នា, ដូចម្ដាយក្មេក..., (ជាញាតិ

សម្ពន្ធក៏មាន)

ញាតិវង្ស (ម.ថ. វង់) តំណនៃញាតិ, ពួកញាតិ ។

ឋបនាការ ន. អាការដែលបិត, ដែលតាំង, ដែល ដំកល់នៅ ។

ឋបនីយភណ្ឌ ន. ទ្រព្យ, របស់ដែលគួរតាំងទុក ។

ឋមនោបាយ ន. ឧបាយ, គំនិតបេះទុកបេះដាក់ ។

ឋានបទ្ម (ម.ថ. ឋានៈបត់) ទីដំកល់ផ្កាឈូក (ស.ពុ. ច្រើន ថា ក្បាច់ត្របកឈូកផ្កាប់ផ្ងារ ដែលរចនាជាជើងទ្រព្រះពុទ្ធរូប ។

ឋានីយ (ម.ថ. នីយ្ណី) ទីសំរាប់សំណាក់, ទីបត ។

ឋាមរា ន. ក្មាន, ហង្ស ។

តក្កវិទ ន. អ្នកចេះតក្កវិជ្ជា - តក្កសាស្ត្រ ។

តរុណបុត្រ ន. កូនខ្ចី ។

តុល្យភាព គុ. ឬ ន. ភាពដែលស្មើគ្នា,- ដែលស្របគ្នា ។

ត្រីបថ ន. ទីប្រជុំផ្លូវបែកជាបី ។

ត្រីចក្រយាន ន. យានមានកង់បី

ត្រីមាស ន. បីខែ (ត្រៃមាសក៏មាន) បញ្ញត្រីមាស ។

ថលបថ ន. ផ្លូវគោក, ដើរគោក ។

ថាវរៈ គុ. មាំមួន, មាំទាំ, ឋិតថេរ ។

ថាវរកម្ម ន. ការមាំមួន, ការមាំទាំ ។

ថោមនាការ ន. អាការ-ដំណើរនៃសេចក្ដីសរសើរ ។

ទក្ខិណាវត្តិ (ម.ថ.-ព័រ) ន. ដំណើរដែលដើរវិលជា

ទក្សិណក្នុងឱកាសនៃកិច្ចការណាមួយ ។

ទព្វសម្ភារៈ (ម.ថ..សំភា:) គ្រឿងប្រុង សម្រាប់ផ្គុំដំឡើង ។

ទមភាព ន. ភាពនៃការទូន្មាន, ដំណើរទូន្មាន ។

ទស្សនាការ ន. អាការនៃការឃើញ, លក្ខណៈនៃការ

ឃើញ ។

ទស្សនូបចារ ន. ទីជិតល្មមមើលឃើញច្បាស់ ។

ទឡ្ហការី ន. អ្នកធ្វើការមាំទាំ, ជាអ្នកព្យាយាមមាំ ។

ទឡ្ហីករណ៍ ន. ពាក្យឬសេចក្ដីផ្សេង ដែលទាញនាំយកមក
អាងដើម្បីឲ្យមាំ ... ។

ទារុណកម្មឬទារុណក័ម្មន. អំពើកាច, អំពើអាក្រក់ ។

ទារុណភាព ន. ភាពជាអ្នកកាច, ដំណើរអាក្រក់ ។

ទាសភាព, ទាសព្យ ន. ភាពខ្ញុំគេ ( ភាពគេជិះជាន់ )

ទាសកម្មករ ន. ពួកខ្ញុំកំដរទើនអ្នកធ្វើការស៊ីឈ្នួល ។

ទិដ្ឋធម្មិក គុ. ដែលមានក្នុងបច្ចុប្បន្ននេះ,–ក្នុងជាតិនេះ ។

ទិដ្ឋភាព ន.ភាពដែលមើលឃើញ, ភាពដែលឃើញ(រូបថត)

ទ្រឹស្ដី ន. ដំណើរយល់ឃើញ, សេចក្ដីប្រកាន់តាមការយល់
ឃើញ ។

ទិវាករ ន. ព្រះអាទិត្យ ។

ទិនិកា ន. ឈ្នួលថ្ងៃ, ប្រាក់ថ្ងៃ, (មាសិកា ប្រាក់ខែ, ឈ្នួលខែ

ទិវិន ន. ថ្ងៃ

ទិវសភាគ ន. ចំណែកនៃថ្ងៃ (ពេញមួយថ្ងៃតាំងពីព្រឹកទល់ល្ងាច)

ទុក្ករការណ៍ ន. ហេតុដ៏កម្រ, ដំណើរកម្រ ។

ទុគ្គតបណ្ណាការ ន. កន្សុការ, ដង្វាយ, ជំនូនរបស់អ្នកក្រីក្រ ។

កញ្ញា ន. ស្រីក្រមុំ, ។

ទេវឫទ្ធិ ន. ឫទ្ធិរបស់ទេវតា ។

ទេសភាព. ន. ដំណើរដែលប្លែក, ដែលមានអ្វីៗប្លែកខុសពីធម្មតា ។

ទោសការណ៍ ន. ហេតុដែលនាំឲ្យកើតទោស ។

ទ្វារបាល ន. អ្នកចាំទ្វារ, ឆ្មាំទ្វារ ។

ទ្វាទសមាស ន. ខែទាំងដប់ពីរ (បុណ្យទ្វាទសមាស)។

ទ្វិជាករ ន. ហ្វូងបក្សី ។

ទ្វិបថ ន. ផ្លូវបែកជាពីរ ។

ទ្វិបទ ន. សត្វមានជើងពីរ ។

ទ្វេគុណ គុ. ដែលគុណដោយចំណែកពីរ ។

ធនប័ត្រ ន. ក្រដាស់ប្រាក់ ។

ធម្មកថា ន. ការសំដែងធម៌, សំដីដែលជាធម៌ ។

ធនាគារ ន. ឃ្លាំងដាក់ប្រាក់ ។

ធនាករ ន. គំនរទ្រព្យ (ក្រុមអ្នកមានទ្រព្យច្រើន) ។

ធនាធិការី ន. អ្នករក្សាឃ្លាំង, អ្នករក្សាទ្រព្យ ។

ធនិន ន. ដេស្ឋា, អ្នកមានទ្រព្យ ។

ធម្មបទ ន. ផ្លូវធម៌, លំអានធម៌ ។

ធម្មសភា ន. សាលាប្រឹក្សាអំពីធម៌, សាលាយុត្តិធម៌... ។

ធម្មសាត្រ (ម.ថ. - សាត) សេចក្ដីសំដែងអំពីយុត្តិធម៌,

ច្បាប់ធម្មសាត្រ ។

ធូមកេតុ ន. ផ្កាយដុះកន្ទុយ ។

នគរជន ន. ជនអ្នកនៅក្នុងក្រុង, (អ្នកក្រុង) ។

នគរបាល ន. អ្នករក្សាក្រុង, ក្រសួងឬក្រុមរាជការដែល

ត្រួតត្រារក្សាប្រជាជនក្នុងក្រុង (អ្នកត្រួតត្រាផ្សារ) ។

នភកេតន៍ ន. ព្រះអាទិត្យ, ថ្ងៃ ។

នភមណ្ឌល ន. អាកាសទាំងមូល, មណ្ឌលពពក ។

នភាល័យ ន. មេឃ, អាកាស ។

នភោធូម ន. ពពកដែលសោតមើលទៅឃើញដូចផ្សែង ។

នរពិសុណ៌ (ម.ថ.-ពិស )បីសាច, អារក្សទឹក, អាប,

ព្រាយ (អ្នកស៊ីមនុស្ស ) ។

នរាសភ ន. អ្នកដែលប្រសើរ (ព្រះសម្មាសម្ពុទ្ធ) ។

នរិន្ទ្រ ន. ក្សត្រិយ៍ទ្រង់រាជ្យ ។

នវាគតភណ្ឌ ន. របស់ទើបមកដល់ថ្មី ៗ ។

នវោត្បន្ន គុ. ឬ ន. របស់ទើបកើតថ្មី, របស់ទំនើប ។

នានាប្រទេស ន.គុ. ប្រទេសផ្សេងៗគ្នា, នៅក្នុងប្រទេស

ផ្សេងៗគ្នា ។

នាភី ន. ផ្ចិត ។

នាវិក ន.ឬគុ. អ្នកដើរទូក, កប៉ាល់... ។

នាវិកសាស្ត្រ ន. ក្បួនប្រាប់វិធីដើរទូក, -កប៉ាល់ ។

នាសិករោគ ន. រោគឫសដូងច្រមុះ, រោគផ្កាសសាយ ។

និករ ន. (ពួកសត្វ) ពួក, ហ្វូង ។

និគម ន. ប្រជុំភូមិច្រើន, ទីផ្សារនីមួយៗក្នុងខេត្តក្រៅ ។

និគ្រោធ ន. ដើមជ្រៃ ។

និច្ចកាល កិ.វិ. គ្រប់ពេល, គ្រប់វេលា ។

និទ្ទេសបទ ន. បទដែលញែកចេញ, បទដែលសំដែង

ញែកចេញ ។

និទ្រា ន. ដំណេករដេកលក់ (ក្.ជា និន្ទ្រា ក៏មាន) ។

និន្នាទ ន. សូរស័ព្ទកង់រំពង ។

និពន្ធ គុ. ដែលចងហើយ, ដែលតែងហើយ។ន. អ្នកតែងរឿង

និមល គុ- ដែលឥតមន្ទិល, ឥតសៅហ្មង ។

និរទុក្ខ គុ. ដែលឥតទុក្ខ-ឥតព្រួយ ។

និរទេស ន. ដំណើរបំបរបង់ឲ្យចេញអំពីប្រទេស ។

និវេសន៍ ឬ និវេសដ្ឋាន ន. ទីសម្រាប់នៅ (ផ្ទះ)

និស្ទីទនាការ ន. អាការនៃកិរិយាអង្គុយ ។

នីតិបញ្ញត្តិ ន.សេចក្តីហាមប្រាមរបស់ច្បាប់, ការតាំងច្បាប់

នីតិប្រតិបត្តិ ន. ការប្រព្រឹត្តតាមច្បាប់, (ការកាន់ច្បាប់) ។

នេសាទុបករណ៍ ន. ប្រដាប់នេសាទ, ប្រដាប់ប្រដារ

សម្រាប់នេសាទ. គ្រឿងប្រដាប់សម្រាប់ចាប់ត្រី ។

បញ្ចព័ណ៌ ន. គុ. ពណ៌ ៥ យ៉ាង ។

បញ្ញាការ ន. ការបង្គាប់, អ្នកបង្គាប់ ។

បណ្ណាការ ន. ជំនូន, ភ័ស្តុភារ, ជង្វាយ ។

បរទេស ន. ប្រទេសដទៃ, អ្នកប្រទេសដទៃ ។

បរមត្ថវិជ្ជា ន. វិជ្ជាមានប្រយោជន៍ដ៏ឧត្តម។

បរិភាសន៍ ន. ពាក្យតិះដៀល, ការពោលទោសគេ ។

បរិរក្ស (ម. ថ. បៈ រិ រ័ក) ការគ្រប់គ្រង,ការបីបាច់ថែទាំ ។

បាទបរណ៍ ន. ការដើរដោយជើង (ឥតយានជំនិះ) ។

បារម្ភ ន. ដំណើរទឹកថប់, ឬទឹកព្រួយជាមុន ។

បារាយណ៍ ន. ប្រទេសដែលមានទឹកវាលល្ហល្ហោវធំធេង។

បុញ្ញវន្ត គុ. ឬ ន. អ្នកមានបុណ្យ, - មានសំណាង, ដែលមានបុណ្យ ។

បុញ្ញសិរី ន. ស្រីសួស្តីដែលកើតអំពីបុណ្យ ។

បុប្ផជាតិ ន. ផ្កាគ្រប់យ៉ាង, ជាតិផ្កា ។

បុប្ផវិក័តិ ន. ការធ្វើផ្កាឲ្យប្លែក, ផ្កាកម្រងផ្សេងៗ ។

បុប្ផាកេសរ លំអងផ្កា ។

បុប្ផារាម ន. សួនច្បារ, សួនផ្កា ។

បុព្វករណ៍ ន. ការពយរងដែលត្រូវចាប់ធ្វើមុន ។

បុព្វបុរស ន. បុរសជាខាងដើមវង្ស, ពួកញាតិតាំងអស់ ។

បុព្វហេតុ ន. ហេតុដើម, ដំណើរដើម ។

បុរាណកាល ន. កាលពីព្រេងនាយ ។

បុរាណវត្ថុ ន. ទ្រព្យចាស់, របស់ចាស់ ។

បូជនីយ គុ. ដែលគួរបូជា ។

បូជនីយដ្ឋាន. ន. កន្លែងគួរបូជា, កន្លែងសម្រាប់បូជា ។

បោក្ខរណី ន. ស្រះមានឈូក ។

បោក្ខរព័ស៌, បោក្ខរព័ស្ស (ម. ថ.-ព័រ) ភ្លៀងមានអា

ការដូចជាធ្លាក់លើស្លឹកឈូក ។

ប្រត្យន្តប្រទេស ន. ជនបទនៅចុងប្រទេស, ប្រទេសចុងប្រទេសធំៗ ។

បច្ចេកន័យ ន. លំនាំផ្សេងដោយឡែក,-ដោយខ្លួន ។

បច្ចេកទេស ន. ការបង្អុលបង្ហាញដែលផ្សេងពីគេ, ការសំដែងឡើងផ្សេងដោយខ្លួន ។

បច្ឆាភត្ត ន. វេលាខាងក្រោយភត្ត ។

បច្ឆាជនតា, បច្ឆិមជនតា ន. គុ. ពួកជនដែលកើតជាខាងក្រោយ ។

ប្រតិកម្ម ន. អំពើដែលប្រឆាំង,-ដែលការពារ,ដែលតទប់ ។

ប្រតិការ ន. ដំណើរធ្វើកិច្ចតបគុណ ។

ប្រតិកូល គុ. ដែលផ្ទុយគ្នា, ដែលខុសគ្នា ។

ប្រតិទិន ន. ប្ក. កិ. វិ. រៀងរាល់ថ្ងៃ ។ បញ្ជីចុះចំនួនតាពង ។

ឈ្មោះថ្ងៃ, ខែ ប្រើក្នុង១ឆ្នាំៗ (ខែរ.ប្រ.ជា ប្រក្រតិទិន)

ប្រតិបក្ស, បដិបក្ខ (ម.ថ–ប៉ុក) សត្រូវ, ខ្មាំង ។

បដិមាករ ន. រូបប្រៀប រូបសំណាក (ព្រះពុទ្ធរូប)

បដិសណ្ឋារៈ ន. ការទទួលរាក់ទាក់ ។

បដិសេធ កិ. (ម.ថ.-សែត) ឃាត់, ហាមប្រាម, លើក-

ចោល ។

បដិសេធ បដិសេធន៍ ន. ការឃាត់, ការហាម, ដំណើរ

លើកចោល, លែងយកជាការ ។

បទានុក្រម ន. លំដាប់បទ, លំដាប់ពាក្យរៀងតាមអក្សរៗ

បរមេស្ឋ ន. អ្នកដែលប្រសើរក្រៃលែង ។

បរាមុខ ន.កិ. ធ្វើឡែកាប់មុខ, សេចក្ដីវិនាស ។

បរាជ័យ ន. ការចាញ់, ដំណើរចាញ់គេ ។

បរិនាយក ន. អ្នកត្រួតត្រាដឹកនាំគេ ។

បរិមណ្ឌល ន. វង់មូល, អ្វីៗដែលមានសំណុំមូល ។

បរិយត្តិ ន. ការហាត់រៀន, ការរៀនសូត្រ (ព្រះត្រៃបិដក)

បរិយោសាន ន. ទីបំផុត, ទីចប់, សេចក្ដីចប់ ។

បវត្តិការណ៍ ន. ហេតុនៃការប្រព្រឹត្តទៅ, ហេតុនៃបវត្តិ ។

បុគ្គលិក គុ. ដែលចំពោះបុគ្គលឬ សម្រាប់បុគ្គលម្នាក់មិន

មែនទូទៅ ។

បវត្តិសាស្ត្រ ន. ក្បួនសំដែងអំពីពង្សាវតារ ។

បុព្វកិច្ចឬបុព្វកិច្ច ន. (ម.ព. បុព្វករណ៍) កិច្ចខាងដើមៗ

បាដិភោគ ន. អ្នកធានា, អ្នកទទួលរ៉ាប់រងដំណើរអ្វីៗជួស

អ្នកដទៃ ។

បាឋក ន. អ្នកសូត្របាឡី, អ្នកសំដែងរឿងរ៉ាវ ។

បាឋកថា ន. សំដីសំដែងរឿងរ៉ាវ, –ថ្លែងសេចក្ដី ( មាត់

ទទេ ) ។

ប្រកាសនីយបត្រ ន. សំបុត្រសំដែងគុណសម្បត្តិរបស់បុគ្គលអ្នកមានចំណេះវិជ្ជាអ្វីមួយគ្រប់គ្រាន់គួរដល់កិច្ចការហើយ (សញ្ញាបត្រ) ។

ប្រកាសនីយ (ម.ថ.–នី) ដែលគួរសំដែង, ដែលគួរប្រកាស ។

ប្រត្យក្ស គុ.កិ.វិ. ដែលប្រាកដជាក់ច្បាស់ ។

ប្រណិធាន ន. ការតាំងសេចក្ដីប្រាថ្នា ។

ប្រតិភូ ន. អ្នកធានា, អ្នកជំនួស, អ្នកតំណាង ។

ប្រតិស្ឋាន ន. ការតាំងនៅ, ការបិតនៅ ។

ប្រទោសកាល ន. ពេលប្រលប់ ។

ប្រធានាធិបតី ន. អ្នកដែលជាធំជាងគេទាំងអស់, អ្នកធំដែលប្រជាជនរើសឲ្យធ្វើជាអធិបតី ។

ប្រភព ន. ដែនកើត, ក្បាលស្ពឹង, ក្បាលទន្លេ ។

ប្រភាត ន. ព្រឹកព្រាង, ព្រឹកព្រហាម, ពេលព្រះអាទិត្យរះ ។

ប្រមោទ, ប្រមោទ្យ ន. សេចក្ដីរីករាយ, -ពេញចិត្តខ្លាំង ។

ប្រល័យ ន. សេចក្ដីវិនាស, លោកវិនាស ។

ប្រសាសន៍ ន. ពាក្យបង្គាប់, ពាក្យផ្ដាំផ្ញើ, -បណ្ដាំ ។

ប្រសូតិគ្រឹះ ន. ផ្ទះសម្រាប់សម្រាលកូន ។

ប្រសូតិកម្ម ន. ការសម្រាលកូន ។

ប្រស្រ័យ ន. ការពឹងពាក់, -រាប់អាន, -គោរព,- ដំណើរត្រូវអធ្យាស្រ័យគ្នា ។

បាការភាព ន. ភាពជាកំពែង-ប្ញបន្ទាយ ។

ផលកាល ន. រដូវឈើមានផ្លែ ។

ផលសិទ្ធិ (ម.ថ-សិតធិ, ឬសិត) ការសម្រេចផល ។

ផលសម្ប័ទ ន. ការបរិបូណ៌ដោយផល, ការចំរើនផល ។

ផលព្រឹក្ស ន. ឈើដែលមានផ្លែ (បុប្ផព្រឹក្ស ឈើដែល

មានផ្កា )

ផលិតផល ន. សេចក្ដីចំរើន–, ការដុះដាលដែលផ្សាយ

ទូទៅ ។

ពនាស្រ័យ ន. អ្នកនៅក្នុងព្រៃ, ការនៅក្នុងព្រៃ ។

ពនេចរ ន. អ្នកត្រាច់ទៅក្នុងព្រៃ, (ព្រានព្រៃ) ។

ពន្ធនាការ ន. អាការដែលជាប់, អាការដែលចង, ដែល

ជំពាក់ទៅ ។

ពន្ធនាគារ ន. ផ្ទះសម្រាប់ឃុំខាំង (គុក)

ពលក្ការ (ម.ថ. ពះល័ក.កា) ការកំហែង, ការគំរាម ។

ពស្ត្រាលង្ការ ន. សំពត់និងគ្រឿងប្រដាប់កាយ ។

ពហុការី ន.បុគ្គ. អ្នកធ្វើការច្រើន ។

ពាណិជ្ជកម្ម ន. ការលក់ដូរ, របរលក់ដូរ, ការជួញ ។

ពាណិជ្ជការ ន. អ្នកធ្វើជំនួញ ។

ពាណិជ ន. ឈ្មួញ, អ្នកលក់ដូរ ។

ពាឌីរ ន. អ្នកធ្វើការឈ្នួល, កូនឈ្នួល ។

ពាទ្យភណ្ឌ ន. គ្រឿងប្រគុំមួយវង់, គ្រឿងតន្ត្រីមួយវង់

ពានរិន្ទ ន. ស្តេចស្វា ។

ពាយុគុល្ម ន. ខ្យល់កំបុតត្បូង ។

ពិជ័យសង្គ្រាម ន. ពួកយោធាក្រុមទ័ពស្រួច ។

ពិទ័គ្ធ គុ. វាងវៃ, ប្រសប់, ដែលមានបំណោះ ។

ពិទ្យាធរ ន. អ្នកទ្រទ្រង់វិជ្ជា (អ្នកចេះដឹង) ។

ពិធុរភាព ន. ការកើតទុក្ខម្នេញ, ដំណើរព្រាត់ប្រាស
ភរិយាស្វាមីជាដើម ។

ពិភ័ក្តិរក្សា ន. បែកមុខគ្នារក្សា, ផ្លាស់វេនគ្នារក្សា ។

ពិភពលោក ន. សេចក្តីចំរើន, ទីកើតផ្សេងៗក្នុងលោក
(លោកទាំងមូល, ស. ន.)

ពិភាក្សា កិ. (ម.ជ.ពិ.ភាកសា) ជជែកពិគ្រោះគ្នា, ប្រឹក្សារកឲ្យឃើញខុសត្រូវ ។

ពិរាល័យ ន. លំនៅរបស់អ្នកក្លៀវក្លា, -- អ្នកអង់អាច ។

ពិរុណសាស្ត្រ ន. ក្បួនទាយទឹកភ្លៀង, – សម្រាប់ទាយទឹកភ្លៀង ។

ពិសោធន៍ ឬ ពិសោធ ន. ការល្បងមើល, ដំណើរពិនិត្យ ឬសាកមើលឲ្យឃើញពិត ។

ពិរុទ្ធ គុ. ខុស, ដែលទទៃពីគ្នា, ដែលផ្ទុយគ្នា ។

ពុទ្ធចក្រ ន. កង់ព្រះពុទ្ធសាសនាដែលដឹកនាំពុទ្ធសាសនិកជនទៅកាន់សេចក្តីបរិសុទ្ធ (ដូចជាកង់) ។

ពុទ្ធិកសមាគម ន. ការប្រជុំឬប្រមូលអ្នកដែលជ្រះថ្លាចំពោះព្រះពុទ្ធ–ឬអ្នកដែលជឿជាក់ក្នុងព្រះពុទ្ធសាសនា, ការរួបរួមអ្នកកាន់ពុទ្ធសាសនា ។

ពុទ្ធសាសនិក ន. អ្នកកាន់សាសនាព្រះពុទ្ធ ។

ពុទ្ធិព្រឹទ្ធ ន. ឬ គុ. សេចក្ដីចំរើនប្រាជ្ញា,–ចំរើនការយល់ ។

ពុទ្ធិចរិត ន. អ្នកដែលមានចរិតក្រាស់ដោយការយល់ ។

ព្យត្តភាព ន. ភាពជាអ្នកឈ្លាស, ដំណើរឈ្លាសវៃ ។

ព្យត្តវោហារ ន. មនុស្សមានសំដីឈ្លាសវៃ អ្នកឈ្លាសវៃខាងសំដី ។

ព្យតិហារ ន. ការឈ្លោះប្រកែកជជែកគ្នា ការវាយដំធាក់ច្រំ ។

ព្យាបាល ន. ការថែរក្សាបីបាច់ ។

ព្យូហសន្និបាត ន. ការផ្ជុំពល, ប្រជុំកងទ័ព ។

ព្យោការ ន. ជាងដែក ។

ព្របារណ្យ (ម.ថ. ព្រៈហាព៉ន់) ន. ព្រៃធំ, ព្រៃស្ដុក ។

ព្រហ្មទណ្ឌ (ម.ថ. –ទ័ន) អាជ្ញាជាន់ខ្ពស់ ។

ព្រហ្មទេយ្យ ន. ទានឬរង្វាន់ដ៏ប្រសើរ, រង្វាន់ដែលព្រះមហាក្សត្រិយ៍ទ្រង់ព្រះរាជទានដល់អ្នកណាមួយ (បុណ្យព្រហ្មទាន)

ព្រហ្មេស្វរ (ម.ថ.-មេស) ន. ព្រហ្មជាធំជាងអស់ពួកព្រហ្ម ។

ព្រាហ្មណ្យ (ម.ថ. ព្រហ្ម័ន) ន. លទ្ធិរបស់ព្រាហ្មណ៍ ។

ព្រឹត្តិការណ៍ ន. ហេតុឬដំណើរដែលប្រព្រឹត្តទៅតាមប្រក្រតី ។

ព្រឹត្តិការ ន. អ្នកតែងសេចក្ដីអធិប្បាយវេយ្យាករណ៍ ។

ព្រឹត្តិកម្ម ន. ការយកបំណេញច្រើនហួសពេក, ឬយកការប្រាក់ហួសប្រមាណ ។

ព្រឹទ្ធាចារ្យ ន. អាចារ្យដែលមានអាយុច្រើន, អាចារ្យចាស់ទុំ (សំដៅចាស់ស្រុក, ចាស់ទុំ) ។

ព្រឹទ្ធរោគ ន. រោគគោម (ចាស់) ។

ភក្សាហារ ន. អាហារចំណី, អាហារជាចំណី ។

ភគវតឬភគវន្ត គុ.ន. ដែលមានជោគ, អ្នកមានបុណ្យ, អ្នកប្រាជ្ញ ។

ភណ្ឌការរណ៍ ន. ដំណើរឈ្មោះប្រកែក ។

ភណ្ឌាគារ ន. ឃ្លាំងដាក់ទ្រព្យ ។

ភតិកម្ម ន. ការឈ្នួល ។

ភត្តវេតន៍ ន. បៀវត្សរ៍, បាយទឹងថ្លៃឈ្នួល ។

ភត្តការ ឬ ភត្តការី ន. អ្នកចំអិនកត្ត, អ្នកគ្រួ, ចុងភៅ,

ភត្តកាល ន. ពេលបាយ (ប្រ. និ. សំដៅពេលបាយព្រឹក)

ភត្តាភិហារ ន. អ្នកចាត់ចែងកត្ត អ្នកលើកកត្តបំរើភ្ញៀវ ។

ភយន្តរាយ ន. សេចក្តីអន្តរាយដែលគួរខ្លាច ។

ភស្មការ ន. អ្នកបោកគក់សំពត់, អ្នកស៊ីឈ្នួលបោកអ៊ុត ។

ភាតរភាព ភាពជាបងប្អូន, ការរាប់អានគ្នាដូចបងដូចប្អូន ។

ភាសាបរិវត្តកៈ ន. អ្នកប្រែភាសា, អ្នកបកភាសាពីមួយទៅមួយ ។

ភាសាបរិវត្តន៍ ន. ការប្រែភាសា, ការនិយាយ ឬសរសេរប្រែភាសាពីមួយទៅមួយ. ។

ភិក្ខាភាជន៍ ន. ចានបាយ, ចានដាក់ភោជនាហារ ។

ភិន្នបិតុក ន. បងប្អូនម្តាយជាមួយឪពុកទៃ ។

ភិន្នោទរ ន. បងប្អូនដែលកើតអំពីមាតាផ្សេងគ្នា តែបិតាជាមួយ ។

ភិយ្យោភាព ន. ភាពលើសលែង, ដំណើរច្រើនក្រៃលែង ។

ភុជិស្សភាព ន. ភាពជាអ្នកជា (មិននៅក្រោមអំណាចជនដទៃ) ។

ភុជិស្សជន ន. ជនអ្នកជា គឺអ្នកមិនជាប់បំណុលគេ ។

ភូតកាល ន. កាលដែលមានរួចទៅហើយ (អតីតកាល)

ភូតវេជ្ជ ន. ពេទ្យចាប់ខ្មោច, ឬដេញខ្មោចបិសាចៗ

ភូមិន្ទឬភូមេន្ទ្រ ន. អ្នកដែលជាធំជាងគេសប់ប្រជាជនលើផែនដីៗ

ភូធរេស្វរ៍, ភូមេស្វរ៍, ភូបេស្វរ៍, ប្រែថា ព្រះរាជាដូច

គ្នា ប្លែកគ្នាបន្តិចបន្តួចដោយសព្ទធំ-តូច ប៉ុណ្ណោះ(ព ក.)

ភូមិសាស្ត្រ ន. គម្ពីរសំដែងអំពីផែនដី, អំពីភូមិប្រទេស

ផ្សេងៗ ។

ភេរវារម្មណ៍ ន. អារម្មណ៍ដែលគួរខ្លាចឬគួរភ័ក ។

ភេរីបរណ៍ ន. ការគ្រាប់ទៅតាមផ្លូវ វាយស្គរធំដែកសំបុត្រ

ឬប្រកាសដំណឹងអ្វីមួយឲ្យដឹងទូទៅ ។

ភោគវ័តឬភោគវ័ន្ត ន. អ្នកមានទ្រព្យ ។

ភោជនីយ គុ. ដែលគួរបរិភោគ, សម្រាប់បរិភោគ ។

ភោជនីយដ្ឋាន,-ស្ថាន ន. កន្លែងសម្រាប់បរិភោគអាហារ ។

មករន្ទ (ម.ឋ.-រន់) ទឹកដមផ្កា, ទឹកឃ្មុំ, លំអងផ្កា ។

មគ្គទេសក៍ ឬមគ្គុទ្ទេសក៍ ន. អ្នកសំដែងផ្លូវ (គឺអ្នកនាំផ្លូវ)

មគ្គនកម្ម ន. ការជ្រើសរើស, ការរើសសំរាំង, ការស្វែងរក

មគ្គនាយក ន. អ្នកដឹកនាំ, អ្នកប្រាប់ផ្លូវល្អផ្លូវអាក្រក់ ។

មគ្គនាយកប្រទេស ន. អ្នកនាំប្រទេស (ឲ្យមានវឌ្ឍន-

ភាព) ។

មឃវ័ត-វ័ន្ត ន. ព្រះឥន្ទ ។

មច្ឆព័ន្ធ ន. អ្នកចាប់ត្រី, អ្នកដោតត្រី (លក់) ។

មធ្យមប្រតិប័ទ ន. សេចក្តីប្រតិបត្តិជាកណ្តាលមិនតឹង

ពេកមិនធូរពេក ។

មធ្យមដ្ឋាន ឬ មជ្ឈិមដ្ឋាន ន. ថ្នាក់កណ្តាល (ខេមរសិក្សា

គឺ មធ្យមដ្ឋាន ទី១-ទី២ ឬមជ្ឈិមដ្ឋានទី១-ទី២) ។

មណីការ (ម.ថ. មៈនីកា) ជាងច្នៃពេជ្រ,-ត្បូង,-ដាំខ្សែៗ

មណ្ឌនភណ្ឌ ន. គ្រឿងតាក់តែងខ្លួន, ប្រដាប់តែងខ្លួនៗ

មតកសាសន៍ ន. បណ្ដាំបុគ្គលដែលស្លាប់ (បណ្ដាំខ្មោច)

មនោម័យ (ម.ថ. មៃ) ដែលសម្រេចអំពីចិត្ត, ជាប់ចាន់

ចិត្ត (សេះមនោម័យ)

មនោរថ (ម.ថ.មៈនោរត់) បំណង,សេចក្ដីប្រាថ្នា ៗ

មនោរម,រម្យ គុ. ដែលជាទីត្រេកអរនៃចិត្ត, ដែលគួរឲ្យ

សប្បាយក្នុងចិត្ត, ៗ

មន្ត្រីកិត្តិយស ន. មន្ត្រីក្រៅតំណែងគឺមន្ត្រីដែលព្រះករុណា

ជាម្ចាស់ទ្រង់ប្រោសប្រទានងារឲ្យកើតឈ្មោះ(តែឥតប្រាក់ខែ)

មន្ត្រីសន្និបាត ន. ការប្រជុំពួកមន្ត្រីប្រឹក្សាកិច្ចរាជការ ៗ

មន្ត្រីសភា ន. ទីសម្រាប់ពួកមន្ត្រីប្រជុំគ្នាម្ដងៗ ដំនិតកិច្ចប្រឹក្សា

រាជការ ៗ

មន្ទីរ ន. គ្រឹហា, ផ្ទះ, កន្លែងចាត់ការ ។

មរណបណ្ណ ន. សំបុត្រប្រាប់សេចក្ដីឲ្យអ្នកដទៃសម្លាប់គេ ។

មហន្ធការ គុ. ដែលមានងងឹតខ្លាំង ។ ន. ងងឹតធំ, ងងឹតខ្លាំង

មហាត្មន៍ ន. អ្នកមានចិត្តជាបុណ្យ, ចិត្តប្រសើរ, ចិត្តឧបអរសាទរ ។

មហារាត្រ ន. វេលាអធ្រាត្រ ។

មហាវ័ន ន. ព្រៃធំ ។

មហាវិទ្យាល័យ ន. កន្លែងសម្រាប់រៀនវិជ្ជាជាន់ខ្ពស់, សាលារៀនចំណេះជាន់ខ្ពស់ ។

មហាសន្និបាត ន. ការប្រជុំគ្នាធំ, ការប្រជុំគ្នាច្រើន ។

មហាសមាគម ន. ការជួបជុំគ្នាច្រើន, ការប្រជុំគ្នាយ៉ាងធំ ។

មហៃស្វរ្យ ន. ឬគុ. អានុភាពធំ, កំឡាំងអង់អាច ។

មាតិកានុក្រម ន. បញ្ជីដែលស្រង់មាតិកាដាក់ដោយឡែកជា

របៀប ។

មាតុគ្រាម ន. អ្នកដែលមានលំអានដូចជាមាតា(ស្ត្រី) ។

មានទណ្ឌ (ម.ថ. មានៈទ័ន) ឈើវាស់, ខ្នាតវាស់(ម៉ែត្រ)

មានករ ន. អ្នកវាស់ (មានកម្ម ការដែលវាស់) ។

មានការណ៍ ន. ហេតុដែលត្រូវវាស់, ដំណើរដែលគួរវាស់

មារពន្ធន៍ ន. គ្រឿងសៅហ្មងចិត្តដែលទុកដូចជាបំណង ចងពួកសត្វ ។

មាលាវិកតិ ន. ផ្កាកម្រងដែលក្រងចំរុះរំលេចឲ្យល្អប្លែក ។

មាសានុប្បវត្តិ ន. ដំណើរដែលត្រូវប្រាប់រាល់ៗខែ, សំ-
បុត្របកខែ (ឬហៅថា មាសានុប្រព្រឹត្តក៏បាន) ។

មាសិកជិន ន. អ្នកស៊ីឈ្នួលខែ, អ្នកស៊ីប្រាក់ខែ ។

មហោសថ ន. ថ្នាំម្យ៉ាងកើតយ៉ាងពូកែ, (មហោសធ
ក៏បាន)

មិគពន្ធន៍ ន. គ្រឿងប្រដាប់ដាក់ឲ្យជាប់ម្រឹគ (អន្ទាក់ បង្កាត់ ខ្នារ ជាដើម) ។

មិច្ឆាជីព ន. ការចិញ្ចឹមជីវិតខុស ។

មិត្តភាព ន. ភាពនៃមិត្រ, គឺបែបបទសណ្ដាប់ធ្នាប់របស់មិត្រ ។

មូល្យភាព ន. ភាពដែលចំណេញ, ដំឡៃ, ឈ្នួល ។

មគ្គមុទ្ហបុរស ន. បុរសវង្វេងផ្លូវ ។

មោឃព្រឹទ្ធ ន. ចាស់ឥតអំពើ (ចាស់មិនបានការ) ។

មោនេយ្យភាព ន. ភាពអ្នកប្រាជ្ញ, បែបបទសណ្ដាប់ធ្នាប់អ្នកប្រាជ្ញ ។

មោហប្រព័ន្ធ (ម.ថ. មោហ ហ័ប ប្រព័ន្ធ) មិនស្គាល់ខុសមិនស្គាល់ត្រូវដែលចងខ្ទាក់ អ្នកដែលមោហៈចងខ្ទាក់ ។

មោហន្ធការ ន. សេចក្ដីងងឹតសូន្យឈឹងពុំយល់ខុសត្រូវៗ

យន្តកម្ម ន. ការយន្ត, ការធ្វើយន្ត, រៀនយន្តកម្ម ។

យន្តការី ន. អ្នកធ្វើយន្ត , អ្នកធ្វើការយន្ត , ពួកយន្ត-ការី ។ បើស្រីជា យន្តការិនី, យន្តការិកា ។

យន្តវិជ្ជា . យន្តវិទ្យា ន. បំណេះធ្វើយន្ត ។

យន្តសាលា ន.រោងយន្ត , រោងដាក់គ្រឿងយន្ត , រោងធ្វើគ្រឿងយន្ត ។

យន្តសិក្ខា, យន្តសិក្សា ន- ការរៀនធ្វើយន្ត , ការរៀនកែគ្រឿងយន្ត ។

យន្តសាស្ត្រ ន. ក្បួនប្រាប់វិធីធ្វើយន្ត ។

យានត្ត (ម. ថ. យ៉ា ន៉ាត់) ថ្នាំផង់សម្រាប់ស្រូប ឬ ផ្ញុំ ដោយបំពង់តូចឲ្យចូលតាមរន្ធច្រមុះឲ្យកណ្ដាស់ចូរមុខចូរមាត់ ឬកែរោគថ្លាសាយជាដើម (ថ្នាំយានត្ត)

យានបាត្រ ន. ទូកក្ដោងយ៉ាងធំ. កេត្រា. (កប៉ាល់)

គ័ត្តុ. ហៅ យានបាត្រ ក៏បាន ។

យាបនមត្ត (ម. ឋ.-ម៉ុត) គុ. ដែលល្មមចំអែតអាត្មាបាន ដែលត្រឹមតែមួយចំអែត អាហារជា យាបនមត្ត ។

យាមឃោស ន. សត្វស៊ើវតាមកំណត់យាម (មាន់ឈ្មោល) សូរស័ព្ទប្រាប់យាម, នាឡិកា ។

យាមិកៈ គុ. ន. ដែលត្រូវវេនចាំយាម, អ្នកយាម, អ្នកចាំយាម ។

យុត្តិធម៌ ន. សេចក្ដីត្រឹមត្រូវ, -ទៀងត្រង់, ដែលគួរតាមច្បាប់ ។

យុទ្ធភណ្ឌ ឬ យុទ្ធោបករណ៍ ន. គ្រឿងចំបាំង ប្រដាប់សម្រាប់សង្គ្រាម ។

យុទ្ធវិន័យ ន. ច្បាប់សម្រាប់ទូន្មានទាហាន ។

យុទ្ធវិនាស ន. ដំណើរបាក់ទ័ព ។

យុទ្ធសត្តភាព ន. ដំណើរស្ងប់សង្គ្រាម. លែងច្បាំងគ្នា ។

យុទ្ធសាស្ត្រ ន. ក្បួនចំបាំង, ក្បួនទ័ព, ក្បួនសម្រាប់អ្នកច្បាំង ។

យុទ្ធស្ម័គ្រ ន. ដំណើរក្តុំពលត្រៀមប្រុងចាំការ, ដំណើរស្ម័គ្រចិត្តនឹងច្បាំង ។

យុទ្ធាការ ន. អាការនៃចំបាំង ។

យុទ្ធាធិការ ន. មុខក្រសួងខាងចំបាំង,មុខការខាងសង្គ្រាម

យុវតី ន. ស្រីក្រមុំ ។

យុវ័ន ន. ប្រុសកំលោះ ។

យុវភាព ន. ភាពកំលោះ ឬ ក្រមុំ ។

យោក្ស័ត្រ ន. ឋានន្តរមន្ត្រីរដ្ឋបាល ជាអ្នកកាន់ការខាងបញ្ជីនឹងសំបុត្រផ្សេងៗ ។

យោគក្ស័យ ន. ដំណើរអស់ព្យាយាម, ដំណើរអស់

រលំ ។

យោគក្សេម ន. ដំណើរស្រាករលំ ។

យោគវិក្រ័យ ន. ការលក់ដូរដោយបំបាត់ ។

យោគ្យភាព ន. ការស្ទាត់ជំនាញ, ដំណើរអន់អាច. ការថ្មឹកប្រសប់, ការហាត់របស់ទាហានសេនា ។

យោធកម្ម ន. មុខការរបស់ទាហាន ។

យោធវិទ្យាគារ ន. សាលារៀនពួកទាហាន ។

យោធគ្រឿង ន. គ្រឿងសម្រាប់ទាហាន ។

យៅវ័ន ឬ យៅវ័ន្ន ន. វ័យក្មេង. វ័យក្រមុំកំលោះ ។

យោពូនម័ទ ឬ យៅវនម័ទ ន. សេចក្ដីស្រវឹងក្នុងចិត្តរបស់កំលោះក្រមុំ ។

យៅវ៌ គុ. ន. (ម.ថ.យៅ) កំលោះ,ក្រមុំ, ក្មេងនៅយៅវ៌ ។

យោវិភាគ ចំណែកនៃវ័យកំលោះឬក្រមុំ ។

យោនិភាព ន. ភាពកំលោះឬក្រមុំ ។

យោនិមាល្យ ន. កម្រងផ្កាក្រពុំ ។

យោនិយោគ គុ. ដែលប្រកបដោយវ័យក្មេង ។

វាចានុរក្ស ន. ការរក្សាសំដី, អ្នកប្រយ័ត្នមាត់ ។

វិនយានុរក្ស ន. អ្នកកាន់ច្បាប់, អ្នករក្សាច្បាប់ ។

រក្សាធិក្រឹត្យ ន, ចៅហ្វាយស្រុក ។

រក្សាភិបាល ន. មេឃុំ ។

រង្គាជីព ន. តួល្ខោន, អ្នករាំ, ឬអ្នកលាបថាំ; ជាងគូរគំនូរ

រង្គភូមិ ន. ទីលេងមហោស្រព ។

រង្គសាលា ន. រោងល្ខោន, រោងរាំ ។

រជក ន. អ្នកជ្រលក់សំពត់, ជាងលាបពណ៌ (បើស្ត្រីជារជ-

កីឬរជិកា) ។

រជតកម្ម ន. ការធ្វើប្រាក់, ការធ្វើជាងប្រាក់ ។

រជតការ ន. ជាងធ្វើគ្រឿងប្រាក់ ។

រជតភណ្ឌ ន. គ្រឿងប្រាក់ ។

រជនកម្ម ន. ការជ្រលក់, ការលាបថ្នាំរំលេចពណ៌ ។

រជនីជល ន. ទឹកសន្សើម ។

រជនិករ ឬ រជនីករ ន. ព្រះចន្ទ . . ។

រជនីចរ ន. ព្រាយហោះ . . ។

រជនីមុខ ន. ពេលប្រលប់, ក្បាលប្រលប់ ។

រជ្ជកាល ឬ រជ្ជសម័យ ន. កាលឬសម័យដែលក្សត្រិយ៍អង្គមួយៗទ្រង់សោយរាជ្យ ។

រជ្ជប្បវេណី ន. ទំនៀមទម្លាប់រាជ្យតៗមក ។

រជ្ជូបករណ៍ ន. ប្រាក់ពន្ធ, សួយអាករ, ប្រាក់សម្រាប់ទំនុកបំរុងផែនដី ។

រដ្ឋូបការ  ន. ការទំនុកបំរុងផែនដី ។

រដ្ឋការ រដ្ឋកម្ម រដ្ឋកិច្ច រដ្ឋក្រិត្យ  ន. ការឬកិច្ចសម្រាប់ផែនដីឬសម្រាប់ប្រទេស . . . កិច្ចការរបស់រដ្ឋ ។

រដ្ឋធម្មនុញ្ញឬរដ្ឋធម្មនូញ  ន. ច្បាប់បញ្ញត្តិ សម្រាប់ប្រទេសនីមួយៗ ។

រដ្ឋនាយក រដ្ឋាធិបតី រដ្ឋាភិបាល  ន. អ្នកគ្រប់គ្រងរក្សាប្រទេស, ( តំណាងក្សត្រិយ៍ទ្រង់រាជ្យ ) ព្រះរាជា ។

រដ្ឋបាល  ន. អ្នករក្សាប្រទេស ។

រដ្ឋបាលន៍  ន. ការរក្សាប្រទេស ។

រដ្ឋបុរស  ន. បុរសអ្នកមានចំណេះចេះរក្សាប្រទេស ។

រដ្ឋប្បវេណី ន. ប្រវេណីសម្រាប់ប្រទេស,ច្បាប់សម្រាប់រដ្ឋ

រដ្ឋប្រសាន្តិភាពឬរដ្ឋសន្តិភាព  ន. ការស្ងប់ដែលមានក្នុងដែន, សេចក្ដីសុខសាន្តរបស់ប្រជាជន ។

រដ្ឋប្រសាសន៍ ន. ការប្រិតប្រៀនប្រជាជនឲ្យប្រិតនៅក្នុងអំណាចច្បាប់ ។

រដ្ឋប្រសាសន៍នយ ឬ រដ្ឋប្រសាសនោបាយ ន. ការដឹកនាំ ឬ ឧបាយនាំឲ្យប្រជាជនបិតនៅក្នុងអំណាចច្បាប់, វិជ្ជា ឬ បែបបទជាគោលចារឹកសម្រាប់គ្រប់គ្រងរដ្ឋ ។

រដ្ឋមន្ត្រី ន. អ្នកប្រឹក្សាអំពីការរក្សាប្រទេស ។

រណកម្ម, រណការ, រណកិច្ច, រណក្រឹត្យ ន. ការច្បាំងគ្នា ឬ ការរវល់ដោយច្បាំងគ្នា, ការរវល់ក្នុងចំបាំង ។

រណក្សេត្រ, រណក្ខេត្ត, រណដ្ឋាន, រណភូមិ, រណរង្គ, រណស្ថាន ន. ទីតយុទ្ធគ្នា, ទីចំបាំង, សមរភូមិ ។

រណជ័យ ន. ការច្បាំងឈ្នះ ។

រណបរាជ័យ ន. ការចាញ់ទ័ព. ការច្បាំងចាញ់គេ ។

រណភណ្ឌ, រណង្គ, រណោបករណ៍ ន. ប្រដាប់សម្រាប់

ច្បាំង, គ្រឿងចំបាំង ។

រណមុខ ឬ រណមុខ្យ ន. ទ័ពស្រួច ។

រណមិត្ត ឬ -មិត្រ ន. សម្ពន្ធមិត្រអ្នកជួយច្បាំង ។

រណវិជ្ជា ឬ រណវិទ្យា ន. ចំណេះខាងចំបាំង ។

រណវិស័យ ន. ច្បាប់ចំបាំង ។

រណសាស្ត្រ ន. ក្បួនសម្រាប់សិក្សាខាងចំបាំង ។

រណសិក្សា ន. ការហាត់ច្បាំង .ការរៀនច្បាំង ។

រណស្តម្ភ ន. អនុស្សាវរីយ៍ជាទីនឹកដល់សម័យកើតសង្គ្រាម (គឺជារឹកអ្វីមួយឲ្យដឹងថា កាលណោះច្បាំងនឹងអ្នកនេះ...) ។

រណរិទ្ធិ ឬ រណឫទ្ធិ ន. អ្នកដែលមានរិទ្ធិក្នុងការច្បាំង ។

រណោបាយ ន. ឧបាយក្នុងសង្គ្រាម, ល្បិចព្យុហ៍សឹក ។

រណ្ណកព្រឹក្ស ន. ឈើដែលមិនសូវមានផ្លែ ។

រតនករណ្ឌ ន. ទូ ឬ ហឹបដាក់ត្បូង, - ពេជ្រ, - មាស ។

រតនពាណិជ ន. អ្នកលក់ត្បូង ។

រតនសុវណ្ណ ឬ រតនសុពណ៌ ន. មាសប្រដាប់ដោយត្បូង, មាសដាំពេជ្រ (ចិញ្ចៀន, ទំហូ) ។

រតនាវលី ន. ខ្សែកដាំពេជ្រ ។

រតិកម្ម, រតិក្រិយា ន. ការរួមបវេណី ។

រតិទូតី ន. មេអណ្តើក ។

រតិគ្រឹះ ន. ផ្ទះសម្រាប់កំសាន្តសប្បាយ ។

រត្តចន្ទន៍ ន. ចន្ទន៍ក្រហម ។

រត្តសុវណ្ណ ន. មាសក្រហម (មាសផ្សដី) ។

រត្តញ្ញូ ន. អ្នកដឹងរាត្រី គឺអ្នកដែលមានអាយុច្រើន(ចាស់)

រត្តិកាល ឬ រាត្រីកាល ន. ពេលយប់ ។

រត្តិបរ ឬ រាត្រីបរ គុ. ន. មនុស្ស ឬ សត្វដែលចរ
ក្នុងវេលាយប់ ( ចោរ , ក្រាយ , បិសាច , ទីទុយ . . . ) ។

រត្តិច្ឆេទ ន. ដំណើរដាច់រាត្រី ។

រត្តិន្ទិព ន. យប់នឹងថ្ងៃ , ១យប់ ១ថ្ងៃ ។

រត្តិភាគ ឬ រាត្រីភាគ ន. បំណែកនៃរាត្រី គឺពេល
យប់ទាំងមូល ។

រថការ ន. អ្នកធ្វើរថ , ជាងធ្វើរថ , ជាងរថ ។

រថកេតុ ន. ទង់សម្រាប់រថ , ទង់រថ ។

រថបញ្ជរ ន. រាងរថ, ផ្ទះរថ, តួរថ ។

រថបាទ ន. កង់រថ, ជើងរថ ។

រថភណ្ឌ ន. គ្រឿងរថ, ប្រដាប់រថ ។

រត្តិភាព ន. សេចក្តីសុខ, ដំណើរលេងសប្បាយ, ភាពនៃ
សេចក្តីសុខ ។

រន្ធកសត្វ ន. សត្វដែលនៅក្នុងរូង (ចង្រិត, ជាស···)

រមណីយ៍ គុ. ដែលគួររីករាយ,–គួរត្រេកអរ ។

រមណីយដ្ឋាន,–ស្ថាន ន. ទីសប្បាយ,កន្លែងដែលរីករាយ ។

រមណីយវ័ន ន. ព្រៃដែលសប្បាយ ។

រម្ភា ន. ស្រីអប្សរ, ស្រីពេស្យា ។

រម្យា ន. ដើមចម្ប៉ា, រាត្រី (យប់) ។

រវិចរណ៍ ឬ រវិយាត្រា ន. ដំណើរព្រះអាទិត្យ ។

រវិវណ្ណ គុ. ន. មានសម្បុរដូចជាព្រះអាទិត្យ ។

រវិន្ទ ន. ផ្កាឈូក ។

រវិហង្ស ន. សត្វប្រវឹក ។

រសកៈ ន. អ្នកចំអិនអាហារ,ចុងភៅ (បើស្ត្រីជារសិកា) ។

រសជាតិ ន. ជាតិរបស់រស (រសឆ្ងាញ់ពិសា) ។

រសវតី ន. រោងចំអិនអាហារ, (ផ្ទះបាយ) ។

រសវិទ, សាយនវិទ ន. អ្នកចេះរសវិទ្យា, អ្នកស្ងួបេទ,
ពេទ្យ ។

រសភង្គ ន. ដំណើរខូចរស, សេចក្តីអផ្សុក ។

រសិកាហារ ន. ឬគុ. អាហារឆ្ងាញ់ពិសា ។

រស្សកាល ន. កាលខ្លី, កាលពុំយូរ ។

រហទដ្ឋាន ន. អន្លង់ទឹកជ្រៅ, បឹងជ្រៅ ។

រហស្ថាន ន. ទីស្ងាត់, ទីដែលមិនមានមនុស្សនៅ ។

រហស្សកម្ម ន. អំពើកំបាំង, ការសម្ងាត់ ។

រហស្សការណ៍ ន. ហេតុឬដំណើរកំបាំង ។

រហស្សភាព ន. ភាពសម្ងាត់, ដំណើរសម្ងាត់ ។

រហស្សភេទ ន. គុ. ដំណើរបែកខ្លាយការសម្ងាត់ ។

រហស្សុបាយ ន. ឧបាយសម្ងាត់, ល្បិចសម្ងាត់ ។

រន្ធសហាន ឬ រន្ធស្ថាន ន. ដែលនាំឲ្យក្ដៅក្រហាយស្អុះស្អាប់បែកចាកទី, សេចក្ដីហួងង្គងមោះម៉ង ។

រាជកីឡា,-ក្រីឌា ន. ការក្រសាលសប្បាយផ្ទាល់ព្រះអង្គរបស់ព្រះរាជា ។

រាជកោដ្ឋាគារ ន. ឃ្លាំងព្រះរាជទ្រព្យ ។

រាជកោដ្ឋាគារិក ន. មន្ត្រីអ្នករក្សាឃ្លាំងព្រះរាជទ្រព្យ ។

រាជទូត ន. អ្នករាជការដែលចេញទៅនៅក្នុងប្រទេសដទៃជាដំណាងជាតិនិងប្រទេសរបស់ខ្លួន ។

រាជទូតក្រិយា ន. ក្រឹត្យឬច្បាប់មុខក្រសួងរបស់រាជទូត ។

រាជនីតិ ន. ច្បាប់ឬបែបបទសម្រាប់ព្រះរាជា ។

រាជបញ្ញា ន. ព្រះរាជឧង្ការត្រាស់បង្គាប់ ។

រាជបញ្ញត្តិ ន. បញ្ញត្តិរបស់ព្រះរាជា ។

រាជបណ្ឌិត្យ ន. ភាព–បែបបទមុខការរបស់រាជបណ្ឌិត

រាជបល្ល័ង្ក ន. បល្ល័ង្ករាជ្យ (បល្ល័ង្កក្រោមស្វេតច្ឆត្រ)

រាជប្បវត្តិ ន. ពង្សាវតារក្សត្រិយ៍, រឿងក្សត្រិយ៍ ។

រាជពលានុភាព ន. អានុភាពនៃរាជពល ។

រាជសទ្មន . រាជវេស្មន ន. ព្រះរាជវាំង ។

រាជូបករណ៍ ឬ រាជោបករណ៍ ន. គ្រឿងប្រើប្រាស់សម្រាប់ព្រះរាជា, គ្រឿងប្រើប្រាស់ជិតព្រះអង្គ ។

រាជនាវិក ន. អ្នកកាន់ការក្នុងព្រះរាជនាវា ។

រាជកកុធភណ្ឌ ន. គ្រឿងប្រដាប់សម្រាប់រាជ្យ ។

រាជតាទ្វិត គុ. ដែលជ្រលក់ទឹកប្រាក់, ដែលក្រឡៃប្រាក់

រាត្រីវិភាគ ន. ពេលព្រឹកព្រាង, ពេលបំព្រាង ។

រាត្រីសុវត្ថិ ឬ រាត្រីសួស្តី ន. សួស្តីក្នុងវេលាយប់ ។

រាធន៍ ន. សេចក្តីសម្រេច, សេចក្តីចំរើន ។

រិត្តភាព ន. ភាពទទេ, ដំណើរមិនកើតការ ។

រិស្ត ន. សេចក្ដីលាមក, ដំណើរអាក្រក់, គ្រោះកាច ។

រូបការ. រូបការក៍. រូបការី ន. អ្នកធ្វើរូប, ជាងគូរ ឬ ឆ្លាក់រូប ។

រូបជីវិនី. រូបាជីវា ន. ស្ត្រីអ្នកចិញ្ចឹមជីវិតដោយសាររូប (ស្ត្រីពេស្យា) ។

រូបផ័ន (ម. ថ. រូបៈ ផ័ន) ន. រូបព័ណ៌ ។

រូបភាព ន. រូបវិចិត្រដោយព័ណ៌, បែបរូបផ្សេង ៗ ។

រូបាជីព ន. ស្រីពេស្យា ។

រូបារម្មណ៍ ន. អារម្មណ៍មានរូបជាដើម ។

រូបិយម័យ ន. គុ. ដែលធ្វើដោយប្រាក់, ដែលយកសាច់ប្រាក់ធ្វើ ។

រេចកភេសជ្ជៈ ន. ថ្នាំបញ្ចុះឲ្យបាត់ទល់អាចម៍ ។

រេចនកម្ម ន. ការបញ្ចុះថ្នាំឲ្យបាត់ទល់អាចម៍ (ធ្វើរេចនកម្ម)

រោគនិទ្ធ ន. នាំទៅរោគ, សម្បូររោគ ។

រោគបាល ន. ការរក្សារោគ, ការរក្សាជម្ងឺ ។

រោគបាលកៈ ឬ រោគបាលក៍ ន. អ្នកថែជម្ងឺ (បើស្ត្រីជា រោគបាលិកា) ។

រោគសាន្ត ឬ រោគសាន្តភាព ន. ការរម្ងាប់រោគ, ដំណើរស្បើយរោគ ។

រោចនភាព ន. ភាពរុងរឿង ។

រោទនការណ៍ ន. ហេតុឬដំណើរដែលយំ ។

រោទនភាព ន. ភាពយំ, ដំណើរយំ ។

រោធនការណ៍ ន. ហេតុឬដំណើរដែលជាប់ឃុំ ។

រោធនដ្ឋាន,–ស្ថាន ន. ទីសម្រាប់ឃុំខាំង (គុក)

រោធនទណ្ឌ ន. អាជ្ញាឃុំខាំង (ខ្នោះច្រវ៉ាក់) ។

រោបនកិច្ច ន. ដំណើររវល់ដោយដាំដំណាំ ។

រោបនដ្ឋាន ឬ រោបណស្ថាន ន. ទីដាំដំណាំ, ចំការដាំដំណាំ

រោបនមូល ន. ប្រាក់ដែលបានអំពីដាំដំណាំ ។

រោសភាព ន. ភាពក្រោធ (ខឹង) ។

ឫក្សណភាព ន. ភាពឬដំណើរដែលមើល,- ឃើញ ។

ឫណគ្រស្ត គុ. ដែលជាប់បំណុលគេ (កូនបំណុល) ។

ឫតុសាត្ម្យ (ម.ថ. - សាត) អាហារដែលឆ្ងាញ់តាមរដូវ ។

ឫតុបរិណាមជាពាធ ន. ជម្ងឺដែលកើតព្រោះការប្រែប្តូររដូវ ។

ឫទ្ធិម័ត ន. អ្នកមានឫទ្ធិ,-ដែលមានឫទ្ធិ ។

ឫទ្ធិរង្គ ន. ចំបាំងយ៉ាងសម្បើម ។

ឫទ្ធិរុទ្រ គុ. ន. អ្នកមានឫទ្ធិខ្លាំងពូកែ, ដែលរឹងប៉ឹង ។

លក្ខិក: ន. សេចក្ដីកំណត់ដែលដាច់ស្រេចហើយ ។

លក្ខិកប្បញ្ញត្តិ ន. បញ្ញត្តិរបស់ច្បាប់លក្ខិក: ។

លក្ស្មីបុស្ប ន. ផ្ការបស់លក្ស្មី, (ត្បូងទទឹម) ។

លក្ស្មីវិត គុ. ដែលមានស្រីសួស្ដី,- មានបុណ្យ,-មាន

សម្បត្តិ ។

លង្ឃនកម្ម ន. ការហាត់លោត, -ហាត់ផ្លោះ ។

លិបិការកម្ម ន. មុខការរបស់ស្មៀន ។

លិបិការកិច្ច,-ក្រិត្យ ន. ការរវល់របស់ស្មៀន ។

លិបិការដ្ឋាន,-ស្ថាន ន. ទីធ្វើការរបស់ស្មៀន ។

លិម្បការី ន. ពួកលាបថ្នាំ, ជាងកំបោរ ។

លាយនកម្ម ន. ការប្រុតកាត់ ។

វិលុម្បកកម្ម ន. អំពើរបស់ចោរប្លន់ (ស្រ្ដីជាលុម្បិកា ប្ដ

វិលុម្បិកា ) ។

លូខប្បណីតភាព ន. (ម.ថ. លូខ័បបះណីតះ–) ភាព សៅហ្មង ឬភាពថោកទាបទីឧត្តម ។

លូខជីវិន,–ជីវី គុ. ដែលរស់នៅត្រដាបត្រដួស ( បើស្ត្រីជា លូខជីវិនី )

លូខព័ណ៌ ន. សម្បុរស្រអាប់ ។

លូខភាទិន,–ភាទី គុ. ដែលពោលពាក្យខ្ជិខ្ជា ( បើជាស្ត្រី លូខភាទិនី ) ។

លេខវិទូ ន. អ្នកចេះលេខវិជ្ជា, អ្នកពូកែខាងលេខនព្វន្ត

លេខបុណ្ណិកា ន. ដីស, ដក់សម្រាប់គូរ ។

លេខបត្រ, លេខ្យ–, ន. ក្រដាសសរសេរ, សៀវភៅសម្រាប់សរសេរ ។

លេខហារិន,–ហារី ន. អ្នករត់សំបុត្រ, បុរសប្រៃសណីយ៍

( បើស្ត្រី លេខហារិនី ) ។

លេខនី ន. ស្លាបប៉ាកកា ។

លេខនីករណ្ឌ ន. ប្រអប់ដាក់ស្លាបប៉ាកកា ។

លេខនីទណ្ឌ ន. ដងប៉ាកកា ។

លេខាធិការ ន. ស្មៀនធំរបស់អធិបតីក្រសួង, ចាងហ្វាងស្មៀន. ( បើស្ត្រី លេខាធិការិកា ) ។

លេខានុការ ន. ស្មៀនរងពីលេខាធិការមក (បើស្ត្រី លេខានុការិកា) ។

លោកនិស្សិត ន. មនុស្សសត្វឬអ្វីៗទាំងអស់ដែលនៅក្នុងលោក ។

លោកន្តគូ ន. អ្នកដល់នូវទីបំផុតលោក (ព្រះខីណាស្រព

លោកប្បវត្តិ–ប្រវត្តិ ន. ពង្សាវតារក្នុងលោក ។

លោកប្រសិទ្ធ គុ. ដែលប្រាកដ, ដាក់ច្បាស់ដល់ពួក

មនុស្សទូទៅ ។

លោកវិជ្ជា,-វិទ្យា ន. វិជ្ជាសម្រាប់លោកតាមសម័យនិយម

លោកវុឌ្ឍិ លោកវឌ្ឍន៍ ន. សេចក្ដីចំរើនរបស់លោក

លោកសន្តិភាព ន. ភាពស្ងប់ឬសេចក្ដីសុខរបស់លោក។

លោកសន្តិសុខ ន. ដំណើរសុខសាន្តរបស់លោក ។

លោកានុវត្តន៍ ឬលោកានុវត្តិ ន. ការយកតម្រាប់តាមគ្នា, គឺការអនុលោមតាមបែបបទរបស់មនុស្សផងគ្នា ។

លោកាយតនសាស្ត្រ ន. គម្ពីរសំដែងគតិលោកដែលមានសេចក្ដីយើករយោកមិនគួរជឿ ។

លោកាភិប្រាយ ន. សេចក្ដីអធិប្បាយអំពីលោកសណ្ឋាន។

លោកុត្តរាភិសម័យ ន. ការបានសម្រេចមគ្គផល ។

លោបកម្ម ន. ការដែលលុបលាង,-លើកចោល ។

លោបការណ៍ ន. ហេតុដំណើររឿងដែលលើកចោល។

លោហកម្ម ន. អ្នកធ្វើលោហៈ, មុខរបរលោហៈ, មាន ទង់ហ្វ៊ា, លង់ហិន, សំរិទ្ធ ជាដើម ។

លោហកាណ្ឌ ន. មេដែក ។

លោហការ ន. ជាងលោហៈ, ជាងដែក, (បើស្ត្រី លោហការិកា, -ការិនី) ។

លោហកុម្ភ ន. ឆ្នាំងដែក, ឆ្នាំងស្ពាន់ ... ជាដើម ។

លោហនាឡិ ន. នាឡិលោហៈ(ដោយដែក,-ស្ពាន់)

លោហាករ ន. អណ្តូងឬរណ្តៅរ៉ែលោហៈ ។

លោហិតចន្ទន៍ ន. ចន្ទន៍ក្រហម ។

លោហិតពណ៌ ន. សម្បុរក្រហម ។

លោហិតពស្ត្រ,-ពស្ត្រា ន. សម្ពត់ក្រហម ។

វគ្គព័ន្ធ ន. ការចងបាច់គ្នា, ប្រមូលគ្នាជាពួក ។

វគ្គភេទ ន. ការបែកពួក, ដំណើរផ្សេងពួកគ្នា ។

វិគ្គហិក ន.គុ. សំដីពិរោះ

វិគ្គាហ៊ី,-ហិនី ន.គុ. អ្នកដែលមានសំដីពិរោះ (បើស្រី ជា វិគ្គហិកា,-ហិនី)

វិង្គភាព ន. ភាពរោគ, សេចក្ដីវៀច ។

វិឃាសភោជី ន. អ្នកដែលត្រូវស៊ីទ្រព្យសម្បាច់របស់គ្រួសារ

វិបនករ, វិបនការ, វិបនការក៍, វិបនការី, ន. អ្នកស្ដាប់បង្គាប់, អ្នកធ្វើតាមពាក្យ (បើស្រី វិបនការិកា,-ការិនី)

វិបនរបនា ន. ពាក្យរៀបចំប្តូចក្រងពាក្យពេចន៍ឲ្យចុះ-របៀប,-ឲ្យត្រឹមត្រូវ ។

វិបនានុរូប ន. ការអនុលោមតាមពាក្យ ។

វិបីបរមមិត្ត,-មិត្រ ន. មិត្រល្អតែមាត់ ។

វិបីសង្ហារ ន. ការនាំពាក្យញុះញង់ ។

វិបីសង្ហី ន. អ្នកនាំពាក្យញុះញង់, (បើស្រី វិបីសង្ហិនី,)

វិបីសមាចារ ន. ការប្រើសំដីសុភាពរាបទាប ។

វឌ្ឍកីកម្ម ន. ការធ្វើរបស់ជាងឈើ ។

វឌ្ឍនធម៌ ន. សភាវដែលនាំឲ្យកើតសេចក្ដីចំរើន ។

វឌ្ឍនកម្ម ន. ការធ្វើដែលនាំឲ្យបានផលប្រយោជន៍ ។

វឌ្ឍនភាព ន. ភាពឬដំណើរនាំឲ្យចំរើន ។

វឌ្ឍនាការ ន. អាការនៃសេចក្ដីចំរើន ។

វណរោគ ន. រោគរបេង, ជម្ងឺរបេង, រោគដំបៅ ។

វណ្ណគតិ ន: ដំណើររបស់ពាក្យ, គឺការតែងសេចក្ដី ។

វណ្ណកុម្ភិកា ន. ដបទឹកខ្មៅ ។

វណ្ណតូលិកា ន. ស្លាបប៉ាកកា ។

វណ្ណតូលិកាទណ្ឌ ន. ដងប៉ាកកា ។

វណ្ណទូត ន. សំបុត្រ, ចុតហ្មាយ ។

វណ្ណលេខា ន. ដីស ។

វណ្ណសេដ្ឋ ឬ វណ៌ស្រេស្ឋ គុ. ដែលប្រសើរព្រោះពូជ
ពង្ស (បើស្ត្រី វណ្ណសេដ្ឋា, វណ៌ស្រេស្ឋា) ។

វត្តនិយម ន. ការកំណត់ធម្មតា, សេចក្ដីកំណត់តាមហេតុ;

វធ្យស្ថាន ន. ទីពិឃាតសត្វ, កន្លែងពិឃាតសត្វយក
សាច់លក់ ។

វនន្តរ ន. ចន្លោះ ឬ លន្លែកព្រៃ ។

វនបាល ឬ វនបាលក៍ ន. អ្នកកាន់កាប់ថែរក្សាព្រៃ
(បើស្ត្រី វនបាលី, វនបាលិកា) ។

វនបុស្ប ន. ផ្កាព្រៃ ។

វនប្បទេស ន. ព្រៃទាំងមូល ។

វនប្បវេស ន. ការចូលទៅកាន់ព្រៃ ។

វនកុសុម ន. ផ្កាព្រៃ, ផ្កាដុះក្នុងទឹក ។

វនរតិ ន. សេចក្ដីរីករាយក្នុងព្រៃ ។

វនសណ្ឌ ន. ដងព្រៃ ។

វនស្ថាន ឬ វនដ្ឋាន ន. ទីព្រៃ, តួព្រៃ ។

វនាល័យ ន. ជាយព្រៃ, ជួរព្រៃ ។

វន្ទនាការ ន. អាការអភិវាទន៍, អាការគំនាប់ ។

វន្ទន្ត (ម.ឋ. វ័ន) កិ. កំពុងថ្វាយបង្គំ,-សំពះ,-គំនាប់ ។

វប្បកម្ម, វប្បកិច្ច, វប្បក្រិត្យ ន. ការឬរបរសាបព្រោះ ។

វប្បការ,-ការី ន. អ្នកធ្វើការសាបព្រោះ ។

វប្បកាល,-សម័យ ន. កាលឬសម័យដែលត្រូវសាបព្រោះ ។

វប្បក្ខេត្ត, វប្បក្សេត្រ (ម.ឋ.-ខេត្រ,-ក្សេត្រ) ថ្នាល, ស្រែសាបព្រោះ ។

វិប្បនដ្ឋាន, វិប្រស្ថាន ន. ទីសម្រាប់សាបព្រោះ ។

វិប្បធម៌ ន. សភាវៈដែលសាបព្រោះ (បណ្តុះបណ្តាលឲ្យចំរើន)

វមរោគ ន. រោគក្អួត,–ចង្អោរ,

វយានុរូប កិ. វិ. តាមសមគួរដល់វ័យ, តែងខ្លួនតាមវយានុរូប ។

វយស្យ, វ័យស្យ គុ. មានអាយុ ៗ ន. អ្នកមានអាយុស្មើគ្នាឬស្រករគ្នា (គៀន, គ្នើ បើស្ត្រី វយស្យាឬវ័យស្យា)

វរយោសិត ន.គុ. ស្រីមានរូបល្អ, នាងឆើតឆាយ ៗ

វរ័ត្ថ ន. ក្រោះ, អាវក្រោះ, ៗ ជយវរ័ត្ថ អាវក្រោះមានជ័យ, អ្នកពាក់អាវក្រោះមានជ័យ (ស្ដេចឈ្នះសង្គ្រាម)

វល័យ ន. កងដៃ, កងជើង ។

វលាហក (ពលាហក: មេឃ, ពពក, ភ្លៀង, ទេវតា

អ្នកបណ្ដាលឲ្យក្រៀវ, ឲ្យកើតខ្យល់ ។

វល្លភភាព ន. ភាពដ៏ស្និទ្ធស្នាល, ការគាប់គួរ ។

វល្លភា ន. ប្រពន្ធអ្នកគាប់គួររកប្ដី, ភរិយា ។

វាក្យបរិវត្តន៍ ន. ការប្រែពាក្យ, គឺការប្រែពីភាសាមួយទៅមួយ ។

វាក្យារម្ភ (ម.ថ ក្យារ៉ុម) ការផ្ដើមពាក្យ ។

វាគុរា ន. សំណាញ់, មង, បន្ទង, បណ្ដាត់ជាដើម ។

វាគ្មិន គុ. ដែលប៉ិននិយាយ ។ ន. អ្នកមានសំដីថ្វីមាត់ ។

វាចាបេយ្យភាព ន. ភាពប្តូរដំណើរនៃសំដីពីរោះ ។

វាតគុល្ម ន. ខ្យល់កំបុតត្បូង ។

វាតណ្ឌ ន. កេតកោប ។

វាតបក្សី ន. សត្វត្រចៀកកាំ ។

វាតបាន ន. បង្អួច ។

វាតព័ស្ស ន. ខ្យល់និងភ្លៀង ។

វាតាពាធ ន. រោគខ្យល់តាប់ ។

វាតម្រឹគ ន. ឈ្លូស ។

វាទយុទ្ធ ន. ការជជែកយកឈ្នះ (តាំងសងខាង) ។

វាទកៈ ន. អ្នកប្រគំ, អ្នកលេងភ្លេង (បើស្រីជាវាទិកា) ។

វាទនកម្ម ន. ការប្រគំ, ការលេងភ្លេង ។

វាទ្យភណ្ឌ ន. គ្រឿងតន្ត្រីមួយវង់ ។

វាយទណ្ឌ-ភណ្ឌ ន. កី, (គ្រឿងតំបាញ) ។

វាយុធិល ន. ឥន្ទធនូ, ព្រឹល ។

វារិយន្ត្រ ន. ម៉ាស៊ីនទឹក, គ្រឿងបូមទឹក ។

វារិជាតិ ន. អ្វីៗដែលកើតក្នុងទឹក (សត្វទឹក)

វាលវេធី ន. អ្នកបាញ់ត្រង់ ។

វិកលចរិត ន. ឆ្កួត, ភ្លីភ្លើ ។

វិកល្ប ( ពិកល្ប ) ន. ការៈខ្វះខាត,ដំណើរពិការ(ដូចគ្នានឹង វិកលភាព) ។

វិក្កយាគារ ន. ផ្ទះលក់ទំនិញ, ផ្ទះផ្សារ, ហាង ។

វិក្កាយិកភណ្ឌ ន. អីវ៉ាន់សម្រាប់លក់ (ទំនិញ) ។

វិក្រយានុស័យ ន. ការឈប់ធ្វើជំនួញ ។

វិក្រាន្តយុទ្ធ, វិក្រាន្តសង្គ្រាម (ម.ថ.វិក្រានតៈ-) ន. ចំបាំងយ៉ាងខ្លាំង,- យ៉ាងសម្បើម ។

វិឃាតភាព ន. ដំណើរទើសទែង, ការទទឹងទាស់ (ការប៉ះទង្គិច)

វិឃ្នភាព ន. ដំណើរទើសទាក់, ដំណើរមានឧបសគ្គ

វិប្រភាព ន. សេចក្តីអន្តរាយ, ការខូចវិនាស ។

វិចន្ទ្រ គុ. ដែលឥតព្រះចន្ទ (ខែដាច់) ។

វិចយការណ៍ ន. ហេតុឬដំណើរដែលពិចារណាឃើញ ។

វិចារក ន. អ្នកពិនិត្យសេចក្ដីខុសត្រូវ (ចៅក្រម)

វិចារ ន. ការពិចារណា, ការត្រួតត្រា ។

វិបេស្ដន ន. ការសំដែងឫកឲ្យឃើញឫកខុសប្រក្រតី ។

វិប្បន្ដគ្រឹះ ន. ផ្ទះមានជាន់មានថ្នាក់ច្រើន ។

វិប្បាយព័ណ៌,-វិណ្ណ គុ.ន. សម្បុរស្រអាប់, សម្បុរស្វាំង ។

វិប្បាយភាព ន. ភាពស្វាំងឬស្វក់ ។

វិជនដ្ឋាន,-ស្ថាន ន. ទីស្ងាត់, រហោឋាន ។

វិទ្យាករ ន. អ្នកចេះ, អ្នកបង្កើតវិជ្ជា ។

វិទ្យាកាម ន. អ្នកប្រាថ្នាចំណេះ ។

វិទ្យាគុជ ន. ចំណេះថ្នាក់ជាន់ខ្ពស់បំផុត ។

វិជ្ជាកោដ្ឋ ន. មន្ទីរដាក់ក្បួនច្បាប់ ។

វិទ្យាល័យ, វិទ្យាស្ថាន ន. លំនៅ, កន្លែង, ពេនរៀន ។

វិទ្យាប័ណ ន. គុ. ដែលមានល្បីឈ្មោះខាងការចេះដឹង ។

វិទ្យាម័ទ ន. គុ. ដែលស្អេកស្អាងឆ្មើងឆ្មៃព្រោះអាងចំណេះ ។

វិទ្យាសាស្ត្រ ន. គម្ពីរប្រាប់វិជ្ជាផ្សេងៗ ។ វិជ្ជាពួកមួយដែលគេរកឃើញដោយអាការលៃផ្សំមានការផ្សំធាតុជាដើម ។

វិញ្ញត្តិ ន. ដំណើរថ្លែងការ, សេចក្តីពយការ ។

វិញ្ញាបន៍ ន. សំដីប្រាកដប្រជា, សំដីពន្យល់ ។

វិញ្ញុភាព ន. ការៈដឹងក្តី, (ដំណើរដឹងក្តីនៃកូនក្មេង)

វិទត្ថិប្បមាណ ន. ប្រមាណមួយចំអាម ។

វិត្ថារន័យ ន. ការនាំមកដោយពិស្តារ, ន័យពិស្តារ ។

វិទេសគមន៍ ន. ដំណើរទៅកាន់ប្រទេសដទៃ ។

វិទេសភណ្ឌ ន. របស់តាងប្រទេស, របស់មកពីប្រទេសដទៃ ។

វិទេសាគមន៍ ន. ដំណើរមកពីប្រទេសដទៃ ។

វិទេសុបាយ,វិទេសូបាយ ន. ឧបាយរបស់ប្រទេសដទៃ, ឧបាយសម្រាប់រក្សាប្រទេសកល់ខ្លួន ។

វិទ្យោតភាព គុ.ន. ភាពរុងរឿង,ភាពភ្លឺព្រោងព្រាត ។

វិធាន**ការ**ណ៍ ន. ហេតុឬដំណើរជាបែបផែន,ហេតុជារបៀបដំណើរចាត់ចែងការ ។

វិធិវ័ត,-វ័ត្ត គុ. ដែលមានបែប,ដែលចុះបែប ។

វិរុទ្ធ,ពិរុទ្ធ គុ. ដែលខុសបែប, ដែលមិនចុះរបៀប ។

វិនយប្បញ្ញត្តិ ន. បញ្ញត្តិដែលនាំទៅរកផ្លូវល្អ, ការបញ្ញត្តិច្បាប់ ។

វិនយានុគ្រោះ ន. ការលើកដំកើងវិន័យ ។

វិនាសនាការ ន. អាការដែលនាំបណ្ដាលឲ្យកើតវិនាសន៍

វិនាសនោបាយ ន. ឧបាយឲ្យកើតវិនាសន៍,ឧបាយបំផ្លាញៗ

វិនិច្ឆយដ្ឋាន,វិនិច្ឆយសភា ន. សាលាជំរះក្ដី, សាលា

ជំនុំក្ដី ។

វិបត្តិការណ៍ ន. ដំណើរឬហេតុឲ្យកើតសេចក្ដីប្រែប្រួល,
(ដំណើរប្រែប្រួល) ។

វិបរីតភាព ន. ភាពវិបរិត, ដំណើរប្រែប្រួល ។

វិបុលភាព ន. ភាពធំ, ភាពទូលាយ ។

វិបុលវាឌ្ឍ ន. ការបំពេញពងការផែនដី ។

វិប្បកិណ្ណភាព ន. ភាពៈពាយពាយ,-រយីករយោក ។

វិប្បដិសារភាពន. ដំណើរស្ដាយក្រោយព្រោះដឹងខ្លួនជាខុស

វិប្របគ្គការណ៍ ន. ហេតុកំបាំង, ការណ៍សម្ងាត់ ។

វិពុធសទ្មន ន. វិមានទេវតា ។

វិភូសាលង្ការ ន. គ្រឿងប្រដាប់សម្រាប់តែងខ្លួន ។

វិរោគភាព ន. ភាពឥតរោគ, សេចក្ដីសុខសប្បាយ ។

វិលោភនការណ៍ ន. ហេតុដែលបណ្ដាលឲ្យល្បួង,លលួង

វិវេកភាព ន. ភាពដែលស្ងាត់ ។

វិសភាគជន ន. ជនជាសត្រូវនឹងគ្នា, ជនខុសគេឯគ្នា ។

វិសាមញ្ញការណ៍ ន. ហេតុដែលប្លែកពីសព្វដង ។

វិសាលគ្រឹះ (ពិសាលគ្រឹះ) ន. ផ្ទះទូលាយ ។

វិសិដ្ឋភណ្ឌ (ពិសិដ្ឋភណ្ឌ) ទ្រព្យប្រសើរ, របស់ឧត្ដម

វិសិដ្ឋវិជ្ជា (ពិសិដ្ឋវិជ្ជា) ន. វិជ្ជាជាន់ខ្ពស់ ។

វិសោធន៍ (ពិសោធន៍) ន. ការសំអាត, ជំរះ, ការ-ល្បងមើល ។

វិស្សកម្ម ន. អ្នកធ្វើនូវកិច្ចការបានគ្រប់យ៉ាង ។

វិនាយក ន. អ្នកដឹកនាំគេឲ្យប្រព្រឹត្តល្អ, អ្នកប្រាប់ផ្លូវ-ខុសត្រូវ (បើស្ត្រីជា វិនាយិកា) ។

វិគ្គភាព ន. ដំណើរជួប, ប្រទះ, ពើបពះ ។

វិប្បតិការ ន. ការដេដែកតក៏, ការនិយាយតទល់ ។

វិប្រកតិ ន. ពាក្យត្មះតិះដៀល, ការបៀតបៀន ។

វិលោភន៍ ន. ការល្បួង, ដំណើរធ្វើឲ្យកើតសេចក្ដី-
សង្ស័យ ។

វិលេបន៍ ន. គ្រឿងលាប, គ្រឿងក្រអូប ។

វិឌ្ឍន៍ ន. សេចក្ដីចំរើន ។

វិវដ្ដ (ម. ថ. វិវ័ត) ការវិលត្រឡប់, ការត្រឡប់ធ្វើជា
ថ្មីទៀត ។

វិវរណៈ ន. ការបើក, បង្ហើប, ការប្រែពាក្យពីមួយ
ទៅមួយ ។

វិវិត្ត គុ. ស្ងាត់, ដែលគួរឲ្យកើតវិវេក ។

វិវិធ គុ. ដែលផ្សេង ៗ, ច្រើនបែប, ច្រើនយ៉ាង ។

វិវិធភាព ន. ភាពដែលផ្សេងគ្នា,–ដែលខុសគ្នា ។

## បកិណ្ណកវិបនាលង្ការ

ប្រសាសន៍ ន. ច្រើនប្រើពាក្យសំដីរបស់ឥស្សរជនក្រៅពីក្សត្រ (បើ រ.ស. ព្រះរាជសាសន៍. . .)

ផាតិកម្ម ន. ការធ្វើឲ្យចំរើន, ការបំពេញថែម, ការទ្វេឡើង ៗ

ពនាល័យ ន. លំនៅក្នុងព្រៃ, ការនៅក្នុងព្រៃ ។

ពិភទ្ធសញ្ញា ន. ពាក្យពិតឬដំណើរពិត ដែលនាំឲ្យកើតសេចក្ដីចំរើន ។ ពាក្យសម្រាប់ហៅពិធីច្រ៉ាងក្នុងកម្ពុជរដ្ឋ ។

ពិសោធ ក. សំអាត, ជំរះ, រំលីង, ល្បងមើល ។

ព្យសន៍ (ម.ថ. ព្យស់). ន. អំពើអាក្រក់, សេចក្ដីវិនាស ។

ព្យាក្រឹតិ ន. ការពន្យល់, បំភ្លឺសេចក្ដី, ការអធិប្បាយបញ្ជាក់សេចក្ដីឲ្យភ្លឺច្បាស់ ។

បច្ចន្តប្រទេស ន. ប្រទេសជាចុងនៃប្រទេសធំៗ ។

បរាភព ន. សេចក្តីវិនាស, សេចក្តីហិនហោច ។

មន្ត្រិត ន. អ្នកស៊ើបការសម្ងាត់, ចារបុរស ។

វេប័ស គុ. ទាប, ថោកថយ, កាច, កោង, អាក្រក់, ដូជាតិ, កំណាញ់ ។

វង្សករ, វង្សក្រឹត ន. បុព្វបុរសរបស់ត្រកូល, មនុស្សដើមត្រកូល ។

បូជនីយេសន៍ ន. អ្នកស្វែងទៅបូជា, អ្នកស្វែងទៅដល់កន្លែងសម្រាប់បូជា ។

ហោរហានេយ្យំ ន. ហោរកំណាចដែលត្រូវតែគេសម្លាប់ចោល (និយាយក្លាយជា ហនុយំ កំមាន)

ប្រឌិត កិ. តាំងឡើង, តាំងចាប់ផ្តើមធ្វើ ។

ប្រតិយក្ស ន. មនុស្សអ្នកដឹងកិច្ចការជាក់ (ក្ង.ព.ប្រ័ត្យក្ស)

ព្រហ្មាស្ត្រ (ម.ឋ. ព្រំមាស) ន. សស្ត្រាដ៏ប្រសើរ, ឈ្មោះសរដ៏វិសេសមួយយ៉ាង, សរព្រហ្មាស្ត្រ ។

ជីពបរ ន. ដំណើរនៃជីវិត ។

ជនាចារ ន. សណ្ដាប់ធ្នាប់, បែបបទ, របស់ពួកជនក្នុងប្រទេស ស្រុក ភូមិមួយ ៗ ។

ធនវន្ត ន. អ្នកមានទ្រព្យ, មានសម្បត្តិ ។

ទ្វន្ទយុទ្ធ ន. ការតយុទ្ធគ្នា, ប្រឡូកគ្នា តតួ ។

ធម្មនិយម ន. សេចក្ដីកំណត់តាមធម្មតា, អ្វី ៗ ដែលរមែងកើតមានតាមធម្មតា ។

បុព្វកិច្ច, បុព្វក្រិត្យ ន. ការរវល់រាយរង ដែលចាប់ផ្ដើមមុន ដើម្បីសម្រួលការធ្វើឲ្យចុះរបៀប ។

បូជនក្រិត្យ ន. ការរវល់ដោយថ្វាយឬដោយជូនកស្ដុការអ្វីៗ ។

បដិពន្ធន៍, បដិពន្ធ ន. សេចក្ដីស្រឡាញ់ជាប់ចិត្ត, ដំណើរជាប់ជំពាក់ ។

បដិភាណ ន. ដំណើរឆ្លៀវឆ្លាតដោយការដឹង ។

ប្រជាករ ន. ពួកជនបំណុះស្រុក ។

ប្រជារាស្ត្រ ន. ពួកជនបំណុះដែន ។

បុណ្យាភិសំគ្ការ ន. ធម៌ឬសភាវៈដែលបុណ្យតាក់តែងឲ្យកើតមានឡើង ។

ធម្មជីវិន ន. អ្នករស់នៅដោយធម៌, អ្នករស់នៅតាមធម៌ (អ្នកធ្វើខ្លួនទៅតាមធម៌ តាមច្បាប់ គឺយុត្តិធម៌)

ភោជនុប្បត្តិដ្ឋាន ន. កន្លែងដែលកើតឡើងនៃភោជន, កន្លែងសម្រាប់ធ្វើភោជនឲ្យកើតឡើង,... ។

កម្មករ ន. អ្នកធ្វើការ (ក្រុមការអ្នកធ្វើការតាមលំដាប់)។ ងារក្នុងតំណែងកងការ,... ។

គុណាករ ន. សេចក្ដីបរិសុទ្ធិគ្រប់យ៉ាង, បុគ្គលអ្នកបរិបូណ៌ដោយសេចក្ដីបរិសុទ្ធិ,... ។

ឆាយាធរ ន. កញ្ចក់ ។

ទិនានុប្បវត្តិ ន. ដំណឹងដែលមានរាល់ថ្ងៃ, សំបុត្រឲ្យដំណឹងតាមលំដាប់ថ្ងៃ (កាសែត) ។

បាឋកថា ន. សំដែងសេចក្ដីមាត់ទទេ, សំដីសំដែងរឿងរ៉ាវ ។

ប្រសាធនៈ, ប្រសាធន៍ ន. អលង្ការ, គ្រឿងប្រដាប់កាយ ។

មុខបាឋ ន. ការរៀនចាំមាត់, ពាក្យដែលទន្ទេញចាំមាត់

យថានុរូប កិ.វិ. តាមសមគួរ, តាមគួរដល់ការសមរម្យ ។

រាជវតិ ន. របងស្ដេច ។ ចំរៀកឬស្សីឬឈើវែងអបជារបងព័ទ្ធជុំវិញ ទីប្រជុំធ្វើបុណ្យធំ ។

រាជានុញ្ញាត ន. សេចក្ដីដែលព្រះរាជាទ្រង់យល់ព្រម ហើយ ។

រាជបរិត្តន៍ ន. ការផ្លាស់រាជ, ការផ្ទេររាជ ។

រាជបណ្ណាល័យ ន. កន្លែង, ទីដាក់ក្បួនច្បាប់ផ្សេងៗ ជាសម្បត្តិឬជាឃ្លាំងបំណេះរបស់ទូមជរដ្ឋ ។

រាជកិច្ច, រាជក្រិត្យ ន. កិច្ច ឬ ក្រិត្យរបស់ព្រះរាជា, កិច្ចការផែនដី ។

រាត្រីគម ន. ពេលព្រឹកព្រាង, វេលាបំព្រាង ។

លាវណ្យ ស៊ប្រៃ, លំអគួរឲ្យស្រឡាញ់ ។

លិង្គព្រិត្តិ ន. មនុស្សមានគំនិតគ្រឡប់គ្រឡិន ។

វិបនាលង្ការ ន. គ្រឿងប្រដាប់ពាក្យ, សំដីសម្រាប់ ប្រើតែមសើមឲ្យស្រួលស្ដាប់ ។

វិបិកប័ត្រ ន. សំបុត្រ, ចុតហ្មាយ ។

ភិទអាទ៍ ឬ ភិទ្យ–, កិ. ផ្ដើមនិយាយ ឬ តាំងនិយាយមុខគេ, យកមុខ, យកអំណាច ។

ប្រីតិ, ប្រីតិ៍ (ម.ថ. ប្រីតិ: ឬ ប្រីត) ន. សេចក្ដីត្រេកអរ, សេចក្ដីឆ្អែតចិត្តដោយអំណរដ៏វិសេស, ត្រឹត្រេប ។

កម្មនាការប្បត្ត កិ. ដល់ហើយនូវអាការដែលញាប់ញ័រ ។

ភោជនបាតិ ន. តាដន៍សម្រាប់ទ្រនូវភោជន (ថាស.. )

ហត្ថធោវ័ន ន. ការលាងដៃ ។

វាមហត្ថ ន. ដៃឆ្វេង ។

ទក្ខិណហត្ថ ន. ដៃស្ដាំ ។

បរិភណ្ឌ ន. ប្រសិទ្ធី, ប្រស់ព្រំ, (កិ. ធ្វើឲ្យព្រូកៃ...).

វិស្សុតនាម គុ. ដែលមានឈ្មោះ ឬ មានកេរ្ដិ៍ឈ្មោះល្បីល្បាញ ។

វិហង្គជិន ន. អ្នកជិះយន្តហោះ, ជនអ្នកជិះយន្តហោះ

វិហង្គយានដ្ឋាន ន. កន្លែងសម្រាប់យន្តហោះឡើងចុះ ឬសម្រាប់ចតយន្តហោះ ។

វិត្តដ្ឋាន ន. កន្លែងដែលបាននិយាយគ្នារួចមកហើយ ។

វិត្តានុក្រម ន. លំដាប់នៃពាក្យដែលបាននិយាយរួចមកហើយ ។

វេជ្ជសាស្ត្រ ន. ក្បួនប្រាប់វិធីរក្សាអាយុ, ក្បួនពេទ្យ ។

វេទនាក្សាន្តិ ន. ការអត់ទ្រាំទុក្ខវេទនា ។

បគុណភាព ន. ភាព ឬ ដំណើរស្ទាត់ជំនាញ ។

វិត្តន័យ ន. ន័យដែលពោលរួចមកហើយ ។

បដិច្ឆន្នាគារ ន. អាគារដែលបិទបាំង (មិនឲ្យឃើញ)

វិស្សាសបាត្រ (ម.ថ. វិៈ ស្សាសៈ បាត្រ) អ្នកដែលស្និទ្ធស្នាល អ្នកទុកចិត្ត ។

ការដ្ឋាន ន. កន្លែងធ្វើការ ។

កីឡាស្ថាន ន. កន្លែងលេងល្បែង, កន្លែងកីឡា ។

វេទិកា ន. ក្នាក់ដៃ, ប្រកាន់ដៃ, ក្ដារហ៊ឹង, ជើង-ម៉ាសម្រាប់អគ្គិយ, ថ្នាក់ខ្ពស់, គឺថ្នាក់ដែលលើកឲ្យខ្ពស់ជាងទីមាន (សម្រាប់ថ្លែងការណ៍ ឬ មើលអ្វី ៗ ឲ្យស្រឡះភ្នែក)

វិត្តិកម្ម ន. ការរបរសម្រាប់ចិញ្ចឹមជីវិត ។

វេធី ន. អ្នកបាញ់, អ្នកបោះ, ទំលុះ, ចាក់ ។

ប៉ារ៉ុប៉ែង ន. សំពត់សម្រាប់ដណ្ដប់, សំពត់សម្រាប់ឃ្លុំ..

ពាណិជ្ជសមាគម ន. ការរួមគំនិតគ្នាធ្វើជំនួញ (ក្រុមហ៊ុនធ្វើជំនួញ) ។

បាតរាស ន. ពេលបាយព្រឹក, (ឬបាតរាស៍ ក៏បាន) ។

កាឡុបក្ខ,-បក្ស, កាលបក្ខ, ន. ផ្នែកខាងងងឹត(ខែរនោច)

ទន្តសោធន៍ ន. ស្ពូនឬម្រាសសម្រាប់ដុសជំរះធ្មេញ ។

បាទវេស្ត ន. ស្រោមជើង ។

បច្ចុគ្គមន៍ ន. ការក្រោកទទួល ។

វិស្សុករ ន. អ្នកធ្វើការទូទៅ, អ្នកសម្រេចការហត្ថកម្ម (ជាងធ្វើផ្ទះ, សង់ស្ពាន . . . ជាដើម) ។

វបិឧស្ម័ន ន. រថដែលលឿនដោយកម្លាំងភ្លើងអគ្គិសនី, រថអៃ ។

បដិយត្ត, បដិយ័ត្ត គុ. ដែលចាត់ចែងហើយ, ដែលតាក់តែងហើយ, ដែលរៀបចំហើយ, (កិ. រៀបចំចាត់ចែង) ។

ឆាទកម្ម ន. ការប្រក់, ការបាំងឲ្យជិត ។

ឫទ្ធិម័ត គុ. ដែលមានឫទ្ធិ ។ អ្នកដែលមានឫទ្ធិ ។

លទ្ធផល ន. សេចក្ដីរុងរឿងដែលបានហើយ, សេចក្ដី

ចំរើនដែលបានហើយ, ផលដែលត្រូវបាន ។

លទ្ធិ ន. ការយល់ឃើញ, សេចក្ដីប្រកាន់ជឿ, ជំនឿ ។

វាជាយុត្តកៈ ន. សៀវភៅរបស់ព្រះរាជា ។

ទុក្ករកិច្ច, ទុក្ករក្រិត្យ ន. កិច្ចដ៏កម្រ, គឺកិច្ចដែលកម្រ អ្នកណាមួយធ្វើកើត ។

មន្ទីរសម្ភព ន. កន្លែង, ផ្ទះសម្រាប់ប្រសូត ដោយស្រួល ។

ទូរគមន៍ ន. ដំណើរទៅកាន់ទីឆ្ងាយ. ការធ្វើដំណើរ ទៅកាន់ប្រទេសឆ្ងាយឬទីឆ្ងាយ, ។

ទូរាគមន៍ ន. ដំណើរមកអំពីទីឆ្ងាយឬមកអំពីប្រទេសឆ្ងាយ ។

ធម្មសាស្ត្រ ន. ឈ្មោះគម្ពីរមួយដែលមានសេចក្ដីសំដែង អំពីយុត្តិធម៌ ។

វិស្សមកាល, វិស្សមោកាស ន. ឱកាស, កាល, ដែលឈប់សម្រាកមិនធ្វើការ, ឬមិនចូលសាលារៀន ។

វិស្សមដ្ឋាន. ន. ទីសម្រាប់ចត, ទីសម្រាប់សំណាក់ ។

វិហង្គបក្រ ន. គ្រឿងយន្តសម្រាប់ទៅតាមអាកាស ( អាកាសយាន )

វិហារកីឡា ន. ល្បែងកំសាន្តចិត្ត, ការលេងកំសាន្តអារម្មណ៍ ។

វិហារវ័ន ន. ព្រៃសម្រាប់កំសាន្តសប្បាយ, ឧទ្យាន ។

វិធីសង្ក្រាជិក ន. ថ្នល់បែកជាបីឬបួន, ផ្លូវត្រៃឡែងកែង ។

វីរបុរស ន. បុរសអង់អាច ។

វីរភ័ជិ ន. អាយាត្យអង់អាច, មេទ័ព ។

វីរិយភាព ន. ភាពនៃព្យាយាម ។

វីរិយារម្ភ ន. ការតាំងផ្តួងព្យាយាម ។

វឌ្ឍិការណ៍ ហេតុដែលនាំឲ្យមានសេចក្ដីចំរើន ។

វឌ្ឍិសម័យ ន. សម័យដែលមានសេចក្ដីចំរើន ។

វឌ្ឍិភាព ន. ភាពដែលនាំឲ្យមានសេចក្ដីចំរើន ។

វត្តការណ៍ ន. ហេតុដែលបាននិយាយរួចមកហើយ ។

វត្តិភាព ន. ភាពនៃការចិញ្ចឹមជីវិត, ការរស់នៅ ។

វេទនានុវត្តន៍ ន. ការប្រព្រឹត្តទៅតាមវេទនា ។

វេទនាប្រាប្ត ន. អ្នករងនូវសេចក្ដីលំបាក ។

វេធកម្ម ន. ការបាញ់តម្រង់, ការចោះទំលុះ ។

វេយ្យាករណ៍, វៃយាករណ៍ ន. ការធ្វើឲ្យជាក់ច្បាស់ ការពន្យល់ការប្រាកដ ។

វេរភាព ន. ភាពរបស់បុគ្គលជាសត្រូវនឹងគ្នា ។

វេវចនៈ ន. ពាក្យដែលប្រើផ្លាស់ប្ដូរគ្នា, ជំនួសគ្នាបាន ។

វេណិករណ៍ ន. អ្នកធ្វើនូវកណ្ដាប់, ការចងកណ្ដាប់ ។

វោហារវិជ្ជា,– វិទ្យា,– សាស្ត្រ ន. វិជ្ជាប្តក្យួនខាងច្បាប់សម្រាប់ប្រទេស, (ធម្មសាស្ត្រ) ។

សកភាសា ន. សំដីសម្រាប់ជាតិ, ភាសារបស់ជាតិរបស់ខ្លួន ។

សករណីយ៍ ន. អ្នកដែលមានកិច្ចការត្រូវធ្វើ.–កំពុងមានកិច្ចការ ។

សកុណណ្ឌ ន. ពងសត្វស្លាប, ស៊ុតបក្សី ។

ស័ក្តិសិទ្ធិ គុ. ដែលអាចឲ្យសម្រេចប្រយោជន៍បាន ។

សង្ករការណ៍ ន. ហេតុឬដំណើរដែលនាំឲ្យច្របូកច្របល់ ។

សង្ករភាព ន. ភាពច្រឡូកច្រឡំ,–ច្របូកច្របល់ ។

សង្កិណ្ណជាតិ ន. មនុស្សកាត់ជាតិ, មនុស្សដែលមានជាតិលាយ ។

សង្កិណ្ណបុត្រ ន. កូនកាត់, កូនលាយជាតិ ។

សង្កេតការណ៍ ន. ហេតុនៃការពិនិត្យ, ហេតុដែល
សង្កេតឲ្យឃើញច្បាស់ ។

សង្កោចនភាព ន. ភាពក្រញ៉ូវ, ដំណើរធ្វើមុខក្រញ៉ូវ ។

សង្កោចការណ៍ ន. ហេតុដែលបណ្ដាលឲ្យខឹង, ហេតុ
នៃកំហឹង ។

សង្ខិត្តន័យ ន. ន័យដែលបំព្រួញឲ្យខ្លី ។

សង្គមភាព ន. ភាពដែលរាប់រកគ្នា ។

សង្គម ន. ការជួបជុំគ្នា, ការប្រជុំ, ការរាប់រកគ្នា ។

សង្ឃាណត្តិ ន. សេចក្ដីបង្គាប់ឬពាក្យផ្ដាំផ្ញើរបស់សង្ឃ ។

សង្ឃារព័ន្ធ ន. ដំណើរគន្ទោលកើតស្លាប់ដែលទុកដូច
ជាចំណង ។

សច្ចាប័ន, សត្យាប័ន, ន. ការពោលពាក្យពិត, ការ
ធ្វើសញ្ញាពិតដល់គ្នានឹងគ្នា ។

សច្ចុបាន ន. ការផឹកទឹកសំបថដើម្បីឲ្យជឿចិត្តគ្នា ។

សប្បដ្ឋ, ស្វប្បដ្ឋ គុ. ដែលមានសេចក្ដីពេញចិត្តចំពោះអំពើរបស់ខ្លួន (ដែលជាអធិបតីលើខ្លួនឯង) ។

សញ្ញាប័ជ ន. បោរ, ផ្ទាំង, បន្ទះ, ដែលមានអក្សរកត់ចំណាំ ។

សញ្ញាបត្រ,-ប័ត្រ ន. ប្រដាប់កំណត់ហេតុ, សំគាល់ចំណេះវិជ្ជា ។

សតេកិច្ឆភាព ន. ភាពដែលគួរកែសម្រួលវិញបាន ។

សត្វវិទ្យា ន. វិជ្ជាពេទ្យសត្វ, វិជ្ជាសម្រាប់រក្សាសត្វ ។

សត្យវីត ន. ដែលមានពាក្យពិត ។

សទ្ទការីទ ន. អ្នកឈ្លាសក្នុងភាសា ។

សន្តុបាយ ន. ឧបាយឲ្យកើតសេចក្ដីស្ងប់ ។

សន្តិសុខ ន. សុខដែលកើតអំពីសេចក្ដីស្ងប់ ។

សន្តិភាព ន. ភាពសាន្តត្រាណ, ដំណើរសះជានឹងគ្នា ។

សន្តុដ្ឋិភាព ន. ភាពនៃសេចក្ដីសន្ដោស ។

សន្ទនា ន. ការនិយាយគ្នា, ការប្រឹក្សាគ្នា ។

សន្ទិដ្ឋិកហេតុ ន. ហេតុឬដំណើរដែលជាក់ប្រាកដ ។

សន្ទេហការណ៍ ន. ហេតុដែលនាំឲ្យមានសន្ទិះ សន្ស័យ

សន្ទេហការី ន. អ្នកដែលធ្វើឲ្យមានសន្ទិះសន្ស័យ ។

សន្ទេហភាព ន. ភាពឬដំណើរនៃសេចក្ដីសន្ស័យ ។

សន្ធានភាព ន. ដំណើរចងមេត្រីឬចងសមាគម ។

សន្ធិសញ្ញា ន. ការសន្យាតគ្នា, ការសន្យាជាមេត្រីនឹងគ្នា, សំបុត្រសន្យាគ្នាទៅវិញទៅមក (ប្រើជាសន្ធានសញ្ញា ក៏បាន) ។

សន្ធារណ៍ ន. ការចងចាំ, ការប្រព្រឹត្តត្រឹមត្រូវ, ការកាន់ឬប្រព្រឹត្តទៀងទាត់ ។

សន្ធិច្ឆេទកម្ម ន. អំពើកាត់ទីត ។

សន្និប្រកាស ន. ពេលថ្ងៃលិច, ពេលព្រលប់ ។

សន្និច្ច័យ ន. ការសន្សំទុក, ការសន្សំ ។

សន្និដ្ឋាន ន. សេចក្ដីចូលចិត្ត, ការរួមគំនិតជាមួយគ្នា ។

សន្និបាត ន. ការប្រជុំ, ការប្រមូលរួបរួមគ្នា, ការជួបជុំ ។

សន្និបាតសភា ន. កេនប្រជុំ, ពោលក្នុងទីប្រជុំ ។

សន្និព័ន្ធ ន. ការចងភ្ជាប់យ៉ាងមាំ,-ភ្ជាប់មេត្រីភាពនឹងគ្នា (ឬជាសន្និពន្ធ ក៏បាន) ។

សន្និសិទ ក. អង្គុយនៅស្ងៀម, អង្គុយស៊ប់ ។

សន្យាសភាព. ន. មរណភាពយ៉ាងឆាប់ភ្លាម ។

សបត្តជន ន. ជនជាសត្រូវ,-បច្ចាមិត្រ ។

សព្ទិន (ម.ថ. ស័បទិន) គុ. ដែលមានស្នូរ, ដែលលាន់ស្នូរចេញមក ។

សភាសទ៍ ន. អ្នកខ្នះខ្នែងកិច្ចការក្នុងទីប្រជុំ ឬ សមាគម

សភាសមាជិក ន. ក្រុមជំនុំ (ក្រៅពីសភានាយក, និង
សភានុនាយក)

សភាជន ន. សេចក្ដីសុភាពរាបទាប, សណ្ដាប់ធ្នាប់ល្អ ។

សភាជនភាព ន. ភាពនៃការសំដែងសេចក្ដីគួរសមចុះ
ថែបបទ ។

សភាគារម្មណ៍ ន. អារម្មណ៍ត្រូវគ្នា, មិនជាជំទាស់នឹងគ្នា ។

សភាព ន. ដំណើរកើតឯង, សេចក្ដីពិតតាមធម្មតា ។

សមភាព ន. ភាពស្មើគ្នា, ដំណើរស្មើមុខគ្នា ។

សមានុភាព ន. អំណាចស្មើគ្នា, អ្នកដែលមានអា-
នុភាពស្មើគ្នា ។

សមគ្គកម្ម ន. ការព្រមព្រៀងគ្នា ។

សមដ្ឋកាល ន. ពេលដែលត្រូវប្រជុំគ្នា ។

សមដ្ឋទិន ន. ថ្ងៃដែលត្រូវប្រជុំគ្នា, ថ្ងៃដែលមានលេង

មហោស្រព ។

សមញ្ញាប័ជិ ន. ស្លាក, យីហោ, ដែលទាក់ឬសរ-សេរឈ្មោះជាគ្រឿងចំណាំមុខការ, ។ (ហៅសញ្ញាណ-ប័ត្រ ក៏បាន) ។

សមណោគ្រូ ន. បញ្ជីប្រាប់ចំនួនប្រជាជនក្នុងស្រុក ឬប្រទេសនីមួយ ៗ ។ ម.ថ. សះម៉ោណាគ្រូ ។

សមត្ថកាល ន. វេលាដែលខ្លួនទៅប្រឹងបាន (វេលាកំពុងពេញកំឡាំង) ។

សមត្ថបុរស ន. បុរសអង់អាច, បុរសបានការ ។

សមត្ថភាព ន. ភាពនៃសេចក្ដីអាចហាន, សេចក្ដី-មោះមុត ។

សមន្តការ ន. ដំណើរផនឹតសូន្យឈើង (ប្រទេសមិនប្រើរកប្រជាតិទុកដូចជាផនឹត) ។

សមរប្រកាសន៍ ន. ការប្រកាសសង្គ្រាម ។

សមរភូមិ ន. ទីចំបាំង, ទីច្បាំងទ័ព ។

សមរភូមិជ័យ ន. ទីចំបាំងដែលមានជ័យ ។

សមរមុទ្ធា ន. ទ័ពស្រុប, កងទ័ពមុខ ។

សមាជិក ន. អ្នកដែលមានអំណាចត្រូវចូលកាន់ទីប្រជុំបាន, អ្នកចូលក្នុងសមាគម ។

សមានប្បដ្ឋ (ម.ជ.-ជ័ន) ន. បំណងស្មើគ្នា, អ្នកដែលមានបំណងស្មើគ្នា ។

សមារម្ភ ន. ការផ្គងព្យាយាម, ដំណើរប្រារព្ធកិច្ចការ ។

សមាស័ទ ន. ការអង្គុយជាមួយគ្នា, ការចូលទៅរក ។

សមិទ្ធក្រឹត្យ ន. ការរៀល់ដែលសម្រេចឬសម្រេចហើយ

សមិទ្ធផល ន. ផលដែលបានសម្រេចហើយ ។

សមិទ្ធការណ៍ ន. ហេតុនៃសេចក្ដីសម្រេច, ដំណើរ

ដែលបានសម្រេច ។

សមិទ្ធុបាយ ន. ឧបាយនៃសេចក្ដីសម្រេច ។

សមីន្ធន៍ (ម.ថ. សៈមិន) គ្រឿងដុត, ឧស ។

សមុទ្រសុប័ដ្ឋន៍ (ម.ថ. សុប៉ុត) កំពង់មាត់សមុទ្រ ។

សមោសរ ន. ទីប្រជុំ ។ កិ. ប្រជុំ, ជុំគ្នា, ជួបជុំ

សមោសរណដ្ឋាន ន. ទីសម្រាប់ប្រជុំ ។

សម្បរិវត្តន៍ ន. ការផ្លាស់ប្ដូរ, ការរុះរើពាក្យសំដី ។

សម្បសាទ (ម.ថ. ស័ម ប: សាទ) សេចក្ដីជ្រះថ្លាខ្លាំង សេចក្ដីជឿក្នុងចិត្តឥតរង្កៀស (ប្រើជាសម្បសាទន៍ ក៏បាន)

សម្បហារ ន. ការតយុទ្ធគ្នា, ការចូលប្រឡូក ។

សម្ពច្ឆរច្ឆិន្ន ន. (ម.ថ. ស័មព័ឆ ឆៈ រ៉ុប ឆិន) ន. វេលាដាច់ឆ្នាំ (គឺវេលាដាច់ឆ្នាំចាស់ចូលឆ្នាំថ្មី) ។

សម្ពង្ស ន. ការរួមវង្ស ឬ រួមត្រកូលគ្នា ។

សម្ពន្ធមិត្រ ន. មិត្រដែលចងសេចក្ដីពប់អានដោយបាន

ធ្វើញ្ញូ ឬ សន្យាគ្នាយ៉ាងមាំមួន ។

សម្ពន្ធវង្ស ន. វង្សដែលជាប់ទងគន្ធងជាញាតិនឹងគ្នា ។

សម្ពាធកោដ្ឋ ន. គោដ្ឋ, ជង្រុក, បន្ទប់ចង្អៀត ។

សម្ពាធគ្រឹះ ន. ផ្ទះចង្អៀត ។

សម្ពាធបថ,–មគ្គ,–មាគ៌ា ន. ផ្លូវចង្អៀត ។

សម្ពាធប្រាប្ដ គុ. ដែលដល់នូវសេចក្ដីចង្អៀតចិត្ត, អ្នក

ដែលតប់ប្រមល់ចិត្ត ។

សម្ពាធវជ្ជា ន. ប្រកបប្រហាប់ចង្អៀត ។

សម្ពត្តមិត្រ (ម.ថ. ស័ម.ភ័តត: មិត្ត) មិត្រជិតជិតទុក

ចិត្តស្និទ្ធស្នាលយ៉ាងមាំ ។

សម្ពាពន៍ ន. សេចក្ដីសរសើរ, ការស្ញើចសរសើរ (ខ្មែរ

ប្រើជាគុណក៏មាន ពាក្យសម្ពាពន៍ សរសើរ ។

សម្ភារៈ ន. សេចក្តីទំនុកបំរុង, ការស្រោបស្រង់, សេចក្តីសង្គ្រោះ, ការប្រមូល ។

សម្ភាសបត្រ,បណ្ណ ន. សំបុត្រតបទៅវិញទៅមក-ដោយសេចក្តីពប់អាន ។

សម្ភិន្ន គ.គុ. ដែលបែកគ្នា, ធ្លាយហើយ ។

សម្ភោជ ន. ការបរិភោគអាហារជាមួយគ្នា, ការលៀងភ្ញៀវ ខ្មែរប្រើជា គ. (លៀងភ្ញៀវ) បំពោះការលៀងភ្ញៀវក្នុងវេលាប្រជុំគ្នាផ្សងទៀនមង្គលជាដើម ជួនណាហៅថា សម្ភោជ្យ បើមានសេចក្តីថ្លែងការណ៍រៀបរាប់អំពីដំណើររឿង-នោះផង ច្រើនហៅថា សម្ពោធ ឬ សម្ពោធន៍

សម្មជ្ជនកម្ម ន. ការបោសសំអាត ។

សម្មជ្ជនកិច្ច ន. ការរវល់បោសសំអាត ។

សម្មជ្ជនភេរី ន. វេនបោសសំអាត ។

សម្មុទ្យន៍ ន. ការទោស, ការទោសសំរាក ។

សម្មតិវោហារ ន. ពាក្យដែលផ្សំប្រើ,-សន្មតប្រើ ។

សម្មាចារ ន. ការកាន់ត្រូវ, មានមារយាទល្អ ។

សម្មាជីព ន. ការរស់នៅដោយត្រឹមត្រូវ.– ដោយប្រពៃ, (គឺមិនបោកប្រវ័ញ្ចជនដទៃហើយរស់នៅ)

សម្មានភាព ន. ដំណើររាប់អានគ្នា ។

សម្មានចិត្ត ន. ចិត្តរាប់អានគ្នា, (មានចិត្តស្រឡាញ់គ្នា

សម្មោទន៍ គុ. ដែលរាក់ទាក់, ដែលនាំឲ្យមានសេចក្តីរីករាយ ។

សម្មោទនកថា ន. សំដីដែលនាំឲ្យមានសេចក្តីរីករាយ ។ ឲ្យមានអំណរ, សំដីរាក់ទាក់ ។

សម្រាជ ន. (ម.ថ. សំ រ៉ាច) អធិរាជ, មហារាជ ។

សយនដ្ឋាន ន. កន្លែងសម្រាប់ដេក ។

សយនកាល ន. ពេលដេក ។

សយ្យាសន៍, សេយ្យាសន៍ ន. ទីដេកនិងទីអង្គុយ ។

(ដូច សេយ្យាសន៍ សំដៅយកសេចក្ដីថា "ដេក" ជាកិរិយា)

សរណក្ខ័យ, សរណក្ស័យ ន. ដំណើរអស់ទីពឹង ។

សរណភេទ ន. ដំណើរដាច់ទីពឹង ។

សរីរកិច្ច ន. ការរវល់ដោយរាងកាយ (មានបន្ទោឧច្ចារៈ បស្សាវៈជាដើម) ។

សរីរនិក្ខេប ន. ការបញ្ចុះសព ។

សរីរប្បដិពទ្ធ, សរីរប្រតិពទ្ធ (ម.ថ. រុំ រុំប បង់ ព័ត -) ដែលជាប់ទាក់ទងដោយសរីរៈ (ស្រមោល)

សរីរបរិហារ ន. ការថែរក្សាខ្លួន ។

សរីរមោក្ខ ឬ -វិមោក្សណ៍ កិ. ស្លាប់ ។ ន. មរណភាព ។

សរីរសំស្ការ ន. ការរំលាយរូប, (ឈាបនកិច្ច)

សរីរថ ន. រថដាក់សព ។

សវាការ ន. អាការដែលស្លាប់, អាការនៃការស្លាប់ ។

សវីយ៍ គុ. ដែលគួរស្លាប់, ដែលត្រូវស្លាប់ ។

សស្ត្រការ (ម.ថ. ស័សស្ត្រៈកា) ន. អ្នកធ្វើគ្រឿង-សស្ត្រាវុធ, ជាងធ្វើសស្ត្រា (មានកាំបិត, ផ្គាក់..ជាដើម ។

សស្ត្រគ្រឹះ ឬ សស្ត្រាគារ ន. ឃ្លាំងអាវុធ, អាយុធាគារ

សស្ត្រជីវិន ន. ទាហាន យោធា (អ្នកចិញ្ចឹមជីវិតដោយមុខការកាន់គ្រឿងអាវុធ ។

សហកម្ម សហករណ៍ ន. ការងារដែលរួមគ្នាធ្វើ, ដំណើររួមគំនិតគ្នាធ្វើការ ។

សហកីឡា ន. ការលេងជាមួយគ្នា ។

សហគមន៍ ន. ការទៅជាមួយគ្នា (សហគមនាគមន៍

ការទៅមកជាមួយគ្នា ) ។

សហជីវិន ន. អ្នកដែលមានអាយុស្រករគ្នា ( អ្នកដែលរស់នៅជាមួយគ្នា )

សហបាលន៍ ន. ការរួមគ្នារក្សា, ការគ្រប់គ្រងរួមគ្នា

សហពន្ធ ឬ–ពន្ធន៍ (ម.ថ-ពាន់) ការចងភ្ជាប់ជាមួយគ្នា ។

សហភាព ន. ភាពជាមួយគ្នា ឬត្រូវគ្នា ។

សហោទរ ន. បងប្អូនរួមមាតាមួយ ។

សហស្សន័យន៍ ន. អ្នកមានភ្នែកមួយពាន់ ( ព្រះឥន្ទ្រ )

សហិត្រ ( ម.ថ. សៈហិត ) សេចក្ដីប្រឹងប្រែង ។

សហាបិ គុ. ដែលមានសេចក្ដីត្រូវការជាមួយ, ដែលសន្ទាត, ព៌តអាចឲ្យ...

សាកភ័ក្ត,–ភ័ក្ស ន. អ្នកដែលបរិភោគតែបន្លែ (តមសាច់)

សាធារណ៍ គុ. ដែលទូទៅ, ដែលមិនចំពោះមួយ ។

សាធារណការ ន. ការដែលត្រូវធ្វើទូទៅមិនចេះអស់មិនចេះហើយ, ក្រសួងសាធារណការ ។

សាធុក្រឹត្យ ន. កិច្ចត្រឹមត្រូវ ។

សាធុក្រឹត គុ. ដែលបានធ្វើឬផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ។

សាធុព្រឹត្តិ ន. ការប្រព្រឹត្តត្រឹមត្រូវ, មារយាទល្អ ។

សាបករ ន. អ្នកស្បថ ។ សាបកម្ម ការស្បថ ។

សាបតេយ្យ (ម.ថ.–បៈតៃ) ន. សម្បត្តិទ្រព្យ (ប្រ. កុ. សាបតៃយ ក៏មាន)

សាមគ្គីភាព ន. ភាពនៃសេចក្ដីព្រមព្រៀងគ្នា, ដំណើរស្រុះគ្នា ។

សាមញ្ញ គុ. ដែលជាធម្មតា, ដែលស្មើៗតែគ្នា (ពាក្យសាមញ្ញ ពាក្យផ្សារ, មនុស្សសាមញ្ញ មនុស្សធម្មតា)

សាមន្តប្រទេស ន. ប្រទេសជិតខាង ។

សាមន្តរាជ ន. ស្តេចចំណុះគេ ។

សាមាយិក គុ. ដែលកើតឬមានតាមសម័យ ។

សាមីភក្តិ ន. សេចក្តីស្រឡាញ់ស្មោះត្រង់ចំពោះម្ចាស់ ។

សាអីចិសាស័ទ ន. ពាក្យប្រៀនប្រដៅដែលគួរគោរព ។

សាមីចិកម្ម ន. កិច្ចការត្រឹមត្រូវ, ការគប្បី ។

សាយ័ណ្ហ ន. វេលារសៀល, ពេលល្ងាច ។

សាយប្រាតរ៍ (ម.ថ. សាយប្រាត) វេលាល្ងាច និង វេលាព្រឹក ។

សារកតិកា ន. សេចក្តីប្តេជ្ញាមានទុកក់ថាន ។

សារបណ្ណ ឬ សារប័ត្រ (ម.ថ. សារៈប័ន,-បាប់) សន្លឹកប្រាប់បញ្ជីរឿង,–បញ្ជីមាតិកា ។

សារប្បវត្តិ ន. ដំណើរពិត ។

សារភាព ន. ភាពពិត, ដំណើរឬសេចក្តីពិត ។

សារម្ភ (ម.ថ. សារ៉ុម) ប្រណាំងប្រជែងដណ្ដើមយកឈ្នះ (សារម្ភកថា ពាក្យក្រកួតប្រណាំ ...) ។

សារវ៉ិក្រ (ម.ថ. សារៈវ៉ាត់) ន. អ្នកត្រួតត្រាកិច្ចការទូទៅ, អ្នកមើលការ, អ្នកដែលត្រួតត្រាក្បួនទៅហធំ ។

សារាណីយ (ម.ថ.–ណី) គុ. ដែលជាហេតុនាំឲ្យរឭក

សាលក្រម ន. សំបុត្រសម្រេចសេចក្ដីដែលចៅក្រមប្រគល់ឲ្យគូក្ដីអ្នកឈ្នះកាន់កេក្រទុកសំគាល់, (ព.ជ. សានក្រម)។

សាសនទូត ន. អ្នកនាំសំបុត្រ, អ្នកនាំពាក្យបណ្ដាំ ។

សាសនបត្រ ន. សំបុត្របញ្ជាក់ការយ៉ាងជាប់ខាត ។

សាសនវិទ ន. អ្នកប្រាជ្ញខាងការប្រកាសសាសនា ។

សាសនូបត្ថម្ភ ន. ការទំនុកបំរុងសាសនា ។

សាសនោបាយ ន. ឧបាយខាងសាសនា ។

សាសនោវាទ ន. ដម្បូន្មានក្នុងសាសនា ។

សាសនិក ន. អ្នកកាន់សាសនា ។

សាសនប្បវត្តិ, -ប្រវត្តិ ន. ដំណើរសាសនា, ពង្សាវ-
តារសាសនា ។

សាស្ត្រក្រឹត ន. អ្នកតែងគម្ពីរ, អ្នកតែងច្បាប់ ។

សាស្ត្រន័យន៍ (ម.ជ. សាស្ត្រៈ នៃ) ផ្នែករបស់ក្បួន,
វេយ្យាករណ៍ ។

សាស្ត្រាចារ្យ ន. គ្រូបង្រៀនសាស្ត្រ, គ្រូបង្រៀន-
ច្បាប់ក្បួន ។

សិក្សាធិការ ន. ការគ្រប់គ្រងឬត្រួតត្រាលើការសិក្សា ។

សិតការណ៍ ន. ហេតុនៃការញញឹម, ដំណើរញញឹម ។

សិឋិលាភិភាទន៍ ន. ការថ្វាយបង្គំ, សំពះ, គំនាប់-
យ៉ាងតោះតើយ ។

សិឋិលានុសាសន៍ ន. ការប្រៀនប្រដៅ ឬ ស្ដីប្រដៅ

យ៉ាងគួរ ៗ ស្រួល ៗ

សិទ្ធកម្ម ន. អំពើឬការដែលសម្រេចហើយ ។

សិទ្ធកាម ន. អ្នកដែលមានបំណងសម្រេចហើយ ។

សិទ្ធការ្យ ន. អ្នកដែលមានការងារសម្រេចហើយ ។

សិទ្ធាចារ្យ ន. គ្រូអ្នកមានបំណេះយ៉ាងពូកែ, យ៉ាងជំនាញ។

សិទ្ធានុញ្ញាត ន. អនុញ្ញាតដែលសម្រេចតាមច្បាប់បញ្ញត្ត។

សិទ្ធិពល ន. កម្លាំងនៃសេចក្ដីអង់អាច ។

សិនេហប្បដិពទ្ធ គុ. ដែលជាប់ជំពាក់ដោយស្នេហា ។

សិនេហវន្ត ន. អ្នកដែលមានសេចក្ដីស្នេហា ។

សិន្ធុសង្គម ន. ទនេប្រសព្វមុខគ្នា, មាត់ពាម ។

សិប្បកម្ម ន. ការជាង, អ្នកធ្វើសិប្បៈ ។

សិប្បការី ន. ជាង, អ្នកធ្វើជាង ។

សិប្បជីវិន ន. អ្នកចិញ្ចឹមជីវិតដោយសិប្បកម្ម ។

សិប្បិយការ (ម.ថ. សិប បិុយៈកា) ការច្នៃបង្កើតសិប្បៈ ការច្នៃបង្កើតជាផ្សេង ៗ ។

សិព្វកម្ម ឬសិព្វនកម្ម ន. ការដេរ ។

សិព្វនការី, សិព្វនការកៈ ន. ជាងដេរ, អ្នកដេរ ។

សិម្ពលីវ័ន ន. ព្រៃរកា ។

សិរប័ដ, សិរវេឋន៍ ន. ឈ្នួតក្បាល ។

សិរបីឡ (ម.ថ. សិរៈបីឡា) ដំណើរឈឺក្បាល ។

សិរសាប្រណិប័ត,–ប្រណិប័តន៍ ន. ការឱនក្បាលសំពះ, ការផ្ទក់ក្បាលគំនាប់ ។

សិរីសោភ័ណ គុ. លំអនៃសិរី ។

សិរីវុឌ្ឍិ ន. សេចក្ដីចំរើនដោយបុណ្យច្រើន, អំណាច ។

សិលង្គារ ត្បូងថ្ម ។

សិលាចារឹក ន. អក្សរថ្ម, អក្សរជាប់នឹងថ្ម ។

សិលាបុណ្ណ (ម.ថ-បុន) ផង់ថ្ម, (ស៊ីម៉ង់ត៍)

សិលាផលតេល (ម.ថ-ផះតែល) ប្រេងដែលចេញពីថ្ម, ប្រេងសាំង ប្រេងកាត..។

សិលាបដ្ដ-ប័ដ, បន្ទះថ្ម, ផែនថ្ម ។

សិលាព័ណ៌ ន. សម្បុរថ្ម ។

សិលាព័ឞ្ស ន. ភ្លៀងធ្លាក់ដុំថ្ម ។

សិលាវេស្មន ន. ផ្ទះថ្ម, កំពែងថ្ម ។

សិលាសារ ន. ដែក ។

សិលាស្ដម្ភ ន. សសរថ្ម

សិល្បិន (ម.ថ- សិលប្បៈរិន) អ្នកចេះសិល្បៈ ។

សិល្បគ្រឹះ, សិល្បាគារ ន. រោងជាង, រោងរៀនសិល្ប៍

សិល្បសាស្ត្រ ន. ក្បួនរៀនសិល្ប៍, បំណោះជាង ។

សិល្បសិក្សា ន. ការរៀនធ្វើជាង ។

សិវាល័យ ទ. កន្លែងត្រជាក់ត្រជុំ ។ ឋានត្រជាក់ត្រជុំ។

សីលធម៌ ន. ភាវៈមានមារយាទត្រឹមត្រូវ,–នៃការ-

សង្រួម ។

សីលព្វត (ម.ថ. សី ល័ប ពាត់) ទម្លាប់នឹងវត្តប្រតិបត្តិខុស

របៀប, ខុសទំនង ។

សីសវេឋន៍ ន. ឈ្នួតក្បាល ។

សីសត្រាណ ន. ដួន, មួក... ។

សុក្កបក្ស-បក្ខ, ផ្នែកខាងភ្លឺ (ខ្នើត)

សុខការណ៍ ន. ហេតុដែលនាំឲ្យបានសុខ,–នាំឲ្យបាន

ស្រួល ។

សុខប្បត្ត (ម.ថ. –ប្បាប់) អ្នកដែលបានប្រទះនឹង-

សេចក្ដីសុខ ។

សុខព័ន្ធ (ម.ថ.–ពាន់) ការជាប់ជំពាក់ដោយសេចក្ដី.

សុខ ៗ

សុខភាព ន. ភាពជាសុខ, សេចក្ដីប្រកបដោយអនាម័យ ៗ

សុខវឌ្ឍក៍ (ម.ជ.-វ័ត) ន. អ្នកដែលចំរើនដោយសុខៗ

សុខវឌ្ឍន៍ ន. ការចំរើនដោយសុខ ៗ

សុខសម្ភាស ន. អ្នកនិយាយសំដីផ្អែមស្ដាប់ ៗ

សុខសាសន៍ ន. ដំណឹងឬសំបុត្រប្រាប់សេចក្ដីសុខ ៗ

សុខាភិបាល ន. ការរក្សាគ្រប់គ្រងទំនុកបំរុងឲ្យបានសេចក្ដីសុខ ៗ

សុខារម្មណ៍ ន. អារម្មណ៍ដែលទទួលសេចក្ដីសុខៗ

សុខុមព័ណ៌ ឬ វណ្ណ ន. គុ. ព័ណ៌ឬសម្បុរផូរផង់, -សម្បុរប៉ផូរ ៗ

សុខុមព្រស្ដ ន. សំពត់សាច់ម៉ដ្ឋ ៗ

សុខុមភាព ន. ភាពផូរផង់, ភាពល្អិតល្អន់ ។

សុខុមាលជាតិ ន. ជាតិដែលធ្លាប់តែស្រណុក, ជាតិជាអ្នកធ្លាប់តែស្រណុក ។

សុខោទ័យ ន. ការរះឡើងឬកើតឡើងនៃសេចក្ដីសុខ ។

សុគតិគមន៍ ន. ការទៅឬដំណើរដោយល្អ, ដំណើរទៅកើតស្ថានសួគ៌ ។

សុគតិបរាយណ៍ (ម.ថ.-ប៉ាក័យ) អ្នកដែលបំរុងនឹងទៅកើតឯស្ថានសួគ៌ ។

សុគន្ធវារី ន. ទឹកអប់, ទឹកក្រអូប ។

សុង្ហឹមគ្រឹះ ន. ផ្ទះគយ, ផ្ទះសម្រាប់ហូតពន្ធ ។

សុបន៍យ៍, វិសុបន៍យ៍ ន. កម្រាល, កម្រាលសម្រាប់ដេក ។

សុញ្ញកម្ម ន. អំពើឥតប្រយោជន៍, ការឥតប្រយោជន៍ ។

សុញ្ញភាព ន. ភាពទទេ, ភាពសូន្យ ។

សុញ្ញាគារ ន. ផ្ទះទទេ, ផ្ទះស្ងាត់ ។

សុទ្ធសាធ គុ. គ្រប់ព្រម, ទាំងគ្រប់ ។

សុទ្ធជីព ន. អ្នកដែលមានការចិញ្ចឹមជីវិតត្រឹមត្រូវ ។

សុទ្ធិបត្រ ន. សំបុត្របរិសុទ្ធ, សំបុត្របើកខែត្រ ។

សុធាការ ន. អ្នកដុតកំបោរ, ជាងកំបោរ, ជាងបាយអ ។

សុធាគ្រឹះ,-សុធាភពន៍ ន. ផ្ទះឥដ្ឋ, ផ្ទះថ្ម ។

សុន្ទរពេចន៍,-សុន្ទរកថា ន. សំដីពីរោះ, សំដីគួរឲ្យ
ចង់ស្ដាប់ ។

សុន្ទរភាព ន. ភាពល្អ, សេចក្ដីល្អ ។

សុន្ទរលក្សណ៍,-លក្ខណ៍ គ្រឿងសំគាល់ថាល្អ, -
លក្ខណៈល្អ ។

សុន្ទរម័តិ ន. គំនិតល្អ, គំនិតត្រូវ ។

សុន្ទរទាន (ម.ថ. សុន ទាន) ទានល្អ, អំណោយដែលឲ្យដោយប្រពៃ ។

សុប្បថ(មថ. សុបបត់)ន. ផ្លូវស្រួលទៅមក, លំអានធម៌ត្រឹមត្រូវ

សុប្បភាត,-ប្រភាត ន ពេលថ្ងៃរះ ។

សុភាព គុ. ទន់ភ្លន់, រាបទាបចុះបែបបទ ។

សុភោជន៍ ន. ភោជនឆ្ងាញ់, ភោជនល្អ ។

សុរដ្ឋាន ន. រោងឬអាស្រមគេប្រតិស្ឋានទេវរូប ។

សុរាល័យ,សុណាល័យ ន. រោងឬប្រាសាទដែលសន្មតថាជាលំនៅនៃទេវតា ។

សុរាសោណ្ឌ ន. មនុស្សស្រវឹងខ្លួប, អ្នកញៀនស្រា ។

សុរិយ័ន ន. ព្រះអាទិត្យ (ច្រើនប្រើក្នុងពាក្យកាព្យ) ។

សុវណ្ណប័ដ,-បដ្ដ ន. ដំបូរមាស ។

សុវណ្ណការ ន. ជាងមាស ។

សុវណ្ណភិង្គារ ន. កណ្ដីមាស ។

សុវណ្ណភាជន៍ ន. ចានមាស, ភាជន៍មាស ។

សុវត្ថិភាព ន. ការប្រកបដោយសេក្ដីសុខ, ការមានសួស្ដី។

សុស្នំង (សុសស្ងាន់) ន. ភ្លើង, កំដៅ, សេចក្ដីក្ដាហាន ។

សូករិកដ្ឋាន ន. ទីពិឃាតជ្រូក, កន្លែងសម្លាប់ជ្រូក ។

សូរ្យកាល ន. ពេលថ្ងៃត្រង់ ។

សូរ្យគ្រាស-គ្រាះ ន. ដំណើរដែលរាហូចាប់ឬបាំងដួងព្រះអាទិត្យ ។

សៀធី គុ. អាប់ឱន, ទន់ទាប, ទន់ថយ ។

សេដ្ឋកម្ម, សេដ្ឋកិច្ច ន មុខការរបរដ៏សំខាន់ក្នុងប្រទេសនីមួយៗ មុខរបរដ៏ឧត្ដម ការប្រកិច្ចការមានប្រយោជន៍សំខាន់។

សេដ្ឋការ ន. អ្នកធ្វើសេដ្ឋកម្មឬសេដ្ឋកិច្ច ។

សេដ្ឋពាណិជ ន. អ្នកជំនួញឯក ។

សេនាបរ ន. ពហានល្បាក ។

សេនាធិការ ន. អ្នកចាត់ការខាងកងទ័ព ។

សេនាបតី ន. ចៅហ្វាយសេនា ។

សេនាប្រណោត្រិ (ម.ថ. ប្រណោត) មេទ័ពរង ។

សេនាព្យូហ៍ ន. របៀបកងទ័ព, ក្បួនទ័ព ។

សេនាប្រមុខ ន. ស្តេចសឹក ។

សេនាសន្និបាត ន. ការកុំកងទ័ព ។

ស្វៃរីប្រទេស, (ប្រទេសសេរី) ន. ប្រទេសឯករាជ្យ

ដែលមានអំណាចពេញទី ។

សេរីភាព, ស្វៃរីភាព ន. ភាពដែលមានអំណាចធ្វើអ្វី

បានតាមអំពើចិត្ត, អំណាចពេញទី, (ប៉ុន្តែមានមាត្រា

ច្បាប់ជាគោលដែរ, ឬក៏ស្វ័យភាពក៏មាន) ។

ស្វៃរិន ន. អ្នកដែលមានអំណាចលើខ្លួន, អត្តាធីន ។

សេវក ន. អ្នកបំរើ, អ្នកចាំទទួលការបំរើ ។

សេន្យាភាព ន. ភាពប្តូរដំណើរទាហានឬកងទ័ព ។

សោធនបត្រ-ប័ត្រ ន. សន្លឹកប្រាប់ពាក្យខុសត្រូវ ។

សោធន៍ ន. អំពោស, ច្រាស, ប្រែន ។

សោភ័ណ ឬ សោភ័ន គុ. ល្អគន្ធ, ហ្មត់ហ្មង ។

សោភាគ្យ ន. លំអ, សេចក្តីសុខ, សេចក្តីចំរើន
(កុ. សៅភាគ្យ ក៏មាន)

សៅរ៉ភ ឬ សៅរ៉ម្យ (ម.ថ.- រ៉ុប,-រ៉ុម) គ្រឿងក្រអូប,
ទឹកអប់ ។

សៅវលក្សណ៍,-ល័ក្សណ៍ ន. លក្ខណៈល្អ ។

សំរិទ្ធិការ្យ ន. ការសម្រេច, កិច្ចការដែលសម្រេច
ប្រយោជន៍ ។

សំរេចន៏យ៍ គុ. ដែលគួរសរសើរ ។

សំវេជនីយដ្ឋាន ន. ទីដែលគួរឲ្យកើតសេចក្ដីសង្វេគ ។

ស្ដូន ន. ដោះ (ក្លាយទៅជា សុដន់) ។

ស្ដូនយុគល ន. ដោះទាំងគូ ។

ស្ថានបាល ន. អ្នកចាំទី,-កន្លែង, ឆ្មាំទី ។

ស្ថានីយ ន. ទីសម្រាប់ឈប់, ទីចំណត, ដំណាក់សម្រាប់ឈប់ ។

ស្ថាបនា ន. ការតាំង, ការតាក់តែងឬការតែងតាំង, ការសង់ ។

ស្ថាបនិក ន. អ្នកតាក់តែង, អ្នកសាង, អ្នកសង់ ។

ស្ថាពរ គុ. ខ្ជាប់ខ្ជួន, រឹងប៉ឹង, ឋិតថេរ ។

ស្នានីយ ឬ (នហានីយ) គុ. ដែលជាគ្រឿងសម្រាប់ងូត ។

ស្នានវេស្ម បន្ទប់សម្រាប់ងូតទឹក ។

ស្នានីយភណ្ឌ គុ.ន. របស់សម្រាប់ប្រើការដុះដារ (ដូច

លំអិត, សាប៊ូ ... ជាដើម) ។

ស្រាទ្ធពិធី (ម.ថ. ស្រាតធ:-) ន. ពិធីសែនតាមកាលកំណត់, ពិធីសែនដូនតា, ពិធីធ្វើទក្ខិណានុប្បទានតាម-កាលកំណត់ ។

ស្រីមន្ត (ម.ថ.-ម៉ាត់) គុ. មានស្រីសួស្ដី, មានលំអ, មានទ្រព្យ ។

ស្រឹង្គារ ន. សេចក្ដីស្រឡាញ់, គ្រឿងប្រលោមចិត្ត ។

ស្រោត្រ ន. ត្រចៀក ។

ស្វច្ឆន្ទ (ម.ថ. ស្វ័ច ឆ័ន) គុ.ន. ដែលមានសេចក្ដីពេញចិត្តចំពោះខ្លួនឯង, អ្នកដែលប្រព្រឹត្តតាមទំនើងចិត្តខ្លួនឯងបាន ។

ស្វទេសភក្តិ (ម.ថ.ស្វះទេះ ភ័ក ) ន.គុ ដែលស្រឡាញ់ស្រុកកំណើតរបស់ខ្លួន ។

ស្វាគមន៍ ន. ដំណើរមកដោយស្រួល,-ដោយសេចក្ដីរីក

កយដោយសេចក្ដីកក់ក្ដៅ ។

ស្វាគតភាព ន. ភាពនៃដំណើរមកដោយស្រួល ។

ស្វីករណ៍,ស្វីក្រិត,ស្វីក្រឹត (ម.ថ.ស្វី ក.ស្វីក្រឹត (ការទទួលយក, ការយល់ព្រម, ការយល់ព្រមជាមួយ ។

ស្វីការ ន. ការទទួលយក, ការធ្វើប្ដេជ្ញា ។

ស្វទេស ន. ប្រទេសរបស់ខ្លួន, ស្រុកកំណើត,ជាតិភូមិ។

សទ្ទ័យ ន. នៃរបស់គាសា ។

ស្វជន ន' ជនរបស់ខ្លួន, គឺជនជាញាតិ ។

ស្វភូមិ ន. ភូមិឬទីរបស់ខ្លួន, ស្រុកទេសរបស់ខ្លួន ។

ស្វាធីន ន. ដែលតាមអំពើចិត្ត, ដែលស្រេចលើខ្លួនឯងមនុស្សស្វាធីន ។

ស្ថិរភាព ន. ភាពឋិតថេរ ។

សេវាលជាតិ (ម:ជ. សេវាលៈជាត) ន. ករិដលជាតិ

ពួកអណ្ដែតទឹក, មានសារាយ, ចកជាដើម ។

សូទគ្រឹះ ន. ពេនសម្រាប់បំអិនបាយ, ផ្ទះបាយ ។

សូទសាស្ត្រ ន. ក្បួនច្បាប់វិជ្ជាធ្វើម្ហូប, ក្បួនច្បាប់សូទកម្ម

សុភកម្ម ន. អំពើល្អ, សុភករ, អ្នកធ្វើឲ្យមានសេចក្ដីចំរើន ។

សម្បត្តិធារណ៍, សម្បត្តិធារក៍ ន. អ្នកទ្រទ្រង់នូវសម្បត្តិ អ្នកកាន់កាប់សម្បត្តិជំនួសគេ ។

សង្គហការណ៍ ន. ហេតុឬដំណើរនៃសេចក្ដីសង្គ្រោះ។

សញ្ជីវ័ន ន. ការមានជីវិតរស់នៅ, ការចំរើនអាយុ ។

សន្ត្រាព ន. ការលាក់ខ្លួនពួនអាត្មាមិនឲ្យអ្នកណាឃើញ, ធ្វើសន្ត្រាព ។

សម្ពុប្ពយ ន. ការប្រមែប្រមូលផ្សំ, ការកក្កូន ។

សម្ពុជ្ជិល (ម.ថ. ស. មុច ដល់) គុ. ដែលរុងរឿងខ្លាំង

ក្តីសនោ្ទសនៅ្ទ, ព្រោនព្រាត ។

សមោធាន ន. ការប្រជុំ, ការប្រមូលរួបរួម (កិ. ប្រជុំ, ក្តុំ) ។

សារវន្ត គុ. ដែលមានខ្លាក់ឋាន, ដែលមានសេចក្តីអន់អាចដែលសំខាន់, ដែលមានសេចក្តីរឹងប៉ុន, មានខ្លឹមសារ ។

ហង្សបាទ (ម.ថ. ហង់សប៉ាត) ន. ពណ៌ក្រហមដូចជាសម្បុរជើងហង្ស ។

ហរិរក្ខ-រក្ស ន. ព្រះនារាយណ៍, អ្នករក្សាព្រះនារាយណ៍

ហរិបន្ធ ន. ចន្ទន៍លឿង ។

ហរិតបណ្ណ,-ប័ត្រ ស្លឹកខៀវខ្ចី, ស្លឹកស្រស់ ។

ហត្ថកម្ម ន. ការដែលត្រូវធ្វើដោយដៃ, ការរបស់ផ្សេងៗ

ហសនភាព ន. ភាពសើចសប្បាយ,-ឬការរីករាយ ។

ហាសនីយ ឬ ហា–, គុ. ដែលគួរឲ្យសើច,–គួរឲ្យរីករាយ ។

ហាយនការណ៍ ន. ហេតុនៃសេចក្ដីវិនាស, ដែលនាំឲ្យវិនាស ។

ហាយនភាព ន. ភាពដែលសាបសូន្យ,–ដែលនាំឲ្យបាត់ទៅ ។

ហិតករ,–ការកៈ,–ការី,–ក្រឹត ន. អ្នកធ្វើផលប្រយោជន៍ឲ្យ, អ្នកទំនុកបំរុង ។

ហេតុម័ត (ម.ថ.–ម៉ាត់) ដែលមានហេតុ ។

ហោរាសាស្ត្រ, តារាសាស្ត្រ, ជោតិសាស្ត្រ ន. ក្បួនហោរ, វិជ្ជាសម្រាប់ហោរ ។

អកតញ្ញូ ន. អ្នកមិនដឹងឧបការគុណ ដែលគេបានធ្វើហើយ ។

អកតវេទី ន. អ្នកដែលមិនគិតនឹងតបឧបការគុណគេ ។

អករ៍ (ម.ប. អក.) អ្នកមិនធ្វើការអ្វីៗ, អករ៍យាយ ។

អករណីយ (ម.ប.អ:ក:រ:ណី, គុ. ដែលមិនគួរធ្វើ ។

អកាលបុស្ប ន. ផ្កាខុសកាល, ផ្កាខុសរដូវ ។

អក្កោសនការណ៍ ន. ហេតុឬដំណើរជេរគ្នា, ដំណើរនៃការជេរ ។

អក្កោសនភាព ន. ភាពឬដំណើរជេរគ្នា ។

អក្ខបាជិ (មប. អ័កខ: បាត) ន. ទីកីឡា, អក្ខបាដមន្ទីរ។

អក្ខរវិបល្លាស ន. ការបំបែកអក្សរ ។

អក្ខរប័ជិ,-បជ្ដិ ន. ដំបារប្រាក់, ដែលសរសេរខ្ចាក់អក្សរ ។

អក្ខរដ្ឋាន ន. ឋានទិញ្វាន (ឬកន្លែងបង្កើតអក្សរ) ។

អក្ខរសម័យ ន. វិធីប្រើអក្សរ, ការសរសេរឬអានអក្សរ ។

អក្ខរាភិធានសព្ទ ន. មេពាក្យដែលរៀបរៀងតាមលំដាប់អក្សរ, (វចនានុក្រម) ។

អក្សរលក្ខណ៍,-លក្សណ៍ ន. សំបុត្រសំគាល់ ។

អក្សិបក្ស៊ន (ម.ថ.-ប័កស៊ុន) ន. រោមភ្នែក ។

អក្សិភេស័ជ,-ភេសជ្ជ (ម.ថ.-ស័ច) ថ្នាំភ្នែក ។

អគតិគមន៍ ន. ការលុះក្នុងសេចក្តីលំអៀង ។

អគាធការណ៍ ន. ហេតុឬដំណើរដែលជ្រាលជ្រៅពុំ
អាចស្ទង់បាន ។

អគ្គដ្ឋាន ន. តំណែងឬឋានន្តរដ៏ឧត្តម ។

អគ្គមន្ត្រី ន. មន្ត្រីផុតលេខ ។

អគ្គលេខាធិការ ន. ស្មៀនធំ ។

អគ្គសេនាបតី ន. សេនាបតីធំបណ្តាច់ ។

អគ្គិកឡា, អគ្គិក្រីឌា, ន. កាំជ្រួច, រន្ទា, កី, ទៀន ។

អគ្គិសនី ន. ភ្លើងរន្ទះ (សម័យនិយមហៅថាអគ្គិសនី)

អគ្ន្យស្ត្រ (ម.ថ. អ័ក គ័ន យ័ស) ន. កាំភ្លើង ។

អគ្ន្យុត្បាត (ម.ថ. អ័ក គ័ន យុតត្បាត) ន. ភ្លើងដែលធ្លាក់ចុះពីអាកាស ។

អគ្និប្រស្ត (ម.ថ.-ប្រ័ស) ន. ថ្មដែកភ្លើង, ថ្មដែកកេះ ។

អគ្និមណី (ម.ថ.-មនី) អំពូលអគ្គិសនី, អំពូលពិល (តាមសម័យនិយម) ឬថាអគ្គិមណី ក៏បាន) ។

អគ្និវាណ ន. គ្រាប់បែកផ្ទុះ គ្រាប់កាំភ្លើងដែលផ្ទុះចេញជាភ្លើង (ស. និ.) ។

អគ្និហោត្រ ន. វត្ថុដ៏ឧត្តមសម្រាប់បូជាភ្លើង ។

អគ្យាគារ ន. រោងភ្លើង ។

អង្គការ ន. ការធ្វើសេចក្តីដែលចែកឲ្យឃើញចំនួន,-ឬឲ្យឃើញរូបសេចក្តី (ស. និ. អង្គការវដ្ត...) ។

អង្គការដ្ឋាន ន. កន្លែងតាំងអង្គការ, កន្លែងធ្វើអង្គការ ។

អឃម័យ គុ. ដែលបរិបូណ៌ដោយសេចក្ដីទុក្ខ, ដែលរង
សុទ្ធតែទុក្ខ ។

អង្គប្បញ្ញត្តិ ន. ការបញ្ញត្តិដោយមានហេតុជាគ្រឿងសំគាល់ៗ

អង្គមន្ត្រី ន. មន្ត្រីថ្នាក់ខ្ពស់, ជាអ្នកប្រឹក្សាការផែនដីជា
មួយនឹងព្រះរាជា ។

អង្គវិក្ខេបន៍ ន. ដំណើរកាសដៃ, លើកជើង, បែរឆាក
មើលនៃអព្យត ។

អង្គាព្យព (ម.ថ. អង្គា ព្យប់) ន. អវយវៈទាំងអស់នៃ
រាងកាយ ។

អង្គារាគ ន. ម្សៅក្រអូប, ប្រេងក្រអូប,... ។

អង្គារដ្ឋាន ន. កន្លែងដាក់ធ្យូង ។

អង្គារៈលេណ ន. ឡដុតធ្យូង ។

អង្គារលេណដ្ឋាន ន. កន្លែងឡដុតធ្យូង ។

អង្គារពាណិជ ន. អ្នកលក់ធ្យូង ។

អង្គុលីវេស្ត ន. (ម.ថ.-វេស) ស្រោមដៃ, ស្រោមម្រាមដៃ ។

អង្គ្រ័ក្ស ន. អ្នករក្សាអង្គព្រះរាជា, ទាហានរក្សាព្រះអង្គ (ប្រើជា អង្គរក្ស. ក៏មាន) ។

អចរណភាព ន. ការទៅមកមិនកើត, ទៅមករកគ្នាពុំបាន ។

អចិរកាល ន. កាលខ្លី, វេលាមិនយូរ ។

អច្ឆរិយការណ៍ ន. (ម.ថ. អ័ច ឆ: រិយ:) ហេតុជាទីអស្ចារ្យ ។

អច្ឆារ៍ទ កិ. គោរព, គំនាប់ ។ ន. ការសំដែងសេចក្ដីគោរព, ការគំនាប់ ។

អច្ឆិទ្រព្រឹត្តិ (ម.ថ. អ័ច ឆិត ទ្រ:-) ន. ការប្រព្រឹត្តមិនដាច់ដំណើរធ្វើការឥតដាច់ជានិច្ច (ប្រើនិយាយតែពីការល្អ) ។

អជិនប្រទេស ន. ឋានស្ងាត់, ព្រៃទូគិមស្ងាត់ ។

អជ្ឈាចារ ន. ការប្រព្រឹត្តខុសច្បាប់, មារយាទអាក្រក់ ។

អជ្ឈេសនា ន. ការអញ្ជើញ, ការអារាធនា, ការនិមន្ត ។

អជ្ឈោសាន ន. ការស្ទង់មើលឲ្យដឹងទីបំផុត ។

អញ្ញាតកេត ន. មនុស្សសាត់អណ្តែត ។

អញ្ញាតក្រឹត (ម.ថ-ញ៉ា-) អ្នកដែលធ្វើការអ៊ើៗ ស្មានៗ ព្រោះពុំយល់ការ ។

អញ្ញាតករេស ន. ការគៀសខ្លួនមិនឲ្យគេស្គាល់ ។

អញ្ញាតជន ន. មនុស្សដែលគេមិនស្គាល់ ។

អញ្ញោបត្ថម្ភិត (ម.ថ. អ័ញ ញោ ប័ត ថ័ម ភិត) ន. អ្នកដែលនៅក្នុងទំនុកបំរុងនៃអ្នកដទៃ, ប្រទេសដែលមានក្សត្រិយ៍ទ្រង់រាជ្យ ប៉ុន្តែនៅក្នុងការទំនុកបំរុងនៃប្រទេសដទៃ ។

អដវីកាធិបតី ន. អធិបតីក្រសួងមេព្រៃ ។

អធិកម្មករ ន. អ្នកធ្វើការស៊ីឈ្នួលថែរក្សាព្រៃ ។

អដ្ឋប្រតិភូ ន. អ្នកជាទាវៀនក្តី, អ្នកថណាយក្តី, ស្មាក្តី

អដ្ឋវស្ស (ម.ថ.-វស់) ប្រាំបីឆ្នាំ, (កុំអដ្ឋវស្ស) ។

អឌ្ឍមាស ន. កន្លះខែ ។

អឌ្ឍចន្ទ ន. ព្រះចន្ទរះមិនពេញវង់ (ព្រះចន្ទលេចមក ពាក់កណ្តាល គឺឃើញតែពាក់កណ្តាល)

អណ្ឌភោគ ន. មនុស្សកើតពេកស្រែងកន្ថែប ។

អតិវុឌ្ឍ គុ. ចាស់ណាស់ ។

អតិតរុណ ន. កូនខ្ចី ។

អតីត គុ. ដែលកន្លងទៅហើយ, ដែលហួសទៅហើយ បើហៅថា អឌិត ត្រូវសរសេរអតីត, ឧ. អំពីអតីតតមកៗ ឧ. កាលពីអឌិត (អតីត) មានបុរស... ។

អតីតមន្ត្រី ន. ម.ថ. អតីតៈ–) មន្ត្រីចាស់, មន្ត្រី-

ដែលឈប់លែងធ្វើរាជការហើយ ។

អត្តសន្និយាតន៍ (ម.ថ. សន់និយ៉ាត) ការប្រគល់ខ្លួនឲ្យនៅក្នុងអំណាចគេ ។

អត្តនោម័តិ ន. ការយល់ឃើញអំពីគំនិតរបស់ខ្លួន ។

អត្ថចារិយ ន. អ្នកឈ្លាសឬជំនាញក្នុងសេចក្ដីពន្យល់ ។

អត្ថគ្រឹះ ន. ផ្ទះដាក់អីវ៉ាន់ ។

អត្រានុកូលដ្ឋាន ន. បញ្ជីកើតស្លាប់, អាពាហ៍ពិពាហ៍ ឬអាក់ហាមណ្ឌលប្រជាជន (និយមប្រទេស) ហៅថាមន្ត្រីអត្រានុកូលដ្ឋាន មន្ត្រីកាន់បញ្ជីកើតស្លាប់និងអាពាហ៍ពិពាហ៍ ។

អទារជិន ន. ប្រុសលីវ, មនុស្សឥតភរិយា ។

អទារុណភាព ន. ភាពស្លូតត្រង់ល្អ ។

អទិស្សមានការណ៍ ន. ហេតុឬដំណើរពុំប្រាកដ ។

អទ្ធន ន. ផ្លូវ, ផ្លូវឆ្ងាយ, ដងផ្លូវ, កាល, វេលា ។

អទ្ធានគមន៍ ន. ការដើរផ្លូវឆ្ងាយ, ការធ្វើដំណើរទៅឆ្ងាយ ។

អទ្ធានគមនាគមន៍ ន. ការទៅមកតាមផ្លូវឆ្ងាយ ។

អធិកមាស លើកខែ, គឺខែអាសាឍ២ដងដែលលើកបន្ថែមតាមចន្ទគតិ, (គឺបឋមាសាឍ, ទុតិយាសាឍ) ។

អធិកវារៈ លើកថ្ងៃ គឺថ្ងៃមួយដែលថែមគ្រប់ខែជេស្ឋតាមចន្ទគតិ ។

អធិកសុរទិន,-សូរ្យទិន ថ្ងៃមួយដែលលើកថែមគ្រប់ខែកុម្ភៈ តាមសូរ្យគតិ ។

អធិករណលេខកៈ ន. ស្មៀនតុលាការ ។

អធិករណលិខិត ន. លិខិតកាត់ក្តី, សាលក្រម ។

អធិការ ន. ការបង្គាប់បញ្ជា, អ្នកត្រួតត្រា, អ្នកទទួលការខុសត្រូវ, (ស.ន៍ អធិការសាលាវត្ត, អធិការវង្ស,

អធិការវេទ្រ ។

អធិការី ន. អ្នកដែលជាប្រមុខក្នុងការត្រួតត្រាកិច្ចការ

និមួយៗ, គ្រូធំ ។

អធិក្រម,–អធិក្រមណ៍ ន. ការកុកពនចូល, ការលុក

ចូល, អធិក្រមណ៍នៃកងទ័ព ។

អធិក្រឹតិ ន. ការយល់ព្រម, អនុញ្ញាត ។

អធិដ្ឋាន ន. ការតាំងចិត្តតម្រង់ចំពោះ, ការសុំបួង

សួងដោយចិត្តនឹក ។ ជាកិរិយា តាំងចិត្ត ។

អធិបតី ន. អ្នកដែលជាធំ, ជាប្រមុខ ។

អធិមានិក ន.គុ. ឫកឫស, មុខរឹង, អ្នកដែលមានមានះខ្លាំង។

អធិវាសនបត្រន.សំបុត្រព្រមទទួលនិមន្ត ព្រមទទួលអញ្ជើញ

អធុនិក ន.គុ. ដែលកើតមានក្នុងសម័យថ្មី, មនុស្ស

ជាន់ថ្មី ។

អន័គ្ឃអនេក គុ. ច្រើនកាត់ថ្លៃពុំបាន, ច្រើនឥតបើគណនា ។

អនង្គសម្ភាស,– សម្ភាសន៍ ន. ការនិយាយផ្តោះផ្តង ទៅមករកគ្នា, ការនិយាយថៃថង់ ។

អនញ្ញការណ៍ ន. ហេតុឬដំណើរតែមួយ ។

អនន្តរគមនាគមន៍ ន. ការទៅមកបន្តគ្នាមិនដាច់ ។

អនារ្យប្រទេស ន. ប្រទេសគ្មានរបៀប, (ឥ.សប្បុរជន ស៊ីសំណូកផ្តេសផ្តាស, ប្រទេសមិនចំរើន ។

អនវ័តប្ត ន. ស្រះអនោតត្ត ។

អនវិទ្យ,–វ័ទ្យ (ម.ថ-រ័ត) គុ. ដែលឥតទោស, អ្នកដែលឥតទោស ។

អនាម័យ ន. ដំណើរមិនមានរោគ, ឥតជម្ងឺ ។

អនុគមន៍ ន. ការក្រោកជូនដំណើរ, ការតាមជូនដំណើរ ។

អនុជីវិន ន. អ្នកធ្វើការបំរើ ។

អនុញ្ញាត កិ. យល់ព្រម, បើកឱកាសឲ្យ ។ ន. ការយល់ព្រម ។

អនុនាយក ន. នាយករង ។

អនុប្បញ្ញត្តិ ន. ការបញ្ញត្តបន្ទាប់អំពីបឋមបញ្ញត្តិ ។

អនុម័តិ ន. ការយល់ព្រម ។

អនុមន្ត្រី ន. មន្ត្រីបន្ទាប់, មន្ត្រីរង, មន្ត្រីថ្នាក់រង ។

អនុយន្ត្រ ន. អ្នកហែហម, អ្នកហែតាម ។

អនុវត្តន៍,-វត្តិ ន. ការប្រព្រឹត្តតាម, ការបណ្ដោយតាម។

អនុសាសន៍ ន. ពាក្យប្រៀនប្រដៅ, ការប្រៀនប្រដៅ។

អនុសិរិត្សរ៍ ន. កល់ឆ្នាំ, ប្រចាំឆ្នាំ ។

អនុពាក្យ ន. សារសេរតាមសូត្រ, សរសេរតាមគេអាន។

អនុស្សាវរីយ៍ ន. ពាក្យកំណត់ដោយទុកអ្វីៗមួយជាទី

រលឹកតទៅ ។

អនោតត្ត ន. ស្រះធំមានទឹកមិនត្រូវកំដៅថ្ងៃ ។

អនោសជ្ជភាព ន. ដំណើរមិនលះបង់ព្យាយាមក្នុងកិច្ចការណាមួយ, ការមិនលះបង់ព្យាយាម ។

អន្តរការណ៍ ន. ហេតុឬដំណើរដែលនាំឲ្យទើសទាក់ ។

អន្តរាត្មន ន. ចិត្តឯង, ខ្លួនឯង, ក្នុងចិត្ត, ក្នុងខ្លួន ។

អន្តរាគមន៍ ន. ការមកដោយទើសទាក់, ការមកដោយមានឧបសគ្គ:, ដោយមានកិច្ចការត្រូវប្រាស្រ័យរកគ្នានឹងគ្នា

អន្ធការពន្ធនាគារ ន. គុកងងឹត ។

អន្វេស,–អន្វេសន៍ ន. ការស្វះស្វែងតាមរក’ ការខំប្រឹងរក ។

អបគមន៍ ន. សេចក្តីព្រាត់ប្រាស់គ្នា,ការបែកចេញពីគ្នា ។

អបករណ៍ ន. ទោស, កំហុស, អំពើពុំប្រសើរ, ការធ្វើ

មិនល្អ ។

អបរាជ័យ ន. ការមានជ័យ, មានជំនះ, ដំណើរឈ្នះ ។

អបលោកន៍ ន. ការប្រកាសប្រាប់ឲ្យដឹងពល់គ្នា, ការប្រ-
កាសសូមអនុញ្ញាតអំពីក្រុមជំនុំក្នុងសន្និបាត ។

អបាករណ៍ ន. ការដំរះបញ្ចាំបំណុល, ការដំរះបំណុល ។

អប្បវិជ្ជ,អប្បវិទ្យ,អល្បវិទ្យ (ម.ច. អ័បប៉ះវិច,-វិត,អ័ល-
ប៉ះវិត) អ្នកដែលចេះដឹងតិច, អ្នកមានវិជ្ជាតិច ។

អប្បដិវត្តន៍ ន. អំពើអ្វីៗដែលប្រព្រឹត្តទៅពុំបាន ។

អប្បដិវត្តិយ៍ ន·គុ. ដែលឥតមានអ្នកណាអាចឲ្យប្រព្រឹត្ត
ទៅបាន ។

អប្បមាទសម្បាទន៍ (ម.ឋ. អ័បប៉ះមាទៈ ស័មប៉ាត)ន.
ការមិនធ្វើសេចក្ដីធ្វេសប្រហែសឲ្យបរិបូណ៌ ។

អប្ផោដិតសទ្ទ (ម.ឋ. អ័ប ផោដិះ ស័ប) ស្វរទះដៃ

ទទួលអំណរ ឬឲ្យពរ សូរទះដៃ ។

អព្ភុតការណ៍ ន. ហេតុចំឡែក, អស្ចារ្យ ។

អព្យាក្រឹត មិនសម្រេចខាងណា, ដែលនៅជាកណ្ដាល ។

អភ្យាគមន៍ ន. អ្នកដែលមានសំណាងតិច ។

អភិគមន៍,–គម ន. ការប្រសព្វមុខចូលគ្នា, ការជួបគ្នា, ការរួបរួមគ្នា ។

អភិញ្ញាតការណ៍ ន. ហេតុប្រាកដ, ហេតុដែលគេដឹងប្រាកដ ។

អភិធាវ័ន ន. ការស្ទុះរត់, ការរត់ដេញតាម ។

អភិធេយ្យ,–ធៃយ ន. ឈ្មោះ, គ្រឿងសំគាល់ ។

អភិនន្ទន៍ (ម.ថ.–នន់) ន. អំណរខ្លាំង ។

អភិនវកម្ម ន. អំពើដែលទើបបង្កើតថ្មី, ការទើបបង្កើតថ្មី ។

អភិនន្ទនាការ ន. អាការនៃអភិនន្ទន៍ ។

អភិរតី,–រត គុ. សេចក្តីរីករាយក្រៃលែង ។

អភិសាបន៍ ន. ការស្បថបំពាន ។

អភិហារិ,–រី ន. ចោរឆក់ឥវ៉ាន់ ។

អភិនិស្ក្រមណ៍,–នេស្ក្រមណ៍ ន. ការចេញបួស ។

អភិនេស្ក្រម៍ (ម.ថ. អភិនេស) អ្នកដែលលះទ្រព្យ សម្បត្តិ, បព្វជិត ។

អភិវន្ទន៍, អភិវាទន៍ ន. ការថ្វាយបង្គំ, ការគំនាប់, (ជាក់. អភិវន្ទ, អភិវាទ; ថ្វាយបង្គំ, សំពះ) ។

អភិសោធន៍ ន. ការជំរះ, ការផ្ទៀងសម្រេច, ( កិ. អភិសោធ, សំអាត, ផ្ទៀងតម្រូវ ) ។

អភ្យាគម (ម.ថ. អ័បក្យាគំ ) ន. សង្គ្រាម ។

អភ្យាគមនាគមន៍ ន. ការទៅមកសួរសុខទុក្ខគ្នា ។

អមោក្ស ន. អ្នកដែលជាប់ទោសឃុំអស់១អាយុ ។

អម្ភ័ស ន. ទឹក ។

អយស្កាន្ត (ម.ថ.អយ៉ុសស្កាន) ន.ដែកសម្រាប់កាត់ដែក (មេដែក) ។

អយស្ការ ន. ជាងដែក, ជាងរំលាយដែក ។

អយស្ម័យ គុ. ដែលធ្វើដោយដែក ។

អយុត្តិធម៌ ន ការប្រព្រឹត្តពុំត្រឹមត្រូវតាមគន្លងធម៌ឬច្បាប់ ។

អរណី ន. ពុំនួតភ្លើង, ដែកភ្លើង ។

អរហទ្ធជ (ម.ថ.អរហ័តធៈជៈឬធជ) ទង់នៃព្រះអរហន្ត (ចីវរ) ។

អរិន្ទ ន. មេសត្រូវ, ក្បាលសត្រូវ ។

អរិយ (ម.ថ.អៈរិយៈ,) គុ. ប្រសើរ, ត្រឹមត្រូវ, របៀបរយ (ផ្លាស់គ្នាប្រើជាអារ្យក៏បាន ដូចអារ្យប្រទេស, អារ្យធម៌)។

អរុណោទ័យ ន. វេលាថ្ងៃរះ, ពេលអរុណរះ ។

អរោគមន្ទីរ,–អរោគ្យមន្ទីរ ន. វេជ្ជគ្រឹះ, មន្ទីរពេទ្យ កន្លែងព្យាបាលរោគ, កន្លែងបំបាត់រោគ ។

អលង្ការណ៍ (ម.ថ អល័ងក) គ្រឿងប្រដាប់សម្រាប់តែងខ្លួន,(មានចិញ្ចៀន,ខ្សែមាសជាដើម (ប្រើជាអលង្ការក៏បាន)។

អលង្ក្រិត (ម.ថ. អ ល័ង ក្រឹត) គុ. ដែលធ្វើឲ្យសមរម្យ, ដែលប្រដាប់តាក់តែងឲ្យសមរម្យ ។

អលាភការណ៍ ន. ហេតុដែលនាំឲ្យឥតលាភ, ឲ្យខាតបង់ ។

អវិកជិ គុ. ដែលមានទំនងផ្សេងគ្នា, ដែលជាជំទាស់នឹងគ្នា, ដែលផ្សេងគ្នា (ប្រើជា អវិកុជារ ក៏បាន)

អវិគមន៍ ន. សេចក្តីចូលចិត្ត, ការយល់ជាក់ ។

អវិគ្រហៈ (ម.ថ. អវ័គ គ្រៈ ហៈ) គ្រឿងជំទាស់, គ្រឿង

ភព៌ន, ហេតុដែលឲ្យកើតមាន (ប្រើជា អវគ្រោះ ក៏បាន)

អវិជ័យ ន. ការប្រាបប្រាមបង្ក្រាបឲ្យបាក់បប; ឲ្យខូបខាប ។

អវិជ្ញាន ន. ការជ្រប់មុខ, ការសញ្ជប់សញ្ជឹង, ទ្រមឹងទ្រមើយ ។

អវិតារ (ម.ថ. អៈ វៈ តា) ន. ដំណើរចុះ, លំដាប់ត ។ (-ផ្សំជា ពន្ធ+អវតារ> ពន្ធាវតារ) ។

អវិត្តីយ (ម.ថ. អវ៌នទី) គុ. ដែលមិនគួរយាយបន្ថ, មិនគួរសំពះ, មិនគួរគិតនាប់ ។

អវិលោកន ន. ការរមិលមើល, ការឈ្ងោកមើល, ការសម្ញឹងសួនមើល ។

អវិទ្ធ គុ. ដែលគេបណ្ដេញបំបរបង់, ដែលគេលុបឈ្មោះចេញពីពងការ ។

អវិសិដ្ឋ, អវិសិស្ដ គុ. ដែលសល់នៅ, ដែលជាសំណល់ ៗ

អវិជ្ឈឃ្ឃការ ន. អវិជ្ជាដែលជាធំឥតសូន្យ, សេចក្ដីល្ងង់ខ្លៅៗ

អសម្ភិន្ន កិ.ឬគុ. ដែលមិនបែកធ្លាយ, មិនច្រឡំបល់ ៗ

អសាធារណ៍ គុ. ដែលមិនទូទៅ, ដែលមិនចំពោះតែមួយ ១ ៗ

អសុន្ទរភាវ, អសុន្ទរភាព អសុន្ទរពេជន៍ ន. សំដីអាក្រក់, សំដីមិនពីរោះ ៗ

អស្ដង្គត, (ម.ថ. អស់ស្ដង់គត់) កិ. គុ. លិចបាត់ទៅ, បាត់ពន្លឺទៅ ៗ

អស្ដង្គមន៍ (ម.ថ. អស់ស្ដង់គំ) ន. ដំណើរលិចបាត់ទៅ, ដំណើរលិចនៃព្រះអាទិត្យ ឬវេលាថ្ងៃលិច ៗ

អស្វជិពន៍, អស្សុជិពន៍ (ម.ថ.-ជប់) ន. ស្បៀន

សេះ ឬ ហៅថា អស្សជវ័ន ឬ អស្វជវ័ន ក៏បាន ។

អស្សពាហ៍, អស្វពាហ៍ ន. សេះជាជំនិះ, សេះជាពាហនៈ ។

អស្សយុទ្ធ ន. សេះប្រខាំគ្នា ។

អស្សរតន៍, អស្សរ័ត្ន ន. សេះកែវសម្រាប់ស្ដេចចក្រពត្តិ ។

អស្វារោហ៍, អស្សារោហ៍ ន. អ្នកជិះសេះ ។

អស្វរិទ្ធិ, អស្សរិទ្ធិ ន. រិទ្ធិរបស់សេះ (គ្រឿងឥស្សរយស, ហៅថា មេរៃជ័យ អស្សរិទ្ធិ ក៏បាន) ។

អស្វិន ន. អ្នកបង្ហាត់សេះ, អ្នកជិះសេះ (ឈ្មោះផ្កាយនក្សត្រឫក្ស ។

អស្សត្ថព្រឹក្ស, អស្វត្ថព្រឹក្ស (ម.ថ. អ័ស ស័ត ថ: ព្រឹក ឬ អ័ស ស្វ័ត ថ:-) ដើមពោធិ៍ ។

អស្សុជលន័យន៍ ន. ភ្នែកដែលទទឹកដោយទឹកភ្នែក, អ្នកយំ ។

អហង្ការិក,-រី គុ.ន. ដែលប្រកាន់មានះខ្លាំង, អ្នករឹងត្អឹង,

អហោរាត្រ ន. ថ្ងៃនឹងយប់, ថ្ងៃមួយនឹងយប់មួយ ។

អាករិក ន. អ្នកស្គាល់ត្បូង, អ្នកស្គាល់កន្លែងកើតត្បូង ។

អាករដ្ឋាន,-ស្ថាន ន. ទីដែលមានត្បូង, មានលោហធាតុ (រ៉ែ) ។

---

អាកាសវិហាស៍ (ម.ថ.–វេហា) កណ្ដាលអាកាស ។

អាកាសស័យន៍ (ម.ថ-សៃ) ន. ការដេកកណ្ដាលវាល ។

អាកិណ្ណគ្រឹះ, ន. ផ្ទះកុះកុំ, ដែលមានផ្ទះច្រើនត្រៀបត្រា ។

អាកិណ្ណភណ្ឌ ន. អីវ៉ាន់ដែលដាក់ច្រឡាយគ្នា, ច្របូកច្របល់គ្នា ។

អាកិណ្ណវិហារ ន. ការនៅច្រឡូកច្រឡំគ្នា ។

អាកុលដ្ឋាន,-ស្ថាន ន. ទីសុកមម៉ុក ។

អាក្រម,-អាក្រមណ៍ ន. ការធ្វេងចូលផុក, ការចូល លុក, ការចូលតយុទ្ធគ្នា, ការប្រថាមប្រថាប់ ។

អាក្រោធន៍ ន. ទឹងខ្លាំង, កំហឹងខ្លាំង ។

អាឃាតការណ៍ ន. ដំណើរដែលនាំឲ្យគំនុំគ្នាឬឲ្យមានការ បៀតបៀនគ្នា ។

អាឃាតន៍ ន. ការពិឃាត, ការសម្លាប់, កន្លែង សម្រាប់សម្លាប់ ។

ឃោសនាការ ន. អាការប្រកាសដំណឹងផ្សាយឲ្យឮ សុសសព្ទ ។

អាបរិយព្យាករណ៍ ន. ចំណាយគ្រូ ។

អាជិសិរស (ម៉ថ. ក៏ស់) បន្ទាយបោះទ័ពកន្លែងបំណាត កន់ទ័ព ។

អាជីព ន. ការរស់នៅ, ការចិញ្ចឹមជីវិត ។

អាជីវប្បវត្តិ, អាជីវប្រព្រឹត្តិ ន. ដំណើរប្រព្រឹត្តនៃអាយុ, មុខការរបរសម្រាប់ចិញ្ចឹមជីវិត ។

អាជ្ញាករ, អាជ្ញាការិន ន. អ្នកធ្វើតាមពាក្យបង្គាប់ ។

អាជ្ញាបត្រ ន. សំបុត្របង្គាប់ជាផ្លូវការ ។

អាជ្ញាបទ ន. ខបញ្ញត្តិ, មាត្រាច្បាប់ ។

អាឍ្យបរ (ម.ឋ–ឍ្យៈប) គុ. ដែលធ្លាប់មានទ្រព្យស្តុកស្តម្ភពីដើមមក (ដែលធ្លាប់ជាអ្នកមានមកយូរហើយ) ។

អាណ័ត្តិ, អាណាត្តិ (ម.ឋ. អាណ័ត, អាណ័តតិ) ន. ពាក្យបង្គាប់, សេចក្តីបង្គាប់, គ្រឿងសំគាល់ឬចំណាំ ។

អាណត្តិកម្ម ន. ការធ្វើនូវសេចក្តីបង្គាប់, ការធ្វើនូវគ្រឿងសំគាល់ ។

អាណត្តិការណ៍ ន. ហេតុឬដំណើរនៃអាណ័ត្តិ ។

អាណាខេត្ត ន. ខេត្ត, ដែននៅក្នុងអំណាចគ្រប់គ្រង នៃមហាក្សត្រឬរដ្ឋបាលមួយ ៗ ។

អាណាប្រជានុរាស្ត្រ ន. ប្រជាជនដែលនៅក្នុងអាណាខេត្តនឹងរាស្ត្រប្រជាក្នុងបំណុះប្រទេស ។

អាណាព្យាបាល ន. អ្នកគ្រប់គ្រងរក្សាអាណាខេត្ត ។

អាតុរភាព ន. ភាពនៃជម្ងឺគ្រុនក្តៅខ្លាំង, ភាពនៃជម្ងឺ ។

អាត្មក្រឹត ដែលនាំបណ្តាលពីខ្លួនឯង ។

អាត្មទ្រោហិន ន. ដំណើរធ្វើខ្លួនឲ្យលំបាកហួសហេតុ ។

អាត្មោបជីវិន ន. អ្នកចិញ្ចឹមជីវិតអាស្រ័យកម្លាំងខ្លួនឯង ។

អាទរភាព ន. ការនៃសេចក្តីអើពើ, ដំណើរដែលយកចិត្តទុកដាក់ ។

អាទិករ ន. អ្នកផ្តើមធ្វើមុន ។

អាទិការណ៍ ន. ហេតុដើម, ហេតុដំបូង, មូលហេតុ ។

អាទិនវការណ៍ ន. ហេតុ, ដំណើរទាក់ទងដោយ
សេចក្ដីទុក្ខព្រួយ ។

អាទិតភណ្ឌ ន. ផើរ៉ង់អ្នកដំណើរ, កន្ត្រកអ្នកដំណើរ។

អាបណក ឬ អាបណិក ន. អ្នកលក់ទំនិញក្នុងផ្សារ (អ្នកផ្សារ) ។

អាបត្តិ (ម.ថ. អាបាត់) ន. ទោសដែលភិក្ខុត្រូវព្រោះល្មើសពុទ្ធប្បញ្ញត្តិ ។

អាប័ទ (ម.ថ. អាបាត់) ន. គ្រោះកាច, អន្តរាយ ។

អាបុច្ឆនបណ្ណ,-ប័ត្រ ន. សំបុត្រលាគ្នា ។

អាបុច្ឆនភាព ន. ដំណើរលាគ្នា ។

អាពាធ ន. ជម្ងឺ ។

អារម្ភ ន. ការប្រារព្ធ, ការតាំងផ្ដើម, ការរៀបចំ ។

អារម្មណ៍ ន. គ្រឿងគោចររបស់ចិត្ត, គ្រឿងទាញទាក់

របស់ចិត្ត ។

អាភោគភាព ន. ភាពនៃសេចក្ដីពេញចិត្ត, ការកប់រក ។

អាភោគការណ៍ ន. ហេតុដែលនាំឲ្យពេញចិត្ត, ហេតុដែលនាំឲ្យមានសេចក្ដីពេញចិត្ត ។

អាវរណ៍ (ម.ថ. អាវៈ–) ន. គ្រឿងការពារ, គ្រឿងទប់, កាំង ។

អាវរណការណ៍ ន. ហេតុជាគ្រឿងការពារ ។

អាវបនការ,–ករ ន. អ្នកធ្វើរបងជាំដំណាំ ។

អាវុធករ ន. ជាងធ្វើគ្រឿងប្រហារ ។

អាវុធកោដ្ឋាគារ, អាវុធាគារ, អាយុធគ្រឹះ, អាយុធាគារ ន. ឃ្លាំងអាវុធ, ឃ្លាំងដាក់គ្រឿងប្រហារ ។

អាវុធយុទ្ធភណ្ឌ ន. គ្រឿងប្រហារនឹងភណ្ឌៈសម្រាប់ចំបាំង ។

អាវុធសន្និច័យ ន. ការសាងគ្រឿងសស្ត្រាទុក (សម្រាប់ការពារប្រទេស) ។

អាវេសន៍ ន. រោងធ្វើការ, ផ្ទះ, ប្រកផ្បុរ ។

អាសអាភាសន៍,–ភាស គុ. ដែលចេញជាដល់គេក្តីខ្មាស ដែលជាពាក្យអាសគ្រាម ។

អាស្រមបទ (ម.ថ. អាស្រំម៉ៈបត់) ន. ទីក្បែរអាស្រម (កន្លែងនៅសម្រាប់ធ្វើចិត្តឲ្យស្ងប់រម្ងាប់) ។

អាទ្ហាហណដ្ឋាន ន. ទីសម្រាប់ធ្វើឈាបនកិច្ច, ទីប៉ាឆា ។

ឥដ្ឋផល ន. ផលជាទីពេញចិត្ត, ផលដែលគួរប្រាថ្នា ។

ឥដ្ឋមនុញ្ញផល ន. ផលជាទីពេញចិត្តដែលសម្រេចដូចបំណង ។

ឥដ្ឋារម្មណ៍ ន. អារម្មណ៍ដែលត្រូវចិត្តអារម្មណ៍ដែលជាទីគួរប្រាថ្នា ។

ឥណាព័ន្ធ ន. ការជំពាក់បំណុលគេ, (ជាឥណព័ន្ធក៏បាន) ។

ឥត្ថាគារ ន. ល្វែងឬបន្ទប់ដែលនៅសុទ្ធតែស្រីៗ ។

ឥត្ថីរតន៍ ន. ស្ត្រីកែវ, ស្រីឆើតឆាយ ។

ឥទ្ធិពល ន. កម្លាំងនៃឫទ្ធិ ។

ឥន្ទបត្ត ឥន្ទប្រ័ស្ថ (ម.ថ.-បាត់,-ប្រាស់) ន. ឈ្មោះក្រុងមួយក្នុងប្រទេសឥណ្ឌាសម័យបុរាណត្រង់កន្លែងក្រុងដេល្លីសព្វថ្ងៃ ។

ឥរាបរ ន. ព្រឹល, ភ្លៀងធ្លាក់ព្រឹល ។

ឥរាវិត៍ ន. មេឃ, ពពក សមុទ្រ ។

ឥរិយាបថ ន. ផ្លូវឬគន្លងនៃឥរិយា, គឺៈដើរ, ឈរ, អង្គុយ, ដេក ។

ឥរិយាបថបរិវត្តន៍ ន. ការផ្លាស់ឥរិយាបថ ។

ឥស្សរភាព ន. ភាពនៃអ្នកធំ, ភាពជាធំ ។

ឥស្សរាធិបតី ន. អធិបតីនៃពួកឥស្សរជន ។

ឥស្សរិយាភរណ៍ (ម.ថ.-ក) ន. គ្រឿងសម្រាប់ដំកើងយស ។

ឧក្រិដ្ឋ, ឧក្រឹដ្ឋ គុ. យ៉ាងធ្ងន់, យ៉ាងតឹងតែង, យ៉ាងម៉ឺងម៉ាត់

ឧច្ចរឹង ន. ព្រៃស្រោង ។

ឧច្ចសទ្ទ,ឧច្ចាសទ្ទ ន. សំឡេងហៅ, សូរហៅ, សូរស្រែកខ្លាំង ។

ឧច្ចារដ្ឋាន ន. បង្គន់ (ឬវច្ចដ្ឋាន) ។

ឧច្ឆេទសម្មានភាព ន. ដំណើរដាច់សេចក្តីរាប់អានគ្នា ។

ឧណ្ណាពស្ត្រ ន. សម្ពត់រោមចៀម ។

ឧត្តមភូមិ ន. ថ្នាក់ខ្ពស់, ជាន់ខ្ពស់ ។

ឧត្តមមន្ត្រី ន. មន្ត្រីថ្នាក់ខ្ពស់, មន្ត្រីរដ្ឋបាលថ្នាក់ខ្ពស់ ។

ឧត្តរប័ដ (ម.ថ.-បាត់) សំពត់សម្រាប់ពានា, សំពត់បង់ក សំពត់សំពក់ដណ្ដប់ (ហៅថា ឧត្តរពស្ត្រ,-ព័ស្ត្រក៏បាន ។

ឧត្តរាព័ត្ត ឬ ឧត្តរាវដ្ដ ន. ដំណើរវិលទៅខាងឆ្វេង, ដើរវិលទៅខាងឆ្វេងជុំវិញទីណាមួយ, ដើរជាឧត្តរព័ត ។

ឧត្តរិគមនាគមន៍ ន. ការទៅមកបន្តគ្នាមិនដាច់ ។

ឧត្តរិភង្គ (ម.ថ.-ភ័ង) សម្លកគូរឬសម្លការ តាមពិតគឺជាឈ្មោះសម្លម្យ៉ាងដែលគេប្រើនៅប្រទេសឥណ្ឌា ។

ឧត្តានការណ៍ ន. ហេតុឬដំណើរងាយ ។

ឧត្តានភាព ន. ភាពងាយ, ដំណើរងាយ ។

ឧត្តាសការណ៍ ឬ ឧត្រាសការណ៍ ន. ហេតុឬដំណើរគួរឲ្យខ្លាចខ្លាំង ។

ឧត្តាសនីយ គុ. ដែលគួរឲ្យខ្លាចខ្លាំង, ដែលគួរតក់ស្លុត ។

ឧត្តាសនីយដ្ឋាន ន. ទីដែលគួរឲ្យខ្លាចខ្លាំង ។

ឧទកន្តរណ៍ (ម.ថ.ឧទៈកន់ដ) ន. ការឆ្លងទឹក ។

ឧទកវារី ន. ទឹកសម្រាប់ក្សត្រទ្រង់ស្រង់ ។

ឧទកសាស្ត្រ ន. វិជ្ជាស្ទង់ទឹក ។

ឧទរកាណ៍ ន. ដំណើរគ្រាន់តែចំអែតពោះ ។

ឧទ្ទេសាចារ្យ ន. អាចារ្យបង្រៀនបាលី, អាចារ្យអ្នកបង្រៀនបាលី ។

ឧទ្យោគភាព ន. ភាពនៃសេចក្ដីប្រឹងប្រែង ។

ឧបករណ៍ (ម.ថ. អ៊ុប៉ៈក) សេចក្ដីទំនុកបំរុង, ការជួយទប់ទល់គ្នា ។

ឧបកិច្ច, ឧបក្រឹត ន. កិច្ចដែលត្រូវធ្វើភ្លាម ៗ, កិច្ចផ្ទាល់ខ្លួន ។

ឧបដ្ឋាក (ម.ថ. អ៊ុ ប័ត ឋាក់) ន. អ្នកដែលបង្ហាញខ្លួន ឲ្យប្រើប្រាស់ ។

ឧបដ្ឋាន ន. ការបំរើបំពាស់ ការទំនុកបំរុង ។

ឧបឌ្ឍ (ម.ថ. -អ៊ុ ប័ត ឋះ) ន. ជិតពាក់កណ្ដាល (ឧបឌ្ឍបថ ជិតពាក់កណ្ដាលផ្លូវ) ។

ឧបត្ថម្ភ ន. ការទំនុកបំរុង, គ្រឿងទំនុកបំរុង, គ្រឿងទល់ទ្រ . . . ។

ឧបនាយក ន. នាយកបន្ទាប់ឬនាយករងពីមហានាយក ឬអធិបតីមក ។

ឧបនិមន្ត ន. ចូលទៅអញ្ជើញផ្ទាល់ ការអញ្ជើញ ឬ និមន្តទុកមុន ។

ឧបនិស័ទ ន. ការកំបាំង, អាថ៌កំបាំង ។

ឧបយោគ ន. ការសមប្រកប, សេចក្ដីសម្រេច

ប្រយោជន៍ ។

ឧបរោធការណ៍ ន. ដំណើរនៃការបិទផ្លូវ ។

ឧបលក្ខិត (ម.ថ. អ៊ុ ប៉ះ ល័ក ខិត) គុ. ដែលបានកំណត់ ចុះទៀនចាត់ហើយ ។

ឧបវាទការណ៍ ន. ហេតុនៃការពោលតិះដៀល ។

ឧបនិវេសន៍ ន. ការអង្គុយសម្រាក, ការសម្រាកលំហែកម្លាំង ។

ឧបាយ ន. ល្បិចល្បង, កិច្ចកល, ផ្លូវគំនិត ។

ឧប្បត្តិការណ៍ ន. មូលហេតុ, ហេតុដែលបណ្ដាលឲ្យកើតឡើង ។

ឧប្បត្តិកេតន៍ (ម.ថ.–កែត) ស្រុកកំណើត, ជាតិភូមិ ។

ឧភតោពាហ៍ គុ. ដែលហូរបែកជាពីរផ្លូវ ។

ឧភតោប័ណ្ណ គុ. កាចដូចគ្នា ។

ឧភយវាក្យបរិវត្តន៍ ន. ការប្រែភាសាមួយទៅមួយឬមកជាភាសាមួយ (ហៅត្រឹមតែ វាក្យបរិវត្តន៍ ក៏បាន) ។

ឧស្ម័ន (ម.ថ. អ៊ុស ស្ម័ន) ន. បំហាយក្តៅ, បំហាយកើនកំសួល ។

ឧស្មកោដ្ឋក ន. បន្ទប់ដែលមានជើងក្រានដុតកើន បង្ហប់ឲ្យមានបំហាយក្តៅ ។

ឧស្មពល ន. កម្លាំងអគ្គិសនី, កម្លាំងឧស្ម័ន (ស.និ.) ។

ឧស្ម័នមន្ទីរ ន. រោងចក្រ (ស.និ.) ។

ឧស្សាហកម្ម ន. ការបង្កើតរបស់ប្រើប្រាស់តាមសម័យនិយម, ការបង្កើតដោយព្យាយាម ។

ឧស្សាហកិច្ច, ឧស្សាហក្រឹត ន. ការរស់ដោយឧស្សាហកម្ម ។

ឧឡារភណ្ឌ ន. របស់មានតម្លៃ ។

ឧឡារភាព ន. ភាពខ្ពង់ខ្ពស់, របស់មានដំឡៃ ។

ឩសវ័ត, ឩសវិដ្ដ ន.គុ. ដែលមានដីប្រៃ, ប្រទេស, តំបន់ដែលមានដីប្រៃ ។

ឯកអគ្គ, ឯកអគ្រ (ម.ថ. អែក អាក់) ប្រសើរឯក ។

ឯកច្ឆត្រ គុ.ន. ដែលមានស្វេតច្ឆត្រតែមួយ, (គឺស្ដេចទ្រង់រាជ្យតែមួយអង្គឯងមានអានុភាពពេញទី) ប្រទេសឯករាជ្យ ។

ឯកច្ឆន្ទ គុ ដែលមានបំណងត្រូវគ្នាតែមួយ, ដែលព្រមចិត្តគ្នា ( ខ្មែរប្រើភាសាថា ឯកច្ឆន្ទ សម្រេចលើខ្លួនមានសិទ្ធិសេរីពេញទី ) ។

ឯកទេស ន. ចំណែកមួយដែលត្រូវលើកយកទាញមក, និយាយដោយឡែក ។

ឯកាធិបតី ន. មន្ត្រីស័ក្ដិធំដែលជាអធិបតីត្រួតត្រារាជការ

ភាណាត្យាបាលគ្នីប្រទេសមួយៗ ។

ឯកាធិបតេយ្យ ន. មុខក្រសួង, នាទី, អំណាចនៃឯកាធិបតី

ឯកគោត្តម័ន ន. ដំណើរទៅជាមួយគ្នា ។

ឯកវណ្ណ, ឰកវណ្ណ ន. ឈ្មោះដំរីព្រះទីនាំងព្រះឥន្ទដំរីឰ-

កវណ្ណ ។

ឯកទ្រឹស្តី ន. អ្នកដែលមានគំនិតយល់ឃើញត្រូវគ្នា, អ្នក

ដែលមានសេចក្តីយល់ឃើញត្រូវគ្នា ។

ឯកភាព ន. ភាពត្រូវគ្នា, ដែលមានបែបបទសណ្តាប់

ធ្នាប់, សំលៀកបំពាក់, ឬកពារត្រូវគ្នា ។

ឯកសារ គុ.ន.ដែលមានខ្លឹមដូចគ្នា, ដែលសុទ្ធតែខ្លឹម

សំបុត្រឯកសារ ។

## បក្កិណ្ណកវិបសាលង្ការ

សន្ធិ ន. ការសន្សំ, ការសំចៃទុក ឬ ការទុកសំចៃ ។

សមាហារ ន. មារយាទល្អ, មារយាទត្រឹមត្រូវ, របៀបរយ ។

សមាគម ន. ការរួមគំនិតគ្នា, ដំណើររួបរួមកិច្ចការជាមួយគ្នា ។

សម្មោធ, សម្មោធន៍ ន. ការថ្វៃនសេចក្ដីដោយច្បាស់លាស់, ការរំឭក ។

សម្មោធ ន. ការដឹងព្រម, ការត្រាស់ដឹង ។

សម្មាស, សម្មាសន៍ ន. ការនិយាយរាក់ទាក់គ្នា, ពាក្យសរសោះអន្ទន, សំដីឆ្លើយឆ្លងឬសាសនដោយលំអុត ។

ស្វៃរជន (ម.ថ. ស្វៃរះ ជន ឬ ស្វៃជន) អ្នកដែលមានអំណាចលើខ្លួន ។

អត្ថន័យ ន. ន័យរបស់សេចក្ដី, លំនាំនៃសេចក្ដី ។

សម្មោទនីយ (ម.ថ. ស័មមោទៈនីយ ឬ–នី) គុ. ដែល

គួររីករាយ, គួរត្រេកអរ, ស្រួលរាយ, រអាករពាយ ។

សាធុព្រឹត្តិ ន. ការប្រព្រឹត្តត្រឹមត្រូវ, មារយាទល្អ ។

សារទុក្ខ ន. ទុក្ខគ្រប់សព្វ, ទុក្ខតាំងពួង ។

អតិក្រឹត ន. លើសច្បាប់ ។

អត្ថវិជ្ជា, អត្ថសាស្ត្រ ន. វិជ្ជាឬក្បួនសម្រាប់រៀនឲ្យ

ស្គាល់កិច្ចការចិញ្ចឹមជីវិតនិងការគ្រប់គ្រងស្រុកទេស ។

ខ្វះសង្ស័យ លះបង់, បោះបង់ ។

អភិហារ ន. ការគស៊ូពេញកម្លាំង ។

ខ្ពត្តិលោភ ន. លាភដែលបេះតែបានច្រើន ១ មិនដាច់ ។

អគុទ្ទត ន. បំរើដែលចាត់ឲ្យទៅស្ដាប់ការ ។

អនិមិត្ត គុ. ដែលរកហេតុជាគ្រឿងកំណត់គ្មាន, ដែល

រកបំណាំមិនបាន ។

អធិវាសន៍ ន. ទីលំនៅ, សេចក្ដីអត់ទ្រាំ, ការលាប គ្រឿងក្រអូប ។

ឧបធារណ៍ ន. ការចូលទៅទ្រទ្រង់, ការពិចារណាមើល, ការក្រោលមើល ។

អាស្រវិបាវាយណ៍ គុ. ដែលលេចឮកេរ្ដិ៍ឈ្មោះសោហ្មងសាយសុសទៅឆ្ងាយ ។

អាសន្នអន្ត្រក្រ ន. ការក្រម្ភកិច្ចធុរៈយ៉ាងក្រ. ដែលគ្រាប់តែមកដល់ រកផ្លូវឧបាយកែបានដោយលំបាក ។

សច្ចាប្រណិធាន ន. ការតាំងពាក្យពិត, ការសម្បូរសម្រួង, ការប្រកាសពាក្យសំបថ ។

សោធន្តការី ន. អ្នកត្រួតត្រា, អ្នកដែកគេ, ពួកកងត្រវែលអ្នកពិនិត្យការណ៍ (ជាសុធន្តកម្ម, សុធន្តករ ក៏មាន)។

អភិវិឡ្ហន៍ គុ. ដែលចំរើនក្រៃលែង, ដែលចំរើនណាស់ ។

ន. ការដែលចំរើនក្រៃលែង ។

អភុទ្ធកៈ, អភុទ្ធក គុ. ដែលមិនចំរើន, ដែលមិនប្រសើរ ។

ឧរច្ឆ័ទ, ឧរត្ត្រាណ ន. គ្រឿងពាក់ទ្រូង ។

អប្បោគណ្ឋ (ម.ថ.—គ័ន) គុ. ដែលជាអ្នកខ្លាចច្រើនៗ

ហិមាគម ន. កាលឬសម័យជាទីមកនៃទឹកសន្សើម(រដូវរងា) (ជួនប្រើជា ហិមាគមន៍ ក៏មាន) ។

ហិមករ ន. អ្នកធ្វើឲ្យត្រជាក់ ។

ហិមទ្យោតិ (ម.ថ—ទ្យោត) ន. អ្នកមានពន្លឺត្រជាក់មានរស្មីត្រជាក់ (ព្រះចន្ទ) ។

ហិរញ្ញប័ដ,-បដ្ដ ន ដំបារប្រាក់, ដំបារប្រាក់ចារឹកនាមដែលព្រះរាជាទ្រង់ព្រះរាជទាន ។

ហិតមិត្ត ន. មិត្រអ្នកផ្គុងផ្ដើមផលប្រយោជន៍ឲ្យ ។

សង្ឃុដ្ឋ គុ. ដែលគឹកកងហើយ, ដែលអ៊ូរអែះហើយ ។

សុន្ទរោភិទ ន. ទាវទល្អ, ជម្ងូនមានត្រូវ ។

សីមន្តរិក ន. ទីដែលកំនត់ព្រំប្រទល់, (ទីដែលកំនត់ព្រំ-ប្រទល់ដែន) ។

សិព្វនយន្ត ន. ម៉ាស៊ីនដេរ, យន្តដេរ (ជាសព្វយន្តក៏បាន)។

សិប្បជាតិ ជាតិខ្យងខ្ចៅ, គ្រំលៀសខ្ចៅជាដើម ។

សុវិទ គុ. ដែលស្ដីប្រដៅបានដោយងាយ, ស្រណុកប្រៀនប្រដៅ ។ ន. អ្នកដែលគេស្ដីប្រដៅបានដោយ-ងាយមនុស្សសុវិទ ។

អត្តពលកម្ម,អត្តពលកិច្ច ន. អំពើឬកិច្ចការដែលកើតពីកម្លាំងខ្លួន ។

ឧដ្ឋានវន្ត ន. អ្នកដែលមានសេចក្ដីខំប្រឹងពេញកម្លាំង, អ្នកដែលមានព្យាយាមដ៏ក្លៀវក្លា ។

ហិរញ្ញមូល ន. ប្រាក់ដើម, ប្រាក់ដើមទុន ។

អក្ខរសម្បត្តិ ន. ការមិនឃ្លៀងឃ្លាតអក្សរ ។

អក្ខរវិបត្តិ ន. ការឃ្លៀងឃ្លាតឬសំឡេងអក្សរ ។

អគមនីយ ន. ហេតុដែលមិនគួរបណ្ដោយចិត្តឲ្យប្រព្រឹត្ត, ការពុំគួរគប់រក ។

អគ្គយោធិន ន. សេនាប្រមុខ, ស្ដេចសឹក ។

អគ្គសព្ទ, អគ្គវាទ ន. ពាក្យខ្ពស់, សំដីខ្ពស់ (ពាក្យវប្បធម៌) ។

អង្គភាព ន. ភាពរាងកាយ ។

អង្គុលព្យាភរណៈ ន. ចិញ្ចៀន, នាលិកាដៃជាដើម ។

អបលគ្រាម ន. ស្រុកដែលស្ងប់ឥតបះបោរ ។

អតិមហាគ្ឃ គុ. ដែលមានដំឡៃច្រើនក្រៃពេក ។

អត្ថវិនិច្ឆ័យ ន. ការកាត់សេចក្ដី ។

អធិគម ន. ការបានដល់ ការបានសម្រេច ។

អយស្កម្ម ន. ជាងដែក ។

ឧត្តុនិយមវិជ្ជា ន. ការចេះដឹងក្នុងការកំណត់ផ្លូវ (សម័យនិយមច្រើនសំដៅថា វិជ្ជាខាងការកំណត់ដឹងអាកាស-ធាតុ ដើម្បីប្រើសំទៀងវិទ្យុជាផ្លូវការ) ។

អយោធន៍ ន. សង្គ្រាម, ចម្បាំង ។

អាហារូបករណ៍ ន. ការទំនុកបំរុងអាហារ, ការជួយបីបាច់, ជួយគាំទ្រ អាហារ (ដែលសិស្ស ឬ និស្សិតដែលដេកនៅសិក្សាក្នុងសិក្ខាគារ) ។

សីតុណ្ហភាព ន. ភាពឬដំណើរក្តៅនឹងត្រជាក់ ។

ស្ថាបនាកម្ម (ម.ព. ស្ថាបនា ផង) ។

អស្សប្ញទ្ធិ, អស្សប្ញទ្ធិ ន. មេដៃយអស្សប្ញទ្ធិ (ម.ព. អស្សទ្ធិ) ។

សត្យាក្រិត ន. ការធ្វើសេចក្តីពិត, ការពោលពាក្យពិត ។

សម្ភារ ន. អគ្គ, គ្រឿងប្រុង, ការសន្សំ, ការសាងសន្សំកុសល,... ។

ស្ថានការណ៍ ន. ហេតុដែលតាំងឡើង,... ។

សិទ្ធ គុ. ដែលសម្រេចហើយ, ដែលស្រេចហើយ, ដែលសម្រេចតាមច្បាប់ហើយ, ដែលស័ក្តិសិទ្ធិ, សម្បូណ៌, ពូកែ, មានប្រាជ្ញាវៃ... ។

សិទ្ធិ ន. សេចក្តីសម្រេច, ការសម្រេចប្រយោជន៍, ការដាច់ស្រេច, សេចក្តីសម្រេចតាមអំណាចច្បាប់, អំណាច, សេចក្តីអន់អាច, មុខការដែលត្រូវសម្រេចលើខ្លួន ។ល។

សេរី ន. អ្នកដែលមានអំណាចលើខ្លួន, អត្តាធីន ។

# អក្សរសាស្ត្រជាតិនិយម

## ភាគពិសេស

ចប់ដោយសង្ខេប

ទូច-គីមសៀង

# សំឡេងឯករាជ្យ

ចំរើន! ចំរើន! – ឲ្យទាន់បូរាណ
ស្រុកយើង! ថ្កើងថ្កាន ជំនាន់អង្គរ
គួរនាំគ្នាដើរ កុំនាំវី – វរ ។
សម័យអង្គរ – ជាស្រុកថ្កើងថ្កាន ។

ឯក – ទោ

ឱ ខេមរជាតិ! – ទាំងប្រុសទាំងស្រី ។
រក្សាទឹកដីឲ្យបានសុខសាន្ត
បង្កើតសិប្បា – ឧស្សាហ៍គិតគាន ។
ឲ្យស្រុកបំណាន! – លឿនដូចអង្គរ ។

ឯក – ទោ

ចំរើន! ចំរើន! – ឲ្យទាន់សម័យ
ជំនាន់ក្សត្រថ្ងៃ! កាលទ្រង់តាមតារ

យកឯករាជ្យជាតិ ! ព្រះអង្គមិនរា ៗ

ដាក់រាជសម្ភារ ! ចាស្រ័យទឹករាស្ត្រ ៗ

ជយោ !

ព្រះអង្គសាងសុខ ! ឲ្យជាតិខេមរា ៗ

គួរដើរគ្រប់គ្នា ! កុំនាំគេបរាស

ពន្ទឹស្មើ ! វែងចាំង ទុរាស ៗ

សាងសុខជូនរាស្ត្រ ! ជំនាន់សម័យ ៗ

ជយោ !

អតិសុគ្ន. – ខោ !

## បទបំពេកូនសម័យឯករាជ្យ

កូនអើយនាងដេកទៅ ពៅនាងកុំយំ ទំរាំកូនធំ ថ្ងៃទៅសិក្សា
រៀនឲ្យចេះដឹង ខំប្រឹងឧស្សាហ៍ ជួយជាតិសាសនា
មហាក្សត្រិយ៍ឲ្យថ្កើង ៗ

## បទសិក្សាជាតិ

កូនអើយនាងដេក ថ្ងៃកុំយំពេក-នាងខ្លាចក្រ ! ក្អែកពាំធំៗ
មុំកុំត្រេកអរ រអែងសត្រូវ ពាំបុមនុស្សខ្ជិល ៗ កូនធំ-
នាងកាលណា ទៅខំ (ថ្ងៃអើយ) សិក្សា រៀនសូត្រ
សាស្ត្រសិល្ប៍ ឲ្យបានចេះដឹង ខំប្រឹងកុំខ្ជិល ចេះហើយ
រីងរិល (ថ្ងៃអើយ) ស្វែងសិល្ប៍ជីវៈ ៗ

## បទថ្ងៃរះបំព្រាង

ថ្ងៃរះបំព្រាង (មុំអើយ)-ពងត្រចាំង ស្រណោះកាល
ច្បាំង (ថ្ងៃអើយនែ !) បាកំងទៅស្រុក ទាំងប្រុសទាំង
ស្រី គ្មានក្តីវិតក្ក បាកំងទៅស្រុក (ថ្ងៃអើយនែ !) ចាញ់សន្តិ.

(សន់) វិធី ៗ កូនធំនាងខាងក្រោយ ប្រយ័ត្នកុំភ្លោយ
រក្សាធានី ឲ្យបានគង់វង្ស ដូចព្រះភូមី
ស្វែងសព្វទិសទី (ថ្ងៃអើយ !) រកឯកពង្សជាតិ ៗ

កុំបំពេជាៈ ៖

កូនអើយដេកទៅ ពៅងើយកុំយំ ទំពាំបាយធំញុំហើយដើរ-លេង ៗ

បើបំពេដូចបទនេះ ដល់ពេលកូនយើងធំឡើងវារត់តែលេង (ព្រោះប្រាប់វាឲ្យរត់លេង) បើយើងឲ្យទៅរៀន វាប្រកែកថាម៉ែឯងឲ្យខ្ញុំដើរលេង (យល់ឃើញថាបញ្ចាញ់សំដីកូនហើយ) ដូច្នេះត្រូវផ្លាស់ទើបបាន ៗ

ជយោ ! ! គរុណវិហារណ៍

ទូច-គឹមសៀង

រោងពុម្ព បណ្ណាគារគីម-គី

លេខ ៨៨ វិថីអែម៉ក្រង់ ភ្នំពេញ

ឈ្មោះថ្មីប្រែ ហៅ វិថីតេជោដំឌិន

គឺនៅផ្លូវខាងជើងវត្តឧណ្ណាលោមត្រង់ទៅលិច

ផ្លូវខាងកើតវត្តសារាវ័ន្តត្រង់ទៅជើងរំលងផ្ទះមួយផ្លូវ ដល់កាច់ជ្រុង ងាកទៅលិចបន្តិច គឺនៅខាងកើតរោងកុនព្រហ្មបាយ័នផ្ទាល់ ។

## សេចក្ដីជូនដំណឹង

រោងពុម្ព បណ្ណាគារខ្ញុំបាទមានទទួលបោះពុម្ពសៀវភៅនិងប្រូក្រាម ឬ បង្កាន់ដៃផ្សេងៗ គ្រប់យ៉ាង ។

សូមលោកអ្នកអញ្ជើញចូលដោយមេត្រី

រោងពុម្ព-អ៊ុក-ម៉ុ-កុល វិថីប៉ាស្ទ័របន្ត ភ្នំពេញ